ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ម៉ូឌុលទី ៤ ខ្ញុំ និងបំណងប្រាថ្នារបស់ខ្ញុំ



## កម្មវិធីសិក្សា Gap Inc. P.A.C.E.

## សម្រាប់សិស្សវ័យជំទង់ (អាយុ១១ ដល់ ១៣ឆ្នាំ)

គាំទ្រដោយក្រុមហ៊ុន Gap Inc.

រៀបចំដោយ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

# កម្មវិធីសិក្សា Gap Inc. P.A.C.E.

# ការដាក់ទុនលើជំនាញថ្មីដើម្បីអនាគត

## Personal Advancement and Career Enhancement

## កម្មវិធីសម្រាប់ក្មេងស្រីវ័យជំទង់
## ( អាយុ១១ ដល់ ១៣ឆ្នាំ )

### សៀវភៅណែនាំសម្រាប់គ្រូបង្រៀន

# មាតិកា


**សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅ** ..... i

**ម៉ូឌុលទី៤ ៖ ខ្ញុំ និងបំណងប្រាថ្នារបស់ខ្ញុំ** ..... 1

**ជំពូកទី១ ៖ បំណងប្រាថ្នា** ..... 3

មេរៀនទី១ ៖ រយៈពេលកំណត់នៃបំណងប្រាថ្នារបស់ខ្ញុំ ..... 4

មេរៀនទី២ ៖ ល្បែងស្តីពីបំណងប្រាថ្នា ..... 10

មេរៀនទី៣ - មិត្តទាំង៥នាក់របស់ខ្ញុំ ៖ គោលដៅ និងការកំណត់គោលដៅ ..... 14

**ជំពូកទី២ ៖ ការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលា** ..... 23

មេរៀនទី៤ ៖ ការគ្រប់គ្រងពេលវេលា ..... 24

មេរៀនទី៥ ៖ តើខ្ញុំសម្រេចចិត្តដោយរបៀបណា? ..... 28

មេរៀនទី៦ ៖ ការគ្រប់គ្រងប្រាក់ ..... 35

មេរៀនទី៧ ៖ តើ ស៊ីណារតន៍ត្រូវធ្វើអ្វី? ..... 40

**ជំពូកទី៣ ៖ ភាពជាអ្នកដឹកនាំ** ..... 51

មេរៀនទី៨ ៖ នរណាជាអ្នកដឹកនាំ ..... 52

**ជំពូកទី៤ ៖ សិទ្ធិមនុស្ស** ..... 57

មេរៀនទី៩ ៖ ការណែនាំពីសិទ្ធិមនុស្ស ..... 58

មេរៀនទី ១០ ៖ ការយល់ដឹងពីសិទ្ធិមនុស្ស ..... 61

**ឧបសម្ព័ន្ធទី១ ៖ សន្លឹកកិច្ចការសិស្ស** ..... 65

**ឧបសម្ព័ន្ធទី២ ៖ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន** ..... 72

# សេចក្តីណែនាំស្តីពីការប្រើប្រាស់សៀវភៅ

## ១. សេចក្តីផ្តើម

សៀវភៅម៉ូឌុលទី៤សម្រាប់ក្មេងស្រីវ័យជំទង់(អាយុពី១១-១៣ឆ្នាំ)មានគោលបំណងឱ្យសិស្សចេះ និងយល់ពីអ្វីដែលជាបំណងប្រាថ្នា និងអ្វីដែលត្រូវសម្រេចឱ្យបាន ព្រមទាំងធ្វើឱ្យសិស្សមានលទ្ធភាពកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់ខ្លួន។ ម៉ូឌុលនេះមាន៤ជំពូកគឺ ៖ ១) បំណងប្រាថ្នា ២) ការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលា ៣) ភាពជាអ្នកដឹកនាំ និង ៤) សិទ្ធិមនុស្ស ដោយជំពូកនីមួយៗមានមេរៀនដាច់ៗដោយឡែកពីគ្នាចំនួន១០មេរៀន។ ជំពូកនីមួយៗមានកំណត់ពីលទ្ធផលសិក្សាដែលរំពឹងទុកសម្រាប់សិស្សរៀងៗខ្លួន។

ជំពូកស្តីពីបំណងប្រាថ្នាធ្វើឱ្យសិស្សយល់ដឹងពីក្តីសុបិន និងបំណងប្រាថ្នារបស់ខ្លួន ព្រមទាំងផ្តល់លទ្ធភាពឱ្យសិស្សកំណត់ និងធ្វើសកម្មភាពផ្សេងៗឆ្ពោះទៅរកការសម្រេចបានបំណងប្រាថ្នាដែលកំណត់។ ជំពូកស្តីពីការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលាធ្វើឱ្យសិស្សយល់ពីសម្ពាធផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់អាទិភាព និងការសម្រេចចិត្តរបស់ពួកគេសម្រាប់អនាគតផ្ទាល់ខ្លួនជាពិសេស សម្រាប់ក្មេងស្រី។ ចំពោះជំពូកស្តីពីភាពជាអ្នកដឹកនាំជួយសិស្សឱ្យយល់ពីសក្តានុពលភាពរបស់ខ្លួនទាក់ទងនឹងភាពជាអ្នកដឹកនាំ ជាពិសេសសម្រាប់ក្មេងស្រី ដើម្បីឱ្យពួកគេមានលទ្ធភាពធ្វើការផ្លាស់ប្តូរ ទទួលបានការគាំទ្រផ្នែកស្មារតី និងធនធានផ្សេងៗដែលពួកគេអាចនឹងមិនទទួលបានដោយសារតែការលម្អៀង និងការរើសអើងផ្នែកយេនឌ័រ។ ជំពូកស្តីពីសិទ្ធិមនុស្សធ្វើឱ្យសិស្សយល់ពីសិទ្ធិផ្ទាល់ខ្លួន និងសិទ្ធិរបស់អ្នកដទៃដែលជាសិទ្ធិមូលដ្ឋានមួយដែលអាចរំលោភបំពានបាន។

## ២. វត្ថុបំណងរបស់ម៉ូឌុល

នៅចុងបញ្ចប់នៃម៉ូឌុលនេះសិស្ស ៖

- មានលទ្ធភាពគិត និងកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់របស់គេ។
- យល់ពីរបៀបអនុវត្តឆ្ពោះទៅរកការសម្រេចបំណងប្រាថ្នារបស់ខ្លួន។
- កសាងការយល់ដឹងពីវិធីសាស្រ្តជាក់លាក់ក្នុងការរៀបចំផែនការដើម្បីសម្រេចបាននូវបំណងប្រាថ្នារបស់ខ្លួន។
- យល់ដឹងស៊ីជម្រៅពីសិទ្ធិមនុស្ស និងសារៈសំខាន់នៃសិទ្ធិទាំងនេះនៅក្នុងជីវិត និងបរិបទជាក់ស្តែងរបស់ខ្លួនផ្ទាល់។

## ៣. សេចក្តីពន្យល់ពីការប្រើប្រាស់ម៉ូឌុល

សៀវភៅនេះគឺជាសៀវភៅសម្រាប់គ្រូដែលបានរៀបចំរួចជាស្រេចនូវផែនការ ឬលំនាំនៃការបង្រៀនសម្រាប់ជំនួយដល់គ្រូក្នុងការបង្រៀនសិស្ស។ វាចែកចេញជា៥ផ្នែកធំៗតាមលំដាប់លំ

ដោយពោលគឺ ១) ម៉ូឌុល ២) ជំពូក ៣) មេរៀន ៤) ឧបសម្ព័ន្ធទី១ សន្លឹកកិច្ចការសិស្ស និង ៥) ឧបសម្ព័ន្ធទី២ ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន។ នៅក្នុងម៉ូឌុលមានបែងចែកជាជំពូកធំៗចំនួន៤ ហើយនៅក្នុងជំពូកនីមួយៗមានចំនួនមេរៀនជាក់លាក់ទៅតាមភាពចាំបាច់របស់ជំពូក។

**ផ្នែកនៃម៉ូឌុល** ផ្តល់នូវការណែនាំទូទៅទាក់ទងនឹងខ្លឹមសារទាំងមូលនៃប្រធានបទ ជំពូក និងមេរៀន។ ដូច្នេះនៅក្នុងផ្នែកនេះ បានដាក់បញ្ចូលនូវ៖ ទិដ្ឋភាពទូទៅនៃម៉ូឌុល រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងរបស់ម៉ូឌុលដើម្បីឱ្យគ្រូបង្រៀនយល់ដឹងបានទូលំទូលាយពីខ្លឹមសារទូទៅរបស់ប្រធានបទទាំងមូល។

**ផ្នែកនៃជំពូក** ផ្តល់នូវការណែនាំជាក់លាក់សម្រាប់ប្រធានបទរួមរបស់មេរៀនទាំងមូលនៅក្នុងជំពូកនីមួយៗ។ ដូចគ្នានឹងផ្នែកម៉ូឌុលដែរ បានដាក់បញ្ចូលនូវ៖ ទិដ្ឋភាពទូទៅ រយៈពេលឬចំនួនម៉ោងបង្រៀនសរុប ចំនួនលំនាំបង្រៀន និងវត្ថុបំណងដាច់ដោយឡែកសម្រាប់ជំពូកនីមួយៗដើម្បីឱ្យគ្រូបង្រៀនយល់ដឹងពីខ្លឹមសារទូទៅរបស់ជំពូកនីមួយៗ។

**ផ្នែកនៃមេរៀន** ផ្តល់នូវព័ត៌មានលម្អិតសម្រាប់ការងាររៀបចំជាមុនរបស់គ្រូបង្រៀន។ នៅក្នុងមេរៀននីមួយៗមានកំណត់ និងរៀបចំតាមលំដាប់លំដោយនូវ ៖ រយៈពេល វត្ថុបំណង សម្ភារៈដែលត្រូវការ សេចក្តីណែនាំ និងចំណុចសម្រាប់ការពិភាក្សា។ នៅខាងចុងនៃមេរៀន ក៏បានបញ្ចូលនូវ«គន្លឹះសម្រាប់គ្រូបង្រៀន និងសារសំខាន់ៗ»ដើម្បីជាជំនួយដល់គ្រូបង្រៀនផងដែរ។

**ផ្នែកឧបសម្ព័ន្ធទី១** សន្លឹកកិច្ចការសិស្សមានបញ្ជាក់ច្បាស់លាស់ពីកិច្ចការសម្រាប់សិស្សដែលត្រូវបំពេញនៅក្នុងថ្នាក់ និងកិច្ចការផ្ទះ។

**ផ្នែកឧបសម្ព័ន្ធទី២** ទម្រង់វាយតម្លៃសិស្សមុន និងក្រោយពេលបង្រៀន គឺជាទម្រង់ស្ទង់ដារដែលសិស្សត្រូវបំពេញមុនពេលរៀន និងក្រោយពេលបញ្ចប់ដើម្បីឱ្យគ្រូងាយស្រួលក្នុងការពិនិត្យមើលលទ្ធផលសិក្សារបស់សិស្សក្រោយពេលបញ្ចប់ម៉ូឌុលនេះ។

- **ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស**

មានព័ត៌មានទាក់ទងនឹងរបៀបចាប់ផ្តើមពីការបង្រៀនសិស្ស ឬផ្នែកដែលទាក់ទងនឹងសកម្មភាពនៃការបង្រៀន និងរៀន។ វាក៏ផ្តល់នូវការណែនាំពីការរៀបចំសម្ភារៈ និងឯកសារដែលគ្រូបង្រៀនត្រូវការឬអានសម្រាប់ការបង្រៀន និងរៀន។

- **សម្ភារឧបទ្ទេស**

ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបពីសម្ភារឧបទ្ទេស ដែលភាគច្រើនជាសម្ភារៈមូលដ្ឋានដូចជា

ក្តារខៀន ដីស ឬហ្វឺត ស្កុត កន្ត្រៃ ប៊ិក សៀវភៅ ក្រដាសទំហំផ្សេងៗគ្នា ក្រដាសព័ត៌មាន ឬឯកសារផ្សេងៗជាដើម។ សម្ភារៈឯកសារផ្សេងៗទៀតនៅក្នុងសៀវភៅនេះក៏ត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្តដែរតាមរយៈសន្លឹកកិច្ចការសម្រាប់សិស្សដែលមានភ្ជាប់នៅក្នុងសៀវភៅនេះ។

- **វត្ថុបំណង**

ផ្តល់នូវឃ្លា ឬប្រយោគជាក់លាក់មួយចំនួនពីអ្វីដែលត្រូវសម្រេចឱ្យបាន។ សម្រាប់ចំណុចនេះ វត្ថុបំណងចែកចេញជា៣ផ្នែកធំៗដូចរៀបរាប់ខាងលើ ពោលគឺ ៖ ១) វត្ថុបំណងទូទៅដែលមានកំណត់នៅក្នុងផ្នែកនៃម៉ូឌុល ២) វត្ថុបំណងដែលមានលក្ខណៈជាក់លាក់ដែលមានកំណត់នៅក្នុងផ្នែកនៃជំពូក និង ៣) វត្ថុបំណងជាក់លាក់សម្រាប់មេរៀននីមួយៗ។

- **ជំហាន និងលំនាំនៃការបង្រៀន និងរៀន**

នេះជាផ្នែកមេរៀនពិតប្រាកដ។ នៅក្នុងផ្នែកនេះមានផ្តល់ព័ត៌មានទាក់ទងនឹងរយៈពេលបង្រៀន និងរៀន វត្ថុបំណង សម្ភារៈដែលត្រូវការ និងសេចក្តីណែនាំដែលជាផ្នែកដ៏សំខាន់សម្រាប់គ្រូបង្រៀនក្នុងការធ្វើសកម្មភាពក្នុងពេលបង្រៀន និងរៀន។ នៅក្នុងផ្នែកនៃ «សេចក្តីណែនាំ» មានបញ្ជាក់នូវសកម្មភាពដែលគ្រូបង្រៀនត្រូវធ្វើ សំណួរបំផុសគំនិត ឧទាហរណ៍ និងព័ត៌មានផ្សេងៗទៀត។ ដូចដែលបានបញ្ជាក់ពីខាងលើ «គន្លឹះសម្រាប់គ្រូបង្រៀន និងសារសំខាន់ៗ»ដែលនៅចុងបញ្ចប់នៃមេរៀននីមួយៗ ក៏ផ្តល់នូវការណែនាំបន្ថែមសម្រាប់ដំណើរការបង្រៀន និងរៀន និងខ្លឹមសារផ្សេងៗដែលគ្រូបង្រៀនអាចណែនាំ និងពន្យល់សិស្សបន្ថែមទៀតទៅលើខ្លឹមសារមេរៀន។

- **ការប្រើប្រាស់និមិត្តសញ្ញា**

និមិត្តសញ្ញាមួយចំនួនត្រូវបានដាក់បញ្ចូលនៅក្នុងសៀវភៅនេះដើម្បីឱ្យគ្រូបង្រៀនមានការចាប់អារម្មណ៍ និងងាយស្រួលយល់ និងប្រើប្រាស់។ និមិត្តសញ្ញាទាំងនោះរួមមាន ៖

| | | |
|---|---|---|
| 🏆 វត្ថុបំណងម៉ូឌុល ឬជំពូក | ៖ | ចំណេះដឹងក្រោយរបស់សិស្សដែលទទួលបាននៅក្នុងម៉ូឌុលទាំងមូល និងជំពូកនីមួយៗ។<br>☺ ចំណេះដឹងលម្អិតនីមួយៗដែលសិស្សទទួលបាន។ |
| 🕘 រយៈពេល | ៖ | ចំនួនម៉ោងសម្រាប់មេរៀននីមួយ។ |
| ➲ វត្ថុបំណងមេរៀន | ៖ | លទ្ធផលសិក្សាដែលសិស្សសម្រេចបានក្រោយពីបញ្ចប់មេរៀននីមួយៗ។ |
| 🕮 សម្ភារៈដែលត្រូវការ | ៖ | មានសរសេរនៅក្នុងមេរៀននីមួយៗដែលតម្រូវឱ្យគ្រូបង្រៀនរៀបចំទុកជាមុន។ |
| 📢 សេចក្តីណែនាំ | ៖ | ចំណុចនានាដែលគ្រូបង្រៀនត្រូវអនុវត្តជាទូទៅក្នុងពេល |

បង្រៀននិងរៀន។
☞ ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវធ្វើ។

🗣 ចំណុចសម្រាប់ការពិភាក្សា ៖ បញ្ជាក់ពីចំណុចសម្រាប់ការពិភាក្សាក្រុមតូច ឬក្រុមធំ។
◈ សំណួរបំផុសគំនិត ឬពិភាក្សាក្នុងពេលបង្រៀន និងរៀន។
✍ ចម្លើយសម្រាប់សំណួរនីមួយៗ ឬការពន្យល់ទូទៅ។

⊶ គន្លឹះសម្រាប់គ្រូបង្រៀន ៖ ចំណុចបន្ថែមដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែមក្នុងពេលបង្រៀន និងរៀន។
🕯 ចំណុចនីមួយៗដែលគ្រូបង្រៀនត្រូវរៀបចំ អនុវត្ត ឬពន្យល់បន្ថែម។

✉ សារសំខាន់ៗ ៖ ខ្លឹមសារសង្ខេបរបស់មេរៀននីមួយៗដែលគ្រូបង្រៀនត្រូវបញ្ជាក់ប្រាប់សិស្ស។
🗎 ខ្លឹមសារសង្ខេបនីមួយៗ។

## ៤. សន្លឹកកិច្ចការសិស្ស

នៅខាងក្រោយនៃសៀវភៅនេះមានដាក់បញ្ចូលនូវសន្លឹកកិច្ចការសិស្ស *(ឧបសម្ព័ន្ធទី១)*។ មេរៀនមួយចំនួនក្នុងចំណោមមេរៀនទាំងនេះមានឯកសារ និងលំហាត់សម្រាប់សិស្ស។ តាមការជាក់ស្តែងគ្រូអាចថតចម្លងលំហាត់ ឬអាចរៀបចំសន្លឹកកិច្ចការសិស្សនីមួយៗសម្រាប់ចែកជូនដល់សិស្ស។ តាមការអនុវត្តជាក់ស្តែង និងលក្ខណៈពិសេសរបស់ម៉ូឌុល សន្លឹកកិច្ចការសិស្សគប្បីដាក់បញ្ចូលគ្នាទាំង៤ម៉ូឌុលដើម្បីឱ្យសិស្សអាចមើលឡើងវិញបាននៅពេលដែលត្រូវការ ព្រោះថាម៉ូឌុលទាំង៤ពាក់ព័ន្ធនឹងការប្រតិបត្តិល្អច្រើនក្នុងជីវិតប្រចាំថ្ងៃ។

## ៥. ខ្លឹមសារសង្ខេបរបស់ម៉ូឌុល

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបរបស់មេរៀនទាំង១០ដែលមាននៅក្នុងម៉ូឌុលនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | សេចក្តីសង្ខេប |
|---|---|---|
| **ជំពូកទី១ ៖ បំណងប្រាថ្នា** | | |
| ១. រយៈពេលកំណត់នៃបំណងប្រាថ្នារបស់ខ្ញុំ | ៦០នាទី | - សិស្សមានលទ្ធភាពកំណត់ក្តីសុបិន និងបំណងប្រាថ្នាពេលអនាគតរបស់ខ្លួន។ |
| ២. ល្បែងស្តីពីបំណងប្រាថ្នា | ៦០នាទី | - សិស្សអាចកំណត់ពីឱកាស និងឧបសគ្គដែលគេអាចជួបប្រទះក្នុងការបំពេញតាមបំណងប្រាថ្នារបស់ពួកគេ។<br>- សិស្សស្វែងរកវិធីនានាដែលពួកគេអាចគាំទ្រគ្នាទៅវិញទៅមកនៅក្នុងការធ្វើដំណើរនេះ។ |
| ៣. មិត្តទាំង៥នាក់របស់ | ៦០នាទី | - សិស្សយល់ពីគោលដៅ និងការកំណត់គោលដៅ។ |

| | | |
|---|---|---|
| ខ្ញុំ ៖ គោលដៅ និងការកំណត់គោលដៅ | | |
| **ជំពូកទី២ ៖ ការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលា** | | |
| ៤. ការគ្រប់គ្រងពេលវេលា | ៤៥នាទី | - សិស្សយល់ពីតម្លៃពេលវេលា និងរៀនពីរបៀបគ្រប់គ្រងពេលវេលាឱ្យមានប្រសិទ្ធភាព។ |
| ៥. តើខ្ញុំសម្រេចចិត្តដោយរបៀបណា? | ៦០នាទី | - សិស្សបង្កើតការយល់ដឹងពីការធ្វើសេចក្តីសម្រេចចិត្តដ៏ល្អ។ |
| ៦. ការគ្រប់គ្រងប្រាក់ | ៤៥នាទី | - សិស្សយល់ដឹងពីគោលគំនិតនៃការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួនដែលជាធនធានដ៏សំខាន់មួយ។ |
| ៧. តើសុីណារតន៍ត្រូវធ្វើអ្វី? | ៦០នាទី | - សិស្សយល់ពីរបៀបដែលបំណិន(ជំនាញ)សំខាន់ៗមួយចំនួនជួយយើងឱ្យសម្រេចបាននូវបំណងប្រាថ្នារបស់យើង។ |
| **ជំពូកទី៣ ៖ ភាពជាអ្នកដឹកនាំ** | | |
| ៨. នរណាជាអ្នកដឹកនាំ? | ៤៥នាទី | - សិស្សរៀនសូត្រធ្វើជាអ្នកដឹកនាំក្នុងជីវិតផ្ទាល់របស់ខ្លួន។ |
| **ជំពូកទី៤ ៖ សិទ្ធិមនុស្ស** | | |
| ៩. ការណែនាំពីសិទ្ធិមនុស្ស | ៦០នាទី | - សិស្សយល់ដឹងពីទស្សនៈទាននៃសិទ្ធិមនុស្ស។ |
| ១០. ការយល់ដឹងពីសិទ្ធិមនុស្ស | ៦០នាទី | - សិស្សយល់ដឹងពីសិទ្ធិមនុស្សផ្សេងៗដោយប្រើប្រាស់ភាសាសាមញ្ញៗ។ |

## ៦. ការវាយតម្លៃសិស្ស

នៅខាងចុងនៃសៀវភៅនេះ មានដាក់បញ្ចូលនូវទម្រង់នៃការវាយតម្លៃសិស្ស*(ឧបសម្ព័ន្ធទី២)* ដែលទម្រង់នេះត្រូវបានរៀបចំឡើងសម្រាប់វាស់វែងចំណេះដឹងរបស់សិស្ស។ ការវាយតម្លៃនេះត្រូវធ្វើជាពីរដំណាក់កាល ពោលគឺ ការវាយតម្លៃមុនពេលបង្រៀន *(Pre-test)* និងក្រោយពេល បង្រៀន *(Post-test)* ដើម្បីពិនិត្យមើលលើការរីកចម្រើនផ្នែកចំណេះដឹងរបស់សិស្ស។

## ៧. ឯកសារយោង

នៅក្នុងមេរៀននីមួយៗមានបញ្ចូលនូវឯកសារយោង ឬបន្ថែមសម្រាប់ការអានរបស់សិស្ស និងការពន្យល់បន្ថែមរបស់គ្រូ។ ឯកសារទាំងនេះមានចំនួន២ប្រភេទគឺ «ឧបសម្ព័ន្ធ និងក្របខណ្ឌចំណេះដឹង»។ វាមានសារៈសំខាន់ណាស់ដែលគ្រូបង្រៀនត្រូវអានចំណុចទាំងនេះជាមុន ព្រោះវាផ្តល់នូវការពន្យល់ទូទៅនូវចំណេះដឹងមួយចំនួន។

# ម៉ូឌុលទី៤ ៖ ខ្ញុំ និងបំណងប្រាថ្នារបស់ខ្ញុំ

## ទិដ្ឋភាពទូទៅ

ម៉ូឌុលនេះមានគោលបំណងកសាងចំណេះដឹង និងការយល់ដឹងពីអ្វីដែលជាបំណងប្រាថ្នា និងអ្វីដែលត្រូវសម្រេចឱ្យបាន ព្រមទាំងធ្វើឱ្យសិស្សមានលទ្ធភាពកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់ខ្លួន។ វាមានសារៈសំខាន់ណាស់ក្នុងការរៀនតាំងពីវ័យក្មេងពីរបៀបរៀបចំផែនការជាក់លាក់ដើម្បីសម្រេចគោលដៅរបស់ខ្លួន។ តថភាពជាក់ស្តែងសម្រាប់យុវវ័យភាគច្រើនគឺថា ពួកគេធំឡើងក្នុងបរិយាកាសមួយដែលពោរពេញទៅដោយព័ត៌មានចម្រុះពីគ្រប់ទិសទី ដូចជានៅក្នុងក្រុមគ្រួសារ សាលារៀន សហគមន៍ និងពិភពលោកដ៏ធំទូលាយ តាមរយៈការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយដែលព្យាយាមបង្ហាញពីជីវិតដ៏ល្អប្រសើរមួយ ឬអ្វីមួយផ្សេងទៀតដើម្បីឱ្យមនុស្សប្រាថ្នាចង់បាន និងត្រូវសម្រេចឱ្យបាន។ នៅក្នុងដំណើរការនេះ មានយុវវ័យជាច្រើនមិនអាចកំណត់ និងបង្កើតគំនិត និងអារម្មណ៍ផ្ទាល់ខ្លួនបានទេ ចំពោះអ្វីដែលពួកគេគិតថាគេចង់បាន និងអ្វីដែលទំនងជាល្អត្រឹមត្រូវសម្រាប់ពួកគេ។ បញ្ហានេះកាន់តែស្មុគស្មាញដោយសារតែមនុស្សមានការវិវឌ្ឍន៍ ហើយស្ថានភាពជីវិតក៏មានការផ្លាស់ប្តូរដែរ។

ជាថ្មីម្តងទៀត យេនឌ័រដើរតួនាទីសំខាន់មួយក្នុងការធ្វើជាគំរូ និងការគ្រប់គ្រងដែលជារឿយៗបញ្ចប់នូវបំណងប្រាថ្នារបស់បុគ្គលមួយចំនួនដែលមានអារម្មណ៍ថាខ្លួនត្រូវគេបង្ខំឱ្យជ្រើសរើសផ្លូវជីវិតមួយដែលពួកគាត់បានកំណត់រួចហើយ។ ជាទូទៅ ក្នុងពេលដែលចំណុចនេះគឺជាការពិតសម្រាប់បុរស និងក្មេងប្រុស វាក៏ជាការពិតដែលកើតឡើងញឹកញាប់បំផុតចំពោះក្មេងស្រី និងស្ត្រីជាច្រើនដែរ។

ខណៈដែលក្មេងស្រីមានការព្រួយបារម្ភចំពោះការឆ្លើយតបទៅនឹងតម្រូវការចំពោះមុខសម្រាប់ជីវិតប្រចាំថ្ងៃ ម៉ូឌុលនេះធ្វើឱ្យសិស្សយល់ពីរបៀបបង្កើតបំណងប្រាថ្នា របៀបកំណត់គោលដៅសម្រាប់អនាគតរបស់ខ្លួនដែលមានន័យ និងគុណតម្លៃសម្រាប់ពួកគាត់ផ្ទាល់ ព្រមទាំងមានលក្ខណៈពិតប្រាកដ ហើយអាចសម្រេចបាន និងវិធីអនុវត្តឆ្ពោះទៅរកការសម្រេចបានគោលដៅទាំងនេះ។ មានការផ្តោតសំខាន់ដែរទៅលើការរៀនពីបំណិនដែលចាំបាច់ ដូចជាការគ្រប់គ្រងពេលវេលា និងប្រាក់កាស ការកំណត់អាទិភាព ការសម្រេចចិត្ត ការដោះស្រាយបញ្ហា និងភាពជាអ្នកដឹកនាំដែលជួយឱ្យពួកគាត់ម្នាក់ៗសម្រេចបាននូវបំណងប្រាថ្នាមួយចំនួនក្នុងចំណោមបំណងប្រាថ្នានានារបស់គាត់។

🕘 **រយៈពេលរួម ៖ ៩ ម៉ោង ១៥ នាទី**

❐ **ចំនួនលំនាំបង្រៀនសរុប ៖ ១០ មេរៀន**

## 🏆 វត្ថុបំណង ៖

- ☺ ដើម្បីឱ្យសិស្សមានលទ្ធភាពគិត និងកំណត់ពីចំណាប់អារម្មណ៍ និងបំណងប្រាថ្នាផ្ទាល់របស់គេ។
- ☺ ដើម្បីយល់ពីរបៀបអនុវត្តឆ្ពោះទៅរកការសម្រេចបំណងប្រាថ្នារបស់ខ្លួន។
- ☺ ដើម្បីកសាងការយល់ដឹងពីវិធីសាស្រ្តជាក់លាក់ក្នុងការរៀបចំផែនការដើម្បីសម្រេចបាននូវបំណងប្រាថ្នារបស់ខ្លួន។
- ☺ យល់ដឹងស៊ីជម្រៅពីសិទ្ធិមនុស្ស និងសារៈសំខាន់នៃសិទ្ធិទាំងនេះនៅក្នុងជីវិត និងបរិបទជាក់ស្តែងរបស់ខ្លួនផ្ទាល់។

# ជំពូកទី១ ៖ បំណងប្រាថ្នា

## ទិដ្ឋភាពទូទៅ

បុគ្គលនៅក្នុងក្រុមអាយុនេះអាចមានគំនិតខ្លះក្នុងការចង់ធ្វើការងារជាក់លាក់មួយចំនួននាពេលអនាគត ប៉ុន្តែ ជាញឹកញាប់ ពួកគេខ្វះភាពច្បាស់លាស់ចំពោះសមត្ថភាពរបស់ខ្លួនដើម្បីប្រែក្លាយបំណងប្រាថ្នារបស់ខ្លួនឱ្យមានប្រសិទ្ធភាពទៅជាគោលដៅដែលអាចសម្រេចបាន។ ពេលខ្លះ ពួកគេអាចខ្វះនូវគំនិតជាក់លាក់មួយសម្រាប់អនាគតរបស់ខ្លួន។ មេរៀននេះមានគោលបំណងកសាងការយល់ដឹងពីក្តីសុបិន និងបំណងប្រាថ្នារបស់សិស្ស ព្រមទាំងធ្វើឱ្យសិស្សមានលទ្ធភាពចាត់វិធានការជាក់លាក់ឆ្ពោះទៅរកការកំណត់គោលដៅទៅតាមទិសដៅនោះ។ មិនមានគោលដៅ ឬបំណងប្រាថ្នាតែមួយដែលអាចអនុវត្តជាសកលសម្រាប់មនុស្សគ្រប់រូបបានទេ ហើយផ្នែកដ៏ធំមួយនៃការរៀនសូត្រគឺការធ្វើឱ្យសិស្សមានលទ្ធភាពរៀបចំមាគ៌ាមួយដោយឆ្លងកាត់នូវព័ត៌មាន(សារ)ដែលមានលក្ខណៈភាន់ច្រឡំ ដែលទទួលបានពីគ្រប់ទិសទី និងផ្តោតសំខាន់លើខ្លួនឯង។ ចំណុចនេះអាចបណ្តាលឱ្យមានការបារម្ភដែលមិនអាចកំណត់បាន និងរាំងស្ទះដល់ទំនុកចិត្ត ព្រមទាំងគំនិត និងអារម្មណ៍វិជ្ជមាន។ គេអាចមើលឃើញចំណុចនេះថាជាផ្នែកមួយនៃដំណើរអភិវឌ្ឍខ្លួនឯង ដែលបុគ្គលម្នាក់អាចមានលក្ខណៈដូចគ្នាទៅនឹងបុគ្គលម្នាក់ផ្សេងទៀត ប៉ុន្តែនៅមិនទាន់ក្លាយជាបុគ្គលដែលមានលក្ខណៈពិសេសដាច់ដោយឡែកចំពោះគោលដៅ និងក្តីសុបិនផ្ទាល់របស់ខ្លួននៅឡើយ។ យើងម្នាក់ៗមានសិទ្ធិធ្វើខ្លួនបែបនេះបាន ពោលគឺមានលក្ខណៈស្រដៀងគ្នាចំពោះមធ្យោបាយមួយចំនួនរបស់បុគ្គលផ្សេងទៀតដែលយើងមានជីវិតរួមគ្នាជាមួយពួកគេ ប៉ុន្តែក៏មានលក្ខណៈខុសគ្នាដែរ។

🕘 រយៈពេលរួម ៖ ៣ ម៉ោង

❐ ចំនួនលំនាំបង្រៀនសរុប ៖ ៣ មេរៀន

## 🏆 វត្ថុបំណង ៖

- ☺ ដើម្បីឱ្យសិស្សមានលទ្ធភាពគិត និងកំណត់ពីបំណងប្រាថ្នារបស់ខ្លួនផ្ទាល់។
- ☺ ដើម្បីឱ្យសិស្សមានលទ្ធភាពគិត និងអនុវត្តតាមរយៈឱកាស និងការប្រឈមនៅលើវិថីជីវិតរបស់គេដើម្បីសម្រេចបាននូវបំណងប្រាថ្នាផ្សេងៗរបស់ខ្លួន។
- ☺ ដើម្បីឱ្យសិស្សយល់ថាអ្វីទៅជាគោលដៅ និងរបៀបកំណត់គោលដៅទាំងនោះ។

# មេរៀនទី១ ៖ រយៈពេលកំណត់នៃបំណងប្រាថ្នារបស់ខ្ញុំ[១]

🕒 **រយៈពេល** ៖ ១ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីឱ្យសិស្សមានលទ្ធភាពកំណត់ក្ដីសុបិន និងបំណងប្រាថ្នាពេលអនាគតរបស់ខ្លួន។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

- សម្រាប់គ្រូ៖ ក្ដារខៀន និងដីស ឬក្រដាសផ្ទាំងធំ និងហ្វឺត ខ្សែវែង ឬខ្សែពួរស្ដើង ប័ណ្ណកត់ត្រា (សិស្សម្នាក់៦សន្លឹក) ប៊ិក ឬខ្មៅដៃ (ម្នាក់១ដើម) និងស្កុត។ លេខអាចកាត់ជារូប ឬ សរសេរ ប័ណ្ណមួយលេខមួយ៖ -១០, -៥, 0, +៥, +១៥, +២០។ ឯកសារថតចម្លង ឧបសម្ព័ន្ធទី១ ៖ រូបរបស់សុផា នៅលើក្រដាសផ្ទាំងធំ (ដែលសិស្សគ្រប់គ្នាអាចមើលឃើញ)។
- សម្រាប់សិស្ស៖ ប័ណ្ណកត់ត្រាម្នាក់៦សន្លឹក ប៊ិក ឬខ្មៅដៃ (ម្នាក់១ដើម) និងស្កុត។

**ការរៀបចំទុកជាមុន** ៖

- អានទិដ្ឋភាពទូទៅនៃម៉ូឌុលទី៤ ៖ ខ្ញុំ និងបំណងប្រាថ្នារបស់ខ្ញុំ និងជំពូកទី១ ៖ បំណងប្រាថ្នា។
- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- កាត់ក្រដាស A4 ជា៤សន្លឹក សម្រាប់សិស្សប្រើជាប័ណ្ណកត់ត្រា។
- ចម្លងករណីសិក្សារបស់សុផា ឧបសម្ព័ន្ធទី១ ដាក់ក្នុងក្រដាសផ្ទាំងធំ។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ស្វាគមន៍សិស្ស បន្ទាប់មកពិនិត្យមើល «ទឹកចិត្ត» របស់គេដោយឱ្យពួកគេប្រើប្រាស់ដៃរបស់ខ្លួន ដើម្បីបង្ហាញពីកម្រិតនៃថាមពលរបស់ពួកគេ។
- ឱ្យសិស្សចែករំលែកការយល់ឃើញរបស់គេពីអត្ថន័យរបស់ពាក្យ«ក្ដីសុបិន» និង«បំណងប្រាថ្នា»។ សិស្សអាចនិយាយពីពាក្យផ្សេងៗដែលគេយល់ថាពាក់ព័ន្ធនិងគំនិតនេះ ចំណែកលោកគ្រូ អ្នកគ្រូត្រូវកត់ត្រានូវពាក្យគន្លឹះដែលសិស្សបានឆ្លើយ នៅលើក្ដារខៀន។
- ពន្លាតខ្សែ ឬអំបោះនៅលើឥដ្ឋ ឬចងនឹងជញ្ជាំង។ ក្រដាសដែលមានសរសេរលេខត្រូវដាក់តាម

---

[១] វិទ្យាស្ថានសុខភាពបន្តពូជ (IRH). (២០១៤). *ធំធាត់ដោយឆ្លាតវៃ៖ ការណែនាំសម្រាប់អ្នកសម្របសម្រួលដើម្បី ដំណើរការវគ្គបណ្ដុះបណ្ដាលជាក្រុមស្ដីពីការផ្លាស់ប្ដូរពេលធំធាត់ និងពេញវ័យ។* ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី៖ វិទ្យាស្ថានសុខភាពបន្តពូជនៃសកលវិទ្យាល័យចចថោន។

បណ្តោយខ្សែនោះទុកធ្វើជាតំណាងចំនួននៃឆ្នាំ។ លេខដែលគួរមានគឺ ៖ -១០, -៥, ០, +១០, +១៥, +២០។ ពន្យល់សិស្សថា លេខ ០ តំណាងឱ្យពេលបច្ចុប្បន្ន ពោលគឺចំណុចចាប់ផ្ដើមនៃសកម្មភាពនេះ។ លេខដែលមានសញ្ញាដក(អវិជ្ជមាន)តំណាងឱ្យចំនួនឆ្នាំដែលកន្លងផុតទៅ ពោលគឺ ៥ឆ្នាំមុន ឬ១០ឆ្នាំមុន ហើយលេខដែលមានសញ្ញាបូក(វិជ្ជមាន)គឺតំណាងឱ្យចំនួនឆ្នាំនាពេលអនាគត ពោលគឺ ១០ ១៥ ឬ២០ឆ្នាំទៅមុខទៀតរាប់ចាប់ពីថ្ងៃនេះទៅ។

- ☞ សិស្សម្នាក់ៗត្រូវទទួលបានប័ណ្ណកត់ត្រាចំនួន៦សន្លឹក។ លោកគ្រូ អ្នកគ្រូត្រូវណែនាំសិស្សឱ្យសរសេរឆ្នាំដែលកំណត់ពីដំណាក់កាលសំខាន់ៗខាងលើនៅលើប័ណ្ណ។ ដូចនេះ សិស្សម្នាក់ៗត្រូវមានប័ណ្ណចំនួន៦សន្លឹក ដោយប័ណ្ណនីមួយៗមានសរសេរលេខមួយក្នុងចំណោមលេខទាំងនេះ -១០, -៥, ០, +៥, +១៥ និង +២០។
- ☞ បន្ទាប់មកសិស្សម្នាក់ៗត្រូវសរសេរនូវព្រឹត្តិការណ៍សំខាន់ៗផ្សេងៗក្នុងជីវិតរបស់គេដោយសរសេរព្រឹត្តិការណ៍មួយនៅលើប័ណ្ណមួយ។ សម្រាប់ឆ្នាំដែលកន្លងហួស សិស្សត្រូវសរសេរពីព្រឹត្តិការណ៍មួយដែលបានកើតឡើងរួចហើយ។ សម្រាប់លេខ០ សិស្សត្រូវសរសេរព្រឹត្តិការណ៍មួយដែលសំខាន់សម្រាប់ជីវិតរបស់ពួកគេនៅពេលបច្ចុប្បន្ន។ សម្រាប់ឆ្នាំទៅមុខទៀត សិស្សត្រូវសរសេរនូវព្រឹត្តិការណ៍មួយដែលពួកគេចង់ឱ្យវាកើតឡើង។
- ☞ បន្ទាប់ពីបានសរសេរនៅលើប័ណ្ណរួចហើយ សិស្សទាំងអស់ត្រូវបិទប័ណ្ណរបស់ខ្លួនទៅតាមលំដាប់លេខនីមួយៗនៅលើខ្សែដែលតំណាងឱ្យរយៈពេលកំណត់ដើម្បីឱ្យចំនួននៅចំណុចណាមួយរបស់ខ្សែពេលវេលាមានប័ណ្ណរបស់សិស្សទាំងអស់ដែលមានលេខដូចគ្នា (ឧ. លេខ -១០ នៅលើខ្សែពេលវេលាមានប័ណ្ណរបស់សិស្សទាំងអស់ដែលមានលេខសម្គាល់ -១០)។
- ☞ ក្រោយពីបញ្ចប់សកម្មភាពខាងលើ សិស្សត្រូវចែករំលែក និងពិភាក្សាពីបំណងប្រាថ្នានាពេលអនាគតរបស់គេ ដូចមានកត់ត្រានៅលើប័ណ្ណរបស់ខ្លួន (+៥ +១៥ និង +២០) ជាមួយក្រុមធំ។
- ☞ លោកគ្រូ អ្នកគ្រូត្រូវបង្ហាញករណីសិក្សារបស់ សុផា នៅលើក្រដាសផ្ទាំងធំដើម្បីឱ្យក្រុមទាំងមូលមើលឃើញ (សំដៅលើឧបសម្ព័ន្ធទី១ ៖ ករណីសិក្សារបស់ សុផា)។
- ☞ នៅចុងបញ្ចប់នៃសកម្មភាពនេះ សិស្សមានពេល៥នាទីដើម្បីដើរមើលខ្សែពេលវេលា និងអាននូវការឆ្លើយតបរបស់សិស្សផ្សេងទៀតនៅលើប័ណ្ណ។

## ៣. ការពង្រឹងចំណេះដឹង

**🗣 ចំណុចសម្រាប់ការពិភាក្សា ៖**

◇ តើពាក្យថា «បំណងប្រាថ្នា» មានន័យដូចម្ដេច?

- ☝ បំណងប្រាថ្នាគឺជាអ្វីៗដែលមនុស្សម្នាក់សុបិន(ស្រមៃឃើញ)ទាក់ទងនឹងអ្វីដែលគេចង់បាននាពេលអនាគត។ មនុស្សម្នាក់ៗមានបុគ្គលគំរូនៅក្នុងជីវិតរបស់ខ្លួនដែលមាន ឥទ្ធិពលលើក្ដីសុបិនទាំងនេះដូចជា ក្រុមគ្រួសារ និងមិត្តភក្ដិ។ ទោះជាយ៉ាងនេះក្ដី វាជាជម្រើស និងឆន្ទៈរបស់បុគ្គលម្នាក់ៗក្នុងការសម្រេចឱ្យបាននូវអ្វីដែលគេចង់ធ្វើនៅក្នុងជីវិត ដូចជាការងារជាក់

លាក់មួយចំនួន ឬចំណង់ចំណូលចិត្ត ឬអ្វីផ្សេងទៀត ឬកិច្ចការអ្វីមួយដែលគេចង់ធ្វើ(ក្លាយខ្លួនជា)នៅពេលធំពេញវ័យ។ ចំណុចនេះហើយជាអត្ថន័យនៅពេលដែលយើងសំដៅដល់ពាក្យថា បំណងប្រាថ្នារបស់បុគ្គលម្នាក់ៗ។ ឧទាហរណ៍ មនុស្សម្នាក់អាចមានក្តីប្រាថ្នាចង់ក្លាយជាគ្រូបង្រៀន ជាអ្នករបាំ ឬក្លាយជាបុគ្គលម្នាក់ដែលគោរពវិន័យតឹងរ៉ឹងលើពេលវេលា ឬមានទំនុកចិត្តក្នុងការនិយាយជាសាធារណៈ។ ចំណុចនេះក៏ដូចគ្នាទៅនឹងអ្វីដែលយើងបានរៀនក្នុងមេរៀនស្តីពីតួនាទី និងការរំពឹងទុកផ្អែកយេនឌ័រដែលជាញឹកញាប់គេបង្រៀនក្មេងស្រីថាការធ្វើជាកូនក្រមុំសម្រាប់អាពាហ៍ពិពាហ៍ និងភាពជាម្តាយគឺជាតួនាទីចម្បងរបស់ពួកគេ។ ចំណុចនេះបានដាក់កម្រិតទៅលើមធ្យោបាយជាច្រើនដែលពួកគេអាចស្រមើស្រមៃពីអនាគតរបស់ខ្លួន និងអ្វីដែលពួកគេចង់សម្រេចឱ្យបាន។ វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ថា ស្ត្រីនិងក្មេងស្រីមានលទ្ធភាពកាន់តែច្រើនចំពោះការសិក្សាស្វែងយល់ពីជីវិត និង ជម្នះរាល់ការរំពឹងទុករបស់សង្គម ប្រសិនបើអ្វីដែលពួកគេប្រាថ្នាចង់បានសម្រាប់ខ្លួនឯងខុសពីបទដ្ឋាននោះ។ តាមរយៈការរៀនសូត្របៀបនេះ ការចចារ និងការគាំទ្ររបស់អ្នកដែលបានរួមចំណែកក្នុងការសម្រេចបំណងប្រាថ្នារបស់គេធ្វើឱ្យក្មេងស្រីនិងស្ត្រីជាច្រើនមានលទ្ធភាពធ្វើការសម្រេចចិត្ត និងមានជម្រើសផ្ទាល់ខ្លួន។

- តើអ្វីខ្លះដែលអ្នកគិតថាជាកំណត់ពីបំណងប្រាថ្នារបស់យើង?
  - ជាញឹកញាប់ ប្រភេទនៃជម្រើសដែលយើងមើលឃើញនៅជុំវិញខ្លួនយើងគឺជាអ្នកកំណត់ពីបំណងប្រាថ្នារបស់យើង។ យើងទំនងជាទទួលឥទ្ធិពលពីការរំពឹងទុកដែលយើងត្រូវបំពេញចំពោះការសម្រេចចិត្តពីអ្វីដែលយើងប្រាថ្នាចង់បាន។ ចំណុចនេះនាំឱ្យឈានទៅរកការយល់ឃើញដែលមានលក្ខណៈស្រពេចស្រពិលចំពោះជម្រើស និងបំណងប្រាថ្នារបស់បុគ្គលម្នាក់ៗ។ យើងគួរតែបណ្តោយឱ្យក្តីស្រមៃហោះហើរ(កើតឡើង) និងមិនត្រូវកំណត់ព្រំដែននៃក្តីស្រមៃរបស់យើងទៅតាមអ្វីដែលអ្នកដទៃគិតថា យើងអាចធ្វើវាបាន ឬមិនបាននោះទេ។ ឧទាហរណ៍ ៖ គេមិនត្រូវរារាំងដល់ក្តីសុបិនរបស់ក្មេងស្រីដោយសារគំនិតចាស់គំរិលទាក់ទងនឹងការងារណាមួយដែលបុរស ឬស្ត្រីអាចធ្វើបាន។ អ្វីៗកំពុងមានការផ្លាស់ប្តូរ ហើយស្ត្រីក្នុងពេលបច្ចុប្បន្នកំពុងធ្វើការងារ ឬអាជីពដែលម្តាយរបស់ពួកគេផ្ទាល់មិនដែលសុបិនឃើញ ឬគិតដល់។ បច្ចុប្បន្នស្ត្រីអាចក្លាយជាវិស្វករ អាកាសយានិក វេជ្ជបណ្ឌិត អត្តពលលិក អ្នកវិទ្យាសាស្ត្រ សាស្ត្រាចារ្យ អវកាសយានិក ប្រធានាធិបតី អ្នកកាសែត ឬអាជីពផ្សេងៗទៀត។
- តើការមានបំណងប្រាថ្នាច្រើនផ្សេងៗគ្នាជារឿងមិនល្អឬ? (យោងតាមករណីសិក្សារបស់សុជា)
  - បំណងប្រាថ្នាគឺជារឿងអស្ចារ្យ។ វាលើកទឹកចិត្តដល់បុគ្គលម្នាក់ៗ ហើយវាធ្វើឱ្យបុគ្គលនោះមើលឃើញពីអនាគត និងរៀបចំផែនការសម្រាប់អនាគតនោះ។ បំណងប្រាថ្នារបស់បុគ្គលម្នាក់ក៏អាចផ្លាស់ប្តូរដែរនៅពេលដែលគេចាស់ទៅ ហើយវាប្រាកដណាស់មិនមែនជាបញ្ហាទេ។

- តើវាជារឿងមិនល្អឬ ប្រសិនបើនរណាម្នាក់មិនមានភាពប្រាកដប្រជាចំពោះអ្វីដែលជាបំណងប្រាថ្នារបស់ខ្លួនក្នុងពេលបច្ចុប្បន្ន?
  - វាពិតជាគ្មានបញ្ហានោះទេ។ វាមិនមែនមានន័យថា នរណាម្នាក់គ្មានក្ដីសុបិននោះទេ។ វាគ្រាន់តែមានន័យថា ពួកគេមិនទាន់គិតឃើញពីអ្វីដែលពួកគេចង់ធ្វើប៉ុណ្ណោះ។ មនុស្សម្នាក់ៗអាចចាប់ផ្ដើមកំណត់បំណងប្រាថ្នារបស់គេនៅថ្ងៃនេះ ឬថ្ងៃណាមួយ។ មនុស្សម្នាក់ៗគួរចំណាយពេលវេលាដែលមានមួយចំនួនគិតពីក្ដីសុបិនរបស់ខ្លួនសម្រាប់អនាគត។
- តើមនុស្សម្នាក់ចាប់ផ្ដើមគិតពីបំណងប្រាថ្នារបស់ខ្លួនដោយរបៀបណា?
  - ក្ដីសុបិនរបស់មនុស្សភាគច្រើនទទួលឥទ្ធិពលយ៉ាងខ្លាំងពីមនុស្សជុំវិញខ្លួនរបស់គេ ឬសូម្បីពីទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយដែលមានក្នុងពេលបច្ចុប្បន្ននេះ។ ជាដំបូង ត្រូវក្រឡេកមើលជុំវិញខ្លួនយើងសិន។ បុគ្គលម្នាក់អាចចាប់ផ្ដើមដោយការគិតពីមនុស្សដែលពួកគេស្គាល់ ឬធ្លាប់ឮ។ គិតពីបុគ្គលណាម្នាក់ដែលគួរឱ្យសរសើរ។ គិតពីបុគ្គលណាម្នាក់ដែលគេគោរពកោតសរសើរ។ បុគ្គលនោះអាចជាគ្រូបង្រៀន ជាវេជ្ជបណ្ឌិត ជាកីឡាករបាល់ទាត់ ឬជាអ្នកចម្រៀង។ បុគ្គលនោះអាចជាសមាជិកគ្រួសារ ដូចជាឪពុកម្ដាយជាដើម។ តើបុគ្គលទាំងនេះមានចំណុចអ្វីខ្លះដែលគេចាត់ទុកថាគួរឱ្យសរសើរ និងមានតម្លៃ?
  - អ្វីដែលសំខាន់បំផុតគឺមនុស្សម្នាក់ៗមិនគួរបណ្ដោយឱ្យបំណងប្រាថ្នារបស់ខ្លួនត្រូវបានដាក់កម្រិតដោយសារអ្វីដែលគេមើលឃើញនៅជុំវិញខ្លួនគេទេ។ សូមមើលឱ្យបានឆ្ងាយទៅក្នុងពិភពលោកដ៏ធំធេងនេះ។ តើមានបុគ្គលណាដែលគេចុះផ្សាយលើទំព័រកាសែត ឬសៀវភៅដោយសារតែពួកគេបានធ្វើរឿងអ្វីមួយដ៏អស្ចារ្យដែរឬទេ? បុគ្គលនោះប្រហែលជាអ្នកវិទ្យាសាស្ត្រដែលកំពុងសិក្សាពីវិធីដែលសត្វដំរីទំនាក់ទំនងគ្នាទៅវិញទៅមក។ ឬបុគ្គលនោះអាចជាគិលានុបដ្ឋាកដែលមើលថែទាំជនភៀសខ្លួននៅកណ្ដាលតំបន់សង្គ្រាម។ មានមនុស្សជាច្រើនដែលកំពុងធ្វើរឿងដែលគួរឱ្យចាប់អារម្មណ៍ និងមានប្រយោជន៍នៅក្នុងជីវិតរបស់គេ។ បុគ្គលនោះប្រហែលជាអ្នកដែលសំឡេងរបស់គាត់ត្រូវបានគេចាក់ផ្សាយ តាមវិទ្យុជារៀងរាល់ថ្ងៃ ឬជាបងស្រីរបស់មិត្តភក្ដិម្នាក់ដែលស្លៀកពាក់ស្អាតបាតទៅធ្វើការនៅការិយាល័យជារៀងរាល់ថ្ងៃ។ បុគ្គលទាំងអស់នេះអាចដើរតួជាគំរូបាន។ មនុស្សម្នាក់ៗអាចប៉ងប្រាថ្នាចង់រកប្រាក់ចំណូលតាមរយៈការបង្កើតមុខរបរផ្ទាល់ខ្លួន។ ចំណុចទាំងអស់នេះអាចធ្វើឱ្យមនុស្សម្នាក់ចាប់ផ្ដើមបង្កើតក្ដីសុបិនសម្រាប់អនាគតបាន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- សិស្សខ្លះអាចមានការលំបាកក្នុងការគិតអំពីពេលវេលាដែលកន្លងផុតទៅ ឬអនាគតរយៈពេល ១០ ឬ១៥ឆ្នាំទៅមុខទៀត។ សិស្សទាំងនោះទំនងជាត្រូវការឧទាហរណ៍ខ្លះដើម្បីចាប់ផ្ដើម ដូចជា ពេលចូលរៀនដំបូង ចូលរួមការសម្ដែងនៅសាលារៀន ចុះឈ្មោះចូលរៀនគណិតវិទ្យា នឹងបញ្ចប់ការសិក្សា នឹងមានការងារធ្វើ នឹងក្លាយជាអ្នកសិក្សាស្រាវជ្រាវ ។ល។
- បន្ទាប់ពីធ្វើសកម្មភាពរួច ប្រមូលខ្សែ និងប័ណ្ណដែលសិស្សបានសរសេរ និងរក្សាវាទុកដោយប្រុងប្រយ័ត្នសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពបន្ទាប់ទៀត។

**សារសំខាន់ៗ ៖**

- បំណងប្រាថ្នារបស់យើងគឺជាអ្វីដែលយើងចង់ធ្វើ ឬក្លាយជាអ្វីមួយនៅក្នុងជីវិតរបស់យើង។ វា មានសារៈសំខាន់ណាស់សម្រាប់ការរីកចម្រើនរបស់យើង និងសម្រាប់ការសម្រេចគោលដៅក្នុងជីវិតរបស់យើង។
- មនុស្សម្នាក់ៗមិនគួរកម្រិតដែនកំណត់នៃក្ដីសុបិន និងបំណងប្រាថ្នារបស់ខ្លួនដោយឈរលើមូលដ្ឋាននៃតួនាទី និងការរំពឹងទុកផ្នែកយេនឌ័រទេ។
- នៅពេលធ្វើការកំណត់អំពីក្ដីសុបិន និងបំណងប្រាថ្នា សូមទុកឱ្យការស្រមើស្រមៃរបស់យើង កើតឡើងដោយរលូនទៅចុះ។

ឧបសម្ព័ន្ធទី ១ ៖ ករណីសិក្សារបស់សុផា

មនុស្សមួយចំនួនមានក្តីសុបិនជាច្រើន ហើយក្តីសុបិនទាំងនោះមានការផ្លាស់ប្តូរជានិច្ច។ ចូរយករឿងរបស់ សុផា ដែលរស់នៅក្រុងបាត់ដំបង ធ្វើជាឧទាហរណ៍ ៖

- នៅអាយុ ៦ ឆ្នាំ នាងបានទៅសួរសុខទុក្ខពូរបស់នាងដែលជាប៉ូលិស។ ពេលនោះ នាងចង់ក្លាយជាមន្ត្រីប៉ូលិស។
- នៅអាយុ ៨ ឆ្នាំ នាងអានរឿងពាក់ព័ន្ធនឹងកប៉ាល់ទីតានិក ហើយនាងក៏ចង់ក្លាយជាប្រធាននាវិក។
- នៅអាយុ ១០ ឆ្នាំ នាងចង់ក្លាយជាអ្នកបើកយន្តហោះ។
- នៅអាយុ ១៣ ឆ្នាំ មានគ្រូបង្រៀនថ្មីម្នាក់ចូលមកសាលា ហើយគាត់ទទួលបានភាពល្បីល្បាញជាខ្លាំង។ ពេលនោះ សុផាចង់ក្លាយជាគ្រូបង្រៀន។
- នៅអាយុ ១៩ ឆ្នាំ នាងចង់ក្លាយជាវិស្វករ។

# មេរៀនទី២ ៖ ល្បែងស្តីពីបំណងប្រាថ្នា[២]

រយៈពេល ៖ ១ ម៉ោង

វត្ថុបំណង ៖

- ដើម្បីឱ្យសិស្សអាចកំណត់ពីឱកាស និងឧបសគ្គដែលគេអាចជួបប្រទះក្នុងការបំពេញតាមបំណងប្រាថ្នារបស់ពួកគេ។
- ដើម្បីលើកទឹកចិត្តសិស្សឱ្យស្វែងរកវិធីនានាដែលពួកគេអាចគាំទ្រគ្នាទៅវិញទៅមកនៅក្នុងការធ្វើដំណើរនេះ។

## ១. ការរៀបចំ

**សម្ភារៈដែលត្រូវការ ៖**

- សម្រាប់គ្រូ៖ ឯកសារចែកជូនទី ១ - ល្បែងជិះកង់ (មួយឈុតសម្រាប់សិស្សម្នាក់) និងប៊ិក ឬខ្មៅដៃ (មួយដើមសម្រាប់សិស្សម្នាក់)។
- សម្រាប់សិស្ស៖ សន្លឹកកិច្ចការក្នុងថ្នាក់របស់សិស្សទំព័រទី៦៦។

**ការរៀបចំទុកជាមុន ៖**

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ថតចម្លងឯកសារចែកជូនទី១ ល្បែងជិះកង់ សម្រាប់ចែកសិស្សម្នាក់១សន្លឹក។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

**សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ដោយបន្តអនុវត្តពីសកម្មភាពមុន សូមដាក់(ចង)ខ្សែដែលមានបិទ ឬព្យួរលេខសម្គាល់ឆ្នាំ និងប័ណ្ណចម្លើយរបស់សិស្សឡើងវិញនៅលើកម្រាល ឬជញ្ជាំង(ដូចដែលបានធ្វើពីមុន)។ ឱ្យសិស្សដើរមើល៥នាទី រកមើលប័ណ្ណរបស់ពួកគេ និងអានប័ណ្ណទាំងនោះស្ងាត់ៗ ហើយធ្វើការឆ្លុះបញ្ចាំងវា។ បន្ទាប់មកពួកគេត្រូវអង្គុយជារង្វង់។
- ឱ្យសិស្សបិទភ្នែករបស់ខ្លួនចំនួន២នាទី និងគិតអំពីបំណងប្រាថ្នាពេលអនាគតដែលពួកគេបានសរសេរ។ សិស្សត្រូវតែព្យាយាមកំណត់កត្តា និងកាលៈទេសៈនានាដែលអាចជួយ ឬរាំងពួកគេ

---

[២] វិទ្យាស្ថានសុខភាពបន្តពូជ (IRH). (២០១៥). *ធំធាត់ដោយឆ្លាតវៃ៖ ការណែនាំសម្រាប់អ្នកសម្របសម្រួលដើម្បី ដំណើរការវគ្គបណ្តុះបណ្តាលជាក្រុមស្តីពីការផ្លាស់ប្តូរពេលធំធាត់ និងពេញវ័យ។* ទីក្រុងវ៉ាស៊ីងតោន ឌីស៊ី៖ វិទ្យាស្ថានសុខភាពបន្តពូជនៃសកលវិទ្យាល័យចចថោន។

ក្រុមប្រឹក្សាប្រជាជន(២០១០) «បំណិនជីវិត៖ ជំនាញចិត្តសាស្រ្ត និងអន្តរបុគ្គលសម្រាប់ក្មេងស្រីជំទង់នៅក្នុងតំបន់ទីក្រុងហ្គាណា» ទីក្រុងញូវយ៉ក។

មិនឱ្យសម្រេចបាននូវបំណងប្រាថ្នាទាំងនេះ។

*កិច្ចការក្នុងថ្នាក់៖*

☞ ចែកឯកសារចែកជូន «ល្បែងជិះកង់» (សន្លឹកកិច្ចការក្នុងថ្នាក់របស់សិស្សទំព័រទី៦៦)ឱ្យសិស្សម្នាក់ៗ និងសុំឱ្យពួកគេជ្រើសរើសបំណងប្រាថ្នាមួយក្នុងចំណោមបំណងប្រាថ្នានាពេលអនាគតនានារបស់គេសម្រាប់សកម្មភាពនេះ។ សិស្សត្រូវតែជ្រើសរើស បំណងប្រាថ្នាណាមួយដែលសំខាន់បំផុតសម្រាប់ខ្លួន។ បន្ទាប់មក សិស្សត្រូវគិត រកមើល(កំណត់) និងសរសេរឧបសគ្គចំនួន២ដែលអាចកើតមាន(ពន្ទុកកាត់ទទឹងផ្លូវសម្រាប់កាត់បន្ថយល្បឿន) និងជំហានជោគជ័យតូចៗចំនួន២(ទង់កំណត់ពីជំហានជោគជ័យ)នៅលើដងវិថី(មធ្យោបាយ)ដើម្បីសម្រេចបំណងប្រាថ្នារបស់ពួកគេក្នុងពេលដែលពួកគេកំពុងបំពេញចម្លើយទៅនឹងសំណួរនៅលើឯកសារចែកជូនដែរ។ សុំឱ្យសិស្ស២-៣នាក់ស្ម័គ្រចិត្តចែករំលែកចម្លើយរបស់ខ្លួនជាមួយក្រុមធំ។

☞ ធ្វើការជាក្រុម កំណត់ពីធនធាននៅតាមមូលដ្ឋានដែលអាចគាំទ្រ និងជួយពួកគេឱ្យសម្រេចបានបំណងប្រាថ្នារបស់ខ្លួន។ ធនធានទាំងនេះរួមមាន ៖ ឪពុកម្តាយ និងមនុស្សពេញវ័យដែលយកចិត្តទុកដាក់ថែរក្សា ការិយាល័យអង្គការសេវាយុវជន មជ្ឈមណ្ឌលយុវជន ក្លឹបកុមារី និងកុមារា ក្រុមសិក្សា និងអាហារូបករណ៍ វេទិកាយុវជន មណ្ឌលសុខភាព និងអាគារវិជ្ជសាស្ត្រ បណ្តាញភ្នាក់ងារសុខភាពសហគមន៍ កម្មវិធីបណ្តុះបណ្តាលការងារ និងធនធានផ្សេងៗទៀត។

☞ *អនុវត្តក៏បាន មិនអនុវត្តក៏បាន ៖* ប្រសិនបើនៅមានពេល អាចសុំឱ្យសិស្សស្ម័គ្រចិត្ត ២-៣នាក់រៀបចំការសម្តែងតួដើម្បីឆ្លុះបញ្ចាំងថាតើការទទួលជំនួយមួយពីធនធានដែលមានតាមមូលដ្ឋាននោះមានលក្ខណៈបែបណា។

*កិច្ចការផ្ទះ៖*

☞ ណែនាំសិស្សថាសម្រាប់កិច្ចការផ្ទះ ដោយសិស្សត្រូវគិតពីគោលដៅមួយ និងសរសេរ (ឬគ្រាន់តែគិត) កិច្ចការចំនួន៣ដែលពួកគេអាចធ្វើបាន ឬកំពុងតែធ្វើរួចហើយដើម្បីចាប់ផ្តើមអនុវត្តមធ្យោបាយឆ្ពោះទៅរកការសម្រេចបានគោលដៅរបស់គេ (ធ្វើលំនាំល្បែងជិះកង់)។ ប្រសិនបើសិស្សនឹកមិនឃើញពីជំហានចំនួន៣ ពួកគេនៅតែត្រូវកំណត់ពីគោលដៅមួយ និងត្រូវត្រៀមចែករំលែកគោលដៅនោះជាមួយក្រុមធំនៅមេរៀនបន្ទាប់។ បន្ទាប់មក ក្រុមទាំងមូលក៏អាចឆ្លើយតបដោយការផ្តល់នូវគំនិត និងសំណូមពរនានាសម្រាប់ការសម្រេចគោលដៅ។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

- តើអ្វីជាការឆ្លុះបញ្ចាំងរបស់អ្នកចំពោះលំហាត់នេះ?
- តើវាងាយស្រួលដែរឬទេក្នុងការសម្រេចបំណងប្រាថ្នារបស់មនុស្សម្នាក់?
    - មធ្យោបាយដើម្បីសម្រេចបំណងប្រាថ្នា និងគោលដៅរបស់មនុស្សម្នាក់អាចជាដំណើរមួយដែលពោរពេញដោយឧបសគ្គ និងជំហានជោគជ័យតូចៗដែលនាំឱ្យបុគ្គលនោះខិតទៅរកបន្ទាត់(ចំណុច)គោលដៅរបស់គេ។ បំណងប្រាថ្នាផ្សេងៗអាចមានលក្ខណៈខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ប៉ុន្តែបើទោះបីជាមនុស្សមួយចំនួនមានបំណងប្រាថ្នាស្រដៀងគ្នាក៏ដោយ

ក៏ដំណើរឆ្ពោះទៅរកការសម្រេចបំណងប្រាថ្នារបស់ខ្លួនអាចមានលក្ខណៈខុសគ្នាដែរ។ ចំណុចនេះគឺដោយសារស្ថានភាព ធនធាន ចំណុចខ្លាំង និងចំណុចខ្សោយផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ កំណត់ពីមធ្យោបាយរបស់គេ។ ហេតុដូចនេះ ពួកគេអាចជួបប្រទះនូវការលំបាកខុសៗគ្នា និងមានជំហានជោគជ័យ តូចៗ ឬដំណាក់កាលជោគជ័យផ្សេងៗគ្នាដែរ។

- តើមានចំណុចអ្វីខ្លះក្នុងចំណោមចំណុចនានាដែលអាចជួយអ្នកឱ្យសម្រេចបំណងប្រាថ្នារបស់អ្នកបាន?

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- សកម្មភាពនេះតម្រូវឱ្យមានការផ្តោតអារម្មណ៍ដោយខ្លួនឯងយ៉ាងខ្លាំង ហើយសិស្សមួយចំនួនអាចមានកម្រិតសមត្ថភាពខុសៗគ្នាក្នុងការចាប់ផ្តើមការងាររបស់គេសម្រាប់ល្បែងជិះកង់នេះ។ ដូច្នេះ គេតម្រូវឱ្យមានការលើកទឹកចិត្តម្នាក់ម្តងៗបន្តិចបន្តួចដោយមិនធ្វើឱ្យប៉ះពាល់ទៅលើចម្លើយរបស់សិស្សម្នាក់ៗ។
- ការសម្តែងដែលគេបានណែនាំជាជម្រើសមួយនៅចុងបញ្ចប់នៃសកម្មភាពនេះ អាចជាជំនួយដ៏ល្អមួយដើម្បីបង្កើនទំនុកចិត្ត និងលទ្ធភាពទំនាក់ទំនងរបស់សិស្ស។ វានឹងធ្វើឱ្យគោលដៅ និងបំណងប្រាថ្នានានាកាន់តែមានភាពពិតប្រាកដ(ច្បាស់លាស់) នៅពេលដែលមានគេនិយាយពីគោលដៅ និងបំណងប្រាថ្នាទាំងនោះនៅក្នុងបរិបទនៃការស្វែងរកការគាំទ្រ(ជំនួយ)។

**សារសំខាន់ៗ ៖**

- ការកំណត់ពីបំណងប្រាថ្នារបស់មនុស្សម្នាក់គឺជាជំហានដំបូងក្នុងការសម្រេចបាននូវបំណងប្រាថ្នានោះ។ ជំហានបន្ទាប់គឺទាក់ទងនឹងការគិតពីកត្តាផ្សេងៗ ការវិភាគពីការលំបាក និងការកំណត់ពីគោលដៅតូចៗ។
- នៅពេលដែលគូរផែនទីគោលដៅរួចហើយ វាជាការសំខាន់ក្នុងការកំណត់ពី ធនធានដែលមានដែលអាចជួយ និងគាំទ្រការព្យាយាមសម្រេចគោលដៅរបស់មនុស្សម្នាក់ៗ។

**ឯកសារចែកជូនទី ១ ៖ ល្បែងជិះកង់**

ល្បែងជិះកង់ គឺជាវិធីសាស្ត្រដ៏សប្បាយមួយដើម្បីគិតពីការស្វែងរកផ្លូវ (មធ្យោបាយ) ដើម្បីសម្រេចគោលដៅរបស់អ្នក។

- តើអ្វីអាចក្លាយជាបញ្ហាប្រឈមនៅពេលអ្នកចង់សម្រេចបំណងប្រាថ្នារបស់អ្នក? ចូរសរសេរអំពីបញ្ហាប្រឈមចំនួន២ដែលអ្នកអាចគិតឃើញ ៖

  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………

- តើអ្នកមានផែនការអ្វីដើម្បីជម្នះបញ្ហាប្រឈមដែលអាចកើតឡើងទាំងនេះ? ចូរសរសេរពីដំណោះស្រាយចំនួន២ដែលអាចធ្វើបានក្នុងការជម្នះបញ្ហាប្រឈមទាំងនេះ ៖

  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………
  ……………………………………………………………………………………………………



# មេរៀនទី៣៖ មិត្តទាំង៥នាក់របស់ខ្ញុំ ៖ គោលដៅ និងការកំណត់គោលដៅ[៣]

🕒 **រយៈពេល** ៖ ១ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីយល់ពីគោលដៅ និងការកំណត់គោលដៅ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្តារខៀន និងដីស ប៊ិក ឬខ្មៅដៃ (សិស្សម្នាក់1ដើម) ឯកសារចែកជូនទី២ និងទី៣ (១ច្បាប់សម្រាប់សិស្សម្នាក់)។

☞ សម្រាប់សិស្ស៖ សន្លឹកកិច្ចការក្នុងថ្នាក់របស់សិស្សទំព័រទី៦៧។

**ការរៀបចំទុកជាមុន** ៖

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ថតចម្លងឯកសារចែកជូនទី២ និងទី៣ ដើម្បីចែកសិស្សម្នាក់១សម្រាប់។

☞ អាន និងសិក្សាពីក្របខ័ណ្ឌចំណេះដឹងរបស់មេរៀន។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

**ផ្នែកទី ១**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ សរសេរចំណងជើងរបស់សកម្មភាព «មិត្តទាំង៥នាក់របស់ខ្ញុំ ៖ គោលដៅ និងការកំណត់គោលដៅ»នៅលើក្តារខៀនដើម្បីឱ្យសិស្សទាំងអស់មើលឃើញ។ សួរសិស្សពីកិច្ចការផ្ទះដែលបានដាក់ឱ្យធ្វើកាលពីចុងមេរៀនមុន និងប្រាប់ពួកគេថា វត្ថុបំណងនៃសកម្មភាពនេះគឺត្រូវយល់ពីអ្វីដែលជាគោលដៅ និងហេតុអ្វីបានជាការកំណត់គោលដៅមានសារៈសំខាន់។

---

[៣] ក្រុមប្រឹក្សាប្រជាជន(២០១០) "បំណិនជីវិត៖ ជំនាញចិត្តសាស្ត្រ និងអន្តរបុគ្គលសម្រាប់ក្មេងស្រីជំទង់នៅក្នុងតំបន់ ទីក្រុងហ្គាណា" ទីក្រុងញូវយ៉ក។

ICRW,. (២០១៦). *កម្មវិធី ភែស ប្រនហ្ស៍ (P.A.C.E Bronze ) សម្រាប់ក្មេងស្រីពេញវ័យ។* Gap Inc.

- ☞ លេងល្បែងមួយដែលទាក់ទងនឹងពាក្យជាមួយសិស្សដោយសុំឱ្យសិស្សប្រាប់ពីពាក្យនានាដែលគេមាននៅក្នុងចិត្តពេលគេគិតពីពាក្យថា«គោលដៅ»។ លោកគ្រូ អ្នកគ្រូត្រូវកត់ពាក្យគន្លឹះដែលសិស្សបាននិយាយនៅលើក្ដារខៀនទុកជាពាក្យយោង។
- ☞ បន្ទាប់មកត្រូវប្រាប់ពីនិយមន័យរបស់ពាក្យ «គោលដៅ»ដល់សិស្សទាំងអស់គ្នា។
  - ☝ គេឱ្យនិយមន័យ **គោលដៅ** ថាជាអ្វីមួយដែលយើងចង់**សម្រេចបាន**នាពេលអនាគត។ វាជាអ្វីមួយដែលយើងមានបំណងចង់សម្រេចវា។ វាជាសមិទ្ធផល***ជាក់លាក់***ដែលជួយយើងឱ្យបំពេញនូវក្ដីសុបិន និងបំណងប្រាថ្នារបស់យើងនៅក្នុងជីវិត។ ឧទាហរណ៍ ៖ ប្រសិនបើបំណងប្រាថ្នារបស់ក្រុមកីឡាបាល់ទាត់គឺចង់ឈ្នះការប្រកួត គោលដៅមួយចំនួនក្នុងចំណោមគោលដៅនានារបស់ពួកគេគឺត្រូវហាត់សមឱ្យបានញឹកញាប់ ត្រូវមានរាងកាយមាំមួន និងផ្ដោតលើការកែលម្អចំណុចខ្សោយរបស់ខ្លួនជាដើម។

**ផ្នែកទី ២**

**សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ☞ សួរសិស្សថា ហេតុអ្វីបានជាគេគិតថាការកំណត់គោលដៅមានសារៈសំខាន់?
  - ☝ ចម្លើយអាចមានដូចខាងក្រោម ៖
    - សម្រាប់ការរីកចម្រើន និងអភិវឌ្ឍរបស់បុគ្គលម្នាក់ៗ
    - សម្រាប់ភាពជោគជ័យ និងសមិទ្ធផលក្នុងជីវិត
    - ដើម្បីផ្ដល់នូវទិសដៅ និងគោលបំណងក្នុងជីវិត
    - ដើម្បីក្លាយជាបុគ្គលឯករាជ្យ និងពឹងពាក់ខ្លួនឯងបាន
    - ដើម្បីបង្កើតអ្វីមួយនៅក្នុងជីវិតរបស់ខ្ញុំ
    - ដើម្បីបំពេញក្ដីសុបិនរបស់ខ្ញុំ
- ☞ កំណត់និយមន័យការកំណត់គោលដៅដល់សិស្សដូចខាងក្រោម ៖
  - ☝ **ការកំណត់គោលដៅ** គឺជាការគិតពីអនាគតចំពោះអ្វីដែលយើងចង់ធ្វើ ឬ សម្រេចឱ្យបាន ឬ ប្រាថ្នាចង់ធ្វើតាមវិធីជាក់លាក់ណាមួយ។ ការកំណត់គោលដៅគឺមានលក្ខណៈលើសពីការសម្រេចចិត្តពីអ្វីដែលយើងចង់ធ្វើទៅទៀត។ វាពាក់ព័ន្ធនឹងការពិចារណាថា ៖
    - តើយើងចង់ទៅទីណា?
    - តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះដើម្បីទៅដល់ទីនោះ?
    - តើវាត្រូវចំណាយពេលប៉ុន្មានដើម្បីទៅដល់ទីនោះ?

*កិច្ចការក្នុងថ្នាក់៖*

- ☞ ចែកឯកសារចែកជូនទី២ - មិត្តទាំង៥របស់ខ្ញុំឱ្យសិស្សម្នាក់ៗ និងសុំឱ្យគេពិភាក្សាជាមួយអ្នកដែលអង្គុយជិតខ្លួនពីរបៀបកំណត់គោលដៅ។
- ☞ បន្តសកម្មភាពក្នុងលំហាត់«ការកំណត់គោលដៅ» និងចែកឯកសារចែកជូនទី៣ (សន្លឹកកិច្ចការសិស្សទំព័រទី៦៧) ទៅឱ្យសិស្សម្នាក់ៗ។ បែងចែកសិស្សជាក្រុមតូចៗ។ ប្រាប់សិស្សថា ពួកគេនឹងត្រូវធ្វើផែនការសកម្មភាពរៀងៗខ្លួនដោយប្រើឯកសារចែកជូន «មិត្តទាំង៥» ។ ដំបូង ក្រុមតូចនីមួយៗត្រូវមានការពិភាក្សាគ្នាមួយដើម្បីកំណត់ពីផ្នែកនានានៃជីវិតរបស់យើងដែលយើងត្រូវរៀបចំគោលដៅ និងផែនការសម្រាប់វា។ គោលដៅអាចជា ៖ មធ្យោបាយមួយនៃការរស់នៅ ឬ ការងារដែលយើងចង់ធ្វើ ឬទេពកោសល្យអ្វីមួយដែលយើងចង់ចេះ។ បន្ទាប់មកបុគ្គលម្នាក់ៗនៅក្នុងក្រុមត្រូវធ្វើការម្នាក់ឯងក្នុងរយៈពេល១៥នាទី និងកំណត់គោលដៅចំនួន៥ផ្នែកនៃជីវិតរបស់គេដែលពួកគេត្រូវរៀបចំផែនការសម្រាប់ផ្នែកទាំងនោះ។ ផ្នែកបន្ថែមផ្សេងទៀតណាមួយនៃជីវិតដែលក្រុមបានពិភាក្សា (ដែលមិនទាន់មាននៅក្នុងឯកសារចែកជូន) គឺអាចបន្ថែមទៅក្នុងជួរទំនេរ។
- ☞ នៅពេលដែលសិស្សម្នាក់ៗបញ្ចប់ការងារដាច់ដោយឡែករបស់ខ្លួនហើយ គេត្រូវបង្ហាញផែនការនោះទៅកាន់ក្រុមតូចរបស់គេ។ សមាជិកក្រុមអាចចែករំលែក ឬផ្តល់ព័ត៌មានត្រលប់ និងសំណូមពរផ្សេងៗឱ្យគ្នាទៅវិញទៅមក។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

- តើ «មិត្តទាំង៥» ជួយប្អូនឱ្យសម្រេចគោលដៅរបស់ប្អូនបានយ៉ាងដូចម្តេច?
- តើប្អូនមានការលំបាកអ្វីខ្លះនៅពេលដែលប្អូនកំណត់ពីគោលដៅរបស់ប្អូន?
- តើវាជាការសំខាន់ដែរ ឬទេក្នុងការមានគោលដៅផ្សេងៗក្នុងជីវិត? ហេតុអ្វី?
  - វាពិតជាមានសារៈសំខាន់! ការមានគោលដៅមានសារៈសំខាន់ណាស់ដោយសារវាជួយយើងឱ្យសម្រេចបំណងប្រាថ្នារបស់យើង។ ការកំណត់គោលដៅជួយយើងឱ្យរៀបចំប្លង់(ផែនទី)ស្តីពីជំហានដែលយើងត្រូវធ្វើដើម្បីសម្រេចបាននូវបំណងប្រាថ្នារបស់យើង។ ឧទាហរណ៍ ៖ ប្រសិនបើបំណងប្រាថ្នារបស់បុគ្គលម្នាក់ចង់ក្លាយជាវេជ្ជបណ្ឌិត គេអាចសម្រេចបំណងប្រាថ្នានេះបាន លុះត្រាណាតែគេអាចសម្រេចបាននូវគោលដៅតូចៗនៃការធ្វើឱ្យបានល្អចំពោះផ្នែកវិទ្យាសាស្ត្រនៅថ្នាក់ទី១២។ មនុស្សម្នាក់អាចផ្លាស់ប្តូរ ឬតម្រង់គោលដៅឡើងវិញទៅតាមពេលវេលា ប្រសិនបើបំណងប្រាថ្នារបស់គេផ្លាស់ប្តូរ។
- តើគោលដៅជានិច្ចកាលត្រូវភ្ជាប់ទៅនឹងបំណងប្រាថ្នារបស់មនុស្សម្នាក់ៗឬ?
  - វាមិនចាំបាច់ទេ! គោលដៅមួយចំនួនអាចមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបំណងប្រាថ្នាជាក់

លាក់មួយឡើយ ប៉ុន្តែវានៅតែមានសារៈសំខាន់សម្រាប់យើងដដែល។ តួយ៉ាង មនុស្សម្នាក់អាចមានគោលដៅមួយដែលគេចង់ធ្វើជាទម្លាប់ ៖ ព្រោះគេចង់ប្រកាន់យកទម្លាប់នៃការគេង និងហាត់ប្រាណឱ្យបានទៀងទាត់។ ទោះបីជាពេលខ្លះ គោលដៅគឺជារឿងផ្ទាល់ខ្លួនរបស់យើងក្តី ក៏យើងអាចមានគោលដៅដែលតម្រង់ទៅរក ឬផ្តោតលើការសម្រេចបាននូវផលប្រយោជន៍ដ៏ធំសម្រាប់សហគមន៍ដែរ។ ជាញឹកញាប់ គោលដៅក៏ពឹងផ្អែកលើធនធានការអប់រំ ប្រព័ន្ធគាំទ្រ។ល។ របស់យើងដែរ។

- តើយើងកំណត់គោលដៅផ្សេងៗដោយរបៀបណា?
  - នៅពេលដែលយើងកំណត់ពីបំណងប្រាថ្នារបស់យើង យើងត្រូវចាប់ផ្តើមធ្វើការគិតបកក្រោយឡើងវិញដើម្បីកំណត់ពីចំណុចដៅនៃភារកិច្ចរបស់យើង។ ចំណុចដៅទាំងអស់នេះជាគោលដៅរបស់យើង។
- តើប្អូនមានសំណួរអ្វីខ្លះទេពី «មិត្តទាំង៥» និងរបៀបរៀបចំផែនការ?
- បញ្ចប់សកម្មភាពដោយសង្ខេបចំណុចដែលបានរៀនសូត្រសំខាន់ៗដែលសិស្សបានរកឃើញ និងសរសេរវាទុកនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- រំឭកសិស្សថា គោលដៅរបស់គេត្រូវមានលក្ខណៈផ្ទាល់ខ្លួនតាមដែលអាចធ្វើទៅបានជាជាងការផ្អែកលើតែការរំពឹងទុករបស់ឪពុកម្តាយ ឬសង្គម។
- ចងចាំថា វាអាចមានលទ្ធភាពដែលក្មេងស្រីជាច្រើនអាចពុំមានគំនិតពីគោលដៅនានាពីមុនមកទេ ហើយក៏អាចពុំមានគោលដៅផ្នែកវិជ្ជាជីវៈ ឬការអប់រំទេត្រង់ចំណុចនេះ។ ចំណុចស្នូលរបស់កម្មវិធីសិក្សា Gap Inc. P.A.C.E. គឺត្រូវផ្តល់នូវការលើកទឹកចិត្តដល់សិស្សទាំងអស់ និងបណ្តុះពួកគេឱ្យមានលទ្ធភាព មានសេចក្តីប្រាថ្នា និងក្តីសុបិនពីអនាគតរបស់ពួកគេ។
- ចងចាំថា ដំណើរការក្នុងការគិតពីគោលដៅគឺជាការផ្តល់ភាពអង់អាចដល់សិស្សដោយផ្ទាល់ ហើយគេម្នាក់ៗនឹងមើលឃើញពីលទ្ធផលវិជ្ជមាន និងអវិជ្ជមានតាមរយៈដំណើរការនេះ។

**សារសំខាន់ៗ ៖**

- គេឱ្យនិយមន័យ**គោលដៅ**ថាជាអ្វីមួយដែលយើងចង់***សម្រេចឱ្យបាន*** នាពេលអនាគត។ វាជាអ្វីមួយដែលយើងមានបំណងចង់សម្រេចឱ្យបាន។ វាជាសមិទ្ធផល*ជាក់លាក់* ដែលជួយ

យើងឱ្យសម្រេចបាននូវក្តីសុបិន ឬបំណងប្រាថ្នារបស់យើងក្នុងជីវិត។

- ការសម្រេចគោលដៅអាចមិនមានភាពងាយស្រួលទេ ដោយសារតែវានឹងមានឧបសគ្គជាច្រើន។ ការកំណត់ចំណុចដៅសំខាន់ៗ ការរកឱ្យឃើញនូវវិធីដែលមនុស្សម្នាក់សម្រេចបានគោលដៅនោះ និងធនធានអ្វីខ្លះដែលគេត្រូវការជួយដល់ដំណើរការនៃការខិតខំប្រឹងប្រែង កំណត់អាទិភាព និងប្រើប្រាស់ពេលវេលារបស់គេឱ្យមានប្រសិទ្ធភាព។
- គោលដៅអាចនឹងត្រូវបានផ្លាស់ប្តូរ ឬរៀបចំឡើងវិញដោយសារតែបំណងប្រាថ្នារបស់យើងអាចនឹងផ្លាស់ប្តូរនៅពេលដែលយើងធំឡើង។

**ឯកសារចែកជូនទី២ ៖ មិត្តទាំង៥**

ការកំណត់គោលដៅពាក់ព័ន្ធនឹង ៖ អ្វីដែលយើងចង់ធ្វើ និងវិធីដែលយើងចង់ធ្វើវា។ ឬអាចនិយាយម្យ៉ាងទៀតថា ៖

- **ជំហានដំបូង**ក្នុងការកំណត់គោលដៅគឺត្រូវដឹងថាតើយើងចង់ទៅទីណា។
- **ជំហានទី២**គឺត្រូវមានផែនការដើម្បីទៅឱ្យដល់ទីនោះ។

**វាមានសារៈសំខាន់ក្នុងការគិតពីវិធី**ក្នុងការសម្រេចចិត្តពីគោលដៅអ្វីដែលត្រូវកំណត់ និងរបៀបកំណត់គោលដៅប្រកបដោយភាពច្បាស់លាស់ និងអាចសម្រេចបាន។

ជួបជាមួយ «មិត្តទាំង៥» របស់ផែនការល្អ។ លើកដៃរបស់ប្អូនឡើង ហើយសម្រាប់ម្រាមដៃនីមួយៗចូរសរសេរមិត្តទាំង៥ ៖ ហេតុអ្វី នរណា របៀបណា ពេលណា អ្វី។ ការធ្វើបែបនេះគឺអ្វីៗគ្រប់យ៉ាងនៅក្នុងដៃរបស់ប្អូន (ជានិមិត្តសញ្ញា) ហើយមិត្តទាំង៥នាក់នេះនៅជាមួយប្អូនជានិច្ច។




- **ហេតុអ្វី?** មូលហេតុសម្រាប់ធ្វើការងារឆ្ពោះទៅកាន់គោលដៅមួយ។
- **នរណា?** បុគ្គល ឬមនុស្ស (ម្នាក់ ឬច្រើននាក់) ដែលត្រូវអនុវត្តផែនការ។
- **របៀបណា?** សកម្មភាពមួយជំហានម្តងៗដែលចាំបាច់។
- **ពេលណា?** ពេលវេលាដែលត្រូវអនុវត្តជំហាននីមួយៗ និងការសម្រេចគោលដៅ។
- **អ្វី?** ធនធានដែលត្រូវការដើម្បីសម្រេចគោលដៅ។

ឯកសារចែកជូនទី៣ ៖  ការកំណត់គោលដៅរបស់ខ្ញុំ

| | គោលដៅ | ហេតុអ្វី? | នរណា? | របៀបណា? | ពេលណា? | អ្វី? |
|---|---|---|---|---|---|---|
| ផ្ទាល់ខ្លួន | | | | | | |
| គ្រួសារ | | | | | | |
| ការអប់រំ ឬសាលារៀន | | | | | | |
| មិត្តភក្តិ | | | | | | |
| សុខភាព | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ក្របខ័ណ្ឌចំណេះដឹង

### បំណងប្រាថ្នា និងយេនឌ័រ

បំណងប្រាថ្នាគឺជាជម្រើស និងឆន្ទៈរបស់បុគ្គលម្នាក់ៗក្នុងការសម្រេចឱ្យបាននូវអ្វីដែលគេចង់ធ្វើសម្រាប់ផ្នែកវិជ្ជាជីវៈ និងផ្ទាល់ខ្លួន។ ជាញឹកញាប់ ស្ត្រីមានការពិបាកក្នុងការបង្ហាញពីបំណងប្រាថ្នាផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ខ្លួន។ ការសង្កេតមួយក្នុងចំណោមការសង្កេតនានាដែលធនាគារពិភពលោកបានធ្វើឡើងក្នុងឆ្នាំ ២០១២ មានបុរសចំនួន ៥៥% បាននិយាយថា ពួកគេរំពឹងថាស្ត្រីមានទាំងតួនាទីថែទាំគ្រួសារ និងជាមេគ្រួសារ។ ការរំពឹងទុកទាំងនេះ និងការកំណត់តួនាទីរបស់ស្ត្រីធ្វើឱ្យពួកគេមានដែនកំណត់ចំពោះក្តីសុបិន និងជម្រើសរបស់ខ្លួន។ ដូចអ្វីដែលយើងបានយល់ពីម៉ូឌុលមុន ជាញឹកញាប់ យេនឌ័រ និងអនុត្តរភាពនៃអំណាចផ្តល់សារៈសំខាន់តិចតួចទៅលើការរួមចំណែករបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ វាមានសារៈសំខាន់ក្នុងការទទួលស្គាល់ថា ស្ត្រី និងក្មេងស្រីពិតជាមានសិទ្ធិក្នុងការស្វែងយល់ពីសក្តានុពល ក្តីសុបិន និងជីវិតរបស់ខ្លួន ហើយនៅក្នុងដំណើរការនេះពួកគេក៏ជាអ្នកសម្រេចចិត្តលើជម្រើសនៃជីវិតរបស់ខ្លួនផ្ទាល់ដែរ។

### គោលដៅ[៩]

គោលដៅជាអ្វីមួយដែលប្អូនចង់សម្រេចឱ្យបាន។ វាអាចជាអ្វីមួយដែលត្រូវធ្វើ កន្លែងដែលត្រូវទៅ ឬអ្វីដែលគេចង់បាន។ គោលដៅផ្តល់ឱ្យយើងនូវអ្វីមួយដែលយើងទន្ទឹងរង់ចាំ និងអាចផ្តល់ថាមពលឱ្យយើងផងដែរ។ ដើម្បីកំណត់គោលដៅបាន យើងត្រូវប្រមូលព័ត៌មាន ព្រមទាំងធ្វើការសម្រេចចិត្ត និងជ្រើសរើស។ យើងត្រូវរៀន(ដឹង)ពីអ្វីដែលយើងចង់សម្រេចឱ្យបាន។ គោលដៅត្រូវមានភាពជាក់លាក់ ជាក់ស្តែង និងមានពេលវេលាកំណត់មួយ។ ដើម្បីសម្រេចគោលដៅមួយ វាពិតជាមានប្រយោជន៍ក្នុងការរៀបចំផែនការមួយ និងគិតពីផលវិបាកដែលអាចកើតមាន ព្រមទាំងវិធីដែលគេអាចជម្នះការលំបាកទាំងនោះបាន។

ដើម្បីសម្រេចគោលដៅរបស់យើង យើងត្រូវខិតខំធ្វើការ មានជំនឿថា យើងអាចធ្វើវាបាន និងមានការតាំងចិត្ត។ ដើម្បីជួយនរណាម្នាក់ឱ្យសម្រេចបានគោលដៅរបស់គេ ចូរសួរពួកគេនូវសំណួរខាងក្រោមនេះ ៖

- តើគេចង់សម្រេចគោលដៅនេះនៅពេលណា?
- ប្រសិនបើគេសម្រេចគោលដៅនេះ តើវានឹងជួយគេដូចម្តេច?
- តើមានជំហានអ្វីខ្លះដែលគេត្រូវអនុវត្តដើម្បីសម្រេចបានគោលដៅរបស់គេ?
- តើមានរឿងអ្វីខ្លះដែលអាចរារាំងគេមិនឱ្យសម្រេចបានគោលដៅរបស់គេ?
- តើសកម្មភាព(វិធានការ)អ្វីខ្លះដែលគេអាចធ្វើបានដើម្បីជម្នះការលំបាកទាំងនេះ?

[៩] (2២០១៦). ទាញយកពី https://www.path.org/publications/files/CP_kenya_pe_manual_karhp.pdf

**គោលដៅ ជ.វ.ស.ប.ព (SMART)**

វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រដែលសាមញ្ញបំផុតក្នុងការរៀបចំគោលដៅនេះគឺត្រូវកំណត់ថាតើគោលដៅដែលយើងមាន មានលក្ខណៈ «ជ.វ.ស.ប.ព» (SMART) ដែរឬទេ។ គោលដៅគឺ ៖

- **ជាក់លាក់** (Specific) ៖ កំណត់បានយ៉ាងល្អ ច្បាស់លាស់សម្រាប់បុគ្គលណាមួយដែលអាចជាប់ទាក់ទងនឹងគោលដៅ។
- **អាចវាស់វែងបាន** (Measurable) ៖ ជួយកំណត់ថាតើមនុស្សម្នាក់នៅឆ្ងាយប៉ុណ្ណាពីការសម្រេចគោលដៅរបស់គេ។
- **អាចសម្រេចបាន** (Achievable) ៖ ជាអ្វីដែលមានពិតប្រាកដក្នុងពេលបច្ចុប្បន្ន ហើយដែលគេអាចសម្រេចបាន។
- **ប្រាកដនិយម** (Realistic) ៖ សំដៅទៅលើការវាយតម្លៃពីភាពប្រាកដនិយមនៃស្ថានភាពរបស់អ្នកកំណត់គោលដៅ។ គេត្រូវគិតពីធនធានរបស់ខ្លួនដែលមានដូចជាចំណេះដឹង ជំនាញ ឬលទ្ធភាពក្នុងការកសាងចំណេះដឹង និងជំនាញ ពេលវេលា ការគាំទ្រពីខាងក្រៅ ។ល។ ស្របពេលដែលគោលការណ៍នេះលើកទឹកចិត្តឱ្យបុគ្គលម្នាក់ៗកំណត់ពីគោលដៅមួយដោយផ្អែកលើបរិបទ ឬប្រវត្តិស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ខ្លួន គេមិនត្រូវយល់ដោយភាពចង្អៀតចង្អល់ដោយរៀបចំគោលដៅដែលខ្វះមហិច្ឆិតា ឬមានដែនកំណត់ចំពោះគោលដៅរបស់ខ្លួនទេ។ ភាពឆ្លើយតបតាមធម្មតាសំដៅទៅលើការគិតឱ្យបានជិតដល់ពីបរិបទរបស់មនុស្សម្នាក់នៅក្នុងការកំណត់ពីគោលដៅមួយ។
- **ពេលវេលាកំណត់** (Time-bound) ៖ ដើម្បីសម្រេចឱ្យបានក្នុងរយៈពេលមួយដែលបានកំណត់។

# ជំពូកទី២ ៖ ការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលា

### ទិដ្ឋភាពទូទៅ

វ័យជំទង់គឺជាពេលវេលាដែលមានការផ្លាស់ប្តូររាងកាយ និងអារម្មណ៍ច្រើនសម្រាប់មនុស្សដែលនៅវ័យក្មេង។ ជាពិសេស ក្មេងស្រីវ័យជំទង់ក៏ត្រូវជម្នះនឹងសម្ពាធផ្សេងៗពីសាលារៀន និងការងារផ្ទះ ព្រមទាំងទំនួលខុសត្រូវក្នុងគ្រួសារ។ ជាញឹកញាប់ ពួកគេតែងតែយល់ឃើញថាកំពុងស្ថិតនៅក្នុងស្ថានភាពដែលត្រូវធ្វើការសម្រេចចិត្តសំខាន់ៗដែលនឹងជះឥទ្ធិពលលើជីវិត និងអនាគតរបស់ពួកគេ។ ឧទាហរណ៍ ការមានលទ្ធភាពធ្វើសេចក្តីសម្រេចចិត្ត ថាតើពួកគេចង់រៀនអ្វីបន្ទាប់ពីរៀនចប់នៅសាលាដែរឬទេ ប្រសិនបើពួកគេចង់ស្វែងរកវិជ្ជាជីវៈមួយ ឬថាតើពួកគេចង់រៀបអាពាហ៍ពិពាហ៍ពេលគឺនៅពេលណា និងជាមួយនរណា ។ល។ ការសម្រេចចិត្តរបៀបនេះមានឥទ្ធិពលខ្លាំង និងយូរអង្វែងលើជីវិតរបស់មនុស្សម្នាក់ៗ។ ដើម្បីឱ្យក្មេងស្រីមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួនក្នុងការដឹកនាំជីវិតប្រចាំថ្ងៃ ធ្វើសេចក្តីសម្រេចចិត្ត និងធ្វើការដើម្បីសម្រេចបំណងប្រាថ្នារបស់ពួកគេ ពួកគេត្រូវអភិវឌ្ឍជំនាញផ្សេងៗដូចជាការដោះស្រាយបញ្ហា ការធ្វើសេចក្តីសម្រេចចិត្ត ការគ្រប់គ្រងប្រាក់កាស និងពេលវេលា។ មេរៀននេះនឹងណែនាំពីទស្សនៈទាននៃជំនាញទាំងនេះដល់សិស្សក្នុងលក្ខណៈមួយដែលជួយពួកគេឱ្យអនុវត្ត និងយល់ដឹងពីមេរៀនទាំងនេះក្នុងកម្រិតមួយចំនួន។

🕘 **រយៈពេលរួម ៖ ៣ ម៉ោង ៣០ នាទី**

❐ **ចំនួនលំនាំបង្រៀនសរុប ៖ ៤ មេរៀន**

### 🏆 វត្ថុបំណង ៖

- ☺ ដើម្បីយល់ពីការកំណត់អាទិភាព ការដោះស្រាយបញ្ហា និងការធ្វើសេចក្តីសម្រេចចិត្ត
- ☺ ដើម្បីអាចវាស់វែងពីផលវិបាកនៃការសម្រេចចិត្តដែលពួកគេបានធ្វើ
- ☺ ដើម្បីដឹងអំពីតម្លៃនៃពេលវេលានិងអាចគ្រប់គ្រងពេលវេលារបស់គេឱ្យបានកាន់តែប្រសើរ
- ☺ ដើម្បីជំរុញសិស្សឱ្យគិតពីធនធានហិរញ្ញវត្ថុ និងយល់ពីរបៀបរៀបចំផែនការសន្សំប្រាក់។

# មេរៀនទី៤ ៖ ការគ្រប់គ្រងពេលវេលា

🕒 **រយៈពេល ៖ ៤៥ នាទី**

➲ **វត្ថុបំណង ៖** ដើម្បីយល់ពីតម្លៃពេលវេលា និងរៀនពីរបៀបគ្រប់គ្រងពេលវេលាឱ្យមានប្រសិទ្ធភាព

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ ៖**

- ☞ សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្តារខៀន និងដីស ឯកសារចែកជូនទី៤ និងទី៥ (សិស្សម្នាក់១ច្បាប់) បង់ស្អិតប្លាស្ទិកមូល (ឬស្ទីកគ័រ មានចំនួនគ្រប់គ្រាន់សម្រាប់ឯកសារចែកជូនទី៤) និងប៊ិក និងខ្មៅដៃ (១ដើមសម្រាប់សិស្សម្នាក់)។
- ☞ សម្រាប់សិស្ស៖ សន្លឹកកិច្ចការក្នុងថ្នាក់របស់សិស្សទំព័រទី៦៨។

**ការរៀបចំទុកជាមុន ៖**

- ☞ អានទិដ្ឋភាពទូទៅស្តីពី ជំពូកទី២ ៖ ការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលា។
- ☞ ថតចម្លងឯកសារចែកជូនទី៤ និងទី៥ សម្រាប់ចែកជូនសិស្ស។
- ☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ☞ ចាប់ផ្តើមសកម្មភាពដោយពិភាក្សាជាក្រុមពីអត្ថន័យរបស់ពាក្យ«ការគ្រប់គ្រងពេលវេលា»។ លោកគ្រូ អ្នកគ្រូត្រូវកត់ត្រាចម្លើយរបស់សិស្សលើក្តារខៀន។
- ☞ ប្រាប់សិស្សថា ពេលវេលាគឺជាធនធានដ៏មានតម្លៃមួយ។ សុំឱ្យសិស្ស គិតពីពេលវេលានៅក្នុងបរិបទនេះ និងយកចិត្តទុកដាក់លើគំនិតនៃការគ្រប់គ្រងពេលវេលានៅក្នុងសកម្មភាពនេះតាំងពីដើមរហូតដល់ចប់។

***កិច្ចការក្នុងថ្នាក់៖***

- ☞ ចែកឯកសារចែកជូនទី៤ ៖ «ក្រដាសសកម្មភាពសម្រាប់បិទបង់ស្អិតប្លាស្ទិករាងមូល» (**សន្លឹកកិច្ចការសិស្សទំព័រទី៦៨**) ដល់សិស្សទាំងអស់។ ឱ្យសិស្សទាំងអស់បិទបង់ស្អិតប្លាស្ទិករាងមូលមួយសម្រាប់ពេលវេលាមួយម៉ោងៗលើសកម្មភាពដែលរៀបរាប់នៅលើក្រដាស។ នៅពេលដែលសិស្សបានបញ្ចប់កិច្ចការនេះហើយ ចូរសួរពួកគេថា តើមានសកម្មភាពអ្វីផ្សេងក្រៅពីនេះដែលពួកគេចង់ធ្វើប៉ុន្តែមិនមានពេលគ្រប់គ្រាន់ ឬអ្វីដែលគេត្រូវធ្វើតិចជាងអ្វីដែលពួកគេចង់បាន។ ឧទាហរណ៍ ៖ សកម្មភាពទាំងនេះអាចរួមមានការទៅលេងផ្ទះមិត្តភក្តិ ការចំណាយពេល

ច្រើនជាមួយមិត្តភក្តិក្រោយពេលចេញពីសាលា ឬរៀនបន្ថែម ការលេងកីឡា ការរៀនគូរូប ការទៅផ្សារ ការមើលទូរទស្សន៍ ការគេងថ្ងៃ ។ល។ ចូរកត់ត្រាចម្លើយរបស់សិស្សលើក្រដាសផ្ទាំងធំ ឬក្តារខៀន។

☞ ចែកឯកសារចែកជូនទី៥ ៖ «តារាងពេលវេលាគំរូ» ទៅឱ្យសិស្សទាំងអស់ និងបញ្ចប់សកម្មភាពនេះដោយធ្វើការពិភាក្សាទៅតាមការណែនាំ។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ពិភាក្សា ៖**

◇ តើប្អូនអាចធ្វើអ្វីបានដើម្បីបង្កើតពេលវេលាសម្រាប់កិច្ចការផ្សេងៗដែលប្អូនចង់ធ្វើ? ក្នុងចំណោមកិច្ចការដែលប្អូនចង់ធ្វើ តើមានទាក់ទងទៅនឹងគោលដៅរបស់ប្អូនដែរឬទេ?

☝ ប្អូនមិនអាចបង្កើតពេលវេលាបន្ថែមបានទេ។ មនុស្សគ្រប់រូបមានចំនួនម៉ោងដូចគ្នាក្នុងមួយថ្ងៃៗ ប៉ុន្តែប្អូនអាចគ្រប់គ្រង និងចាត់ចែងពេលវេលារបស់ប្អូនបានកាន់តែប្រសើរ ដើម្បីបញ្ចូលកិច្ចការ និងសកម្មភាពដែលប្អូនចង់ធ្វើ និងដែលជួយក្នុងការរៀបចំផែនការដើម្បីសម្រេចគោលដៅរបស់ប្អូន។ ដើម្បីគ្រប់គ្រងពេលវេលារបស់ប្អូនឱ្យមានប្រសិទ្ធភាព ប្អូនត្រូវចេះបែងចែករវាងកិច្ចការ**បន្ទាន់** និងកិច្ចការ**សំខាន់**។ មនុស្សគ្រប់រូបសុទ្ធតែមានកិច្ចការផ្សេងៗដែលពួកគេចង់ធ្វើខ្លាំងបំផុតក្នុងមួយថ្ងៃៗ ប៉ុន្តែក្នុងមួយថ្ងៃៗក៏ទាមទារឱ្យយើងបំពេញភារកិច្ច ឬសកម្មភាពជាក់លាក់ជាប្រចាំផងដែរ។ ដើម្បីអាចរកតុល្យភាពចំពោះការគ្រប់គ្រងពេលវេលារបស់យើងប្រកបដោយប្រសិទ្ធភាព យើងត្រូវតែយល់ពីភាពខុសគ្នាដូចខាងក្រោម ៖

- **ភារកិច្ចសំខាន់ៗ** ៖ ភារកិច្ចសំខាន់អាចទាក់ទងនឹងបំណងប្រាថ្នារបស់នរណាម្នាក់ដែលជាទូទៅមានរយៈពេលវែង និងជាយុទ្ធសាស្ត្រ។ ឧទាហរណ៍ ៖ ប្រសិនបើបំណងប្រាថ្នារបស់ក្មេងស្រីម្នាក់គឺត្រូវធ្វើជាគ្រូពេទ្យ ហើយគោលដៅរបស់នាងគឺត្រៀមខ្លួនសម្រាប់ចូលរួមការប្រឡងប្រជែងមួយបន្ទាប់ពីនាងបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សាទុតិយភូមិ នោះនាងប្រហែលជាចាំបាច់ត្រូវពង្រឹងភាសាបារាំង និងបំណិន ឬជំនាញនៃចំណេះដឹងទូទៅរបស់នាង។ ចំពោះករណីនេះ នាងត្រូវបង្កើតទម្លាប់អានកាសែតមួយម៉ោងជារៀងរាល់ថ្ងៃ។ ការប្រឡង និង ការងារដែលនាងត្រូវការដើម្បីរៀបចំសម្រាប់កិច្ចការនេះគឺជាភារកិច្ចដ៏សំខាន់។ ដូច្នេះនាងត្រូវតែផ្តល់អាទិភាពឱ្យការងារនេះ និងរៀបចំពេលវេលាប្រចាំថ្ងៃមួយផ្នែករបស់នាងដើម្បីឱ្យនាងអាចសម្រេចគោលដៅប្រកបដោយជោគជ័យចំពោះការត្រៀមរៀបចំការប្រឡងប្រកួតប្រជែងគ្នានេះ។
- **កិច្ចការបន្ទាន់** ៖ តាមធម្មតា កិច្ចការបន្ទាន់ក៏មានសារៈសំខាន់ដែរ ប៉ុន្តែភាពបន្ទាន់របស់វាគឺទាក់ទងនឹងកត្តាពេលវេលា (ឧទាហរណ៍ ៖ រយៈពេលខ្លី ការប្តេជ្ញាចិត្តទៅតាមពេលវេលា ភាពបន្ទាន់ និងផ្អែកលើកាលបរិច្ឆេទកំណត់)។ ជូនកាលកិច្ចការបន្ទាន់អាចជាអាទិភាពសំខាន់របស់នរណាម្នាក់ផ្សេងទៀត(មិនមែនជារបស់ប្អូន) ប៉ុន្តែគេអាចទម្លាក់

កិច្ចការនោះឱ្យប្អូនថាជាកិច្ចការបន្ទាន់។ ដោយប្រើឧទាហរណ៍ដដែលរបស់ក្មេងស្រីដែលប្រាថ្នាចង់ក្លាយជាគ្រូពេទ្យ ៖ ថ្ងៃមួយគេប្រាប់នាងនៅក្នុងថ្នាក់ថា សាលារៀនមានភ្ញៀវសំខាន់ម្នាក់នៅថ្ងៃបន្ទាប់ ហើយសិស្សទាំងអស់ត្រូវរៀបចំផ្ទាំងរូបភាពចម្រុះពណ៌ដើម្បីលម្អថ្នាក់រៀនរបស់គេ។ ទស្សនកិច្ចសាលារៀនដែលជោគជ័យមានសារៈសំខាន់សម្រាប់នាយកសាលា ប៉ុន្តែវាបានក្លាយទៅជាកិច្ចការបន្ទាន់សម្រាប់ក្មេងស្រីនោះទៅវិញ។ ខណៈពេលដែលការអានកាសែតជារឿងសំខាន់សម្រាប់គោលដៅរយៈពេលវែងរបស់នាងក្នុងការចូលរួមការប្រឡងដោយជោគជ័យ នាងត្រូវ **លើក** ការអានកាសែតនៅថ្ងៃនេះ ព្រោះនាងត្រូវតែរៀបចំផ្ទាំងរូបភាពសម្រាប់ថ្ងៃបន្ទាប់។ ការធ្វើការងារឱ្យបានល្អសម្រាប់ថ្នាក់រៀន និងសាលារៀនរបស់នាងក៏ជាការចាំបាច់ដើម្បីទទួលបានការទទួលស្គាល់ និងដើម្បីឱ្យនាងទទួលបានអារម្មណ៍លើកទឹកចិត្តក្នុងការបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ។ កិច្ចការនេះបានក្លាយទៅជាកិច្ចការដែលសំខាន់ផង និងបន្ទាន់ផង សម្រាប់នាង។ ប្រសិនបើកិច្ចការនោះជាការដែលម្តាយរបស់នាងប្រើឱ្យចិតបន្លែ នាងអាចសុំឱ្យម្តាយរបស់នាងប្រើបងប្អូនរបស់នាងធ្វើជំនួសវិញដើម្បីឱ្យនាងអាចអានកាសែតបានរយៈពេលកន្លះម៉ោង ឬនាងអាចចិតបន្លែឱ្យលឿន ហើយនៅតែទុកពេលវេលាខ្លះដើម្បីអានកាសែត។

- ហេតុអ្វីបានជាការគ្រប់គ្រងពេលវេលាមានសារៈសំខាន់?
  - ការគ្រប់គ្រងពេលវេលាប្រកបដោយប្រសិទ្ធភាព គឺជាគន្លឹះក្នុងការសម្រេចគោលដៅនិងបំណងប្រាថ្នា។ មានតែនៅពេលដែលមនុស្សម្នាក់អាចគ្រប់គ្រងពេលវេលាដើម្បីបញ្ចូលកិច្ចការដែលគេ **ចង់** ធ្វើ និងកិច្ចការដែលគេចាំបាច់ **ត្រូវ** ធ្វើប៉ុណ្ណោះ ទើបអ្នកនោះអាចធ្វើការឆ្ពោះទៅរកគោលដៅនាពេលអនាគតបាន។
- តើមនុស្សម្នាក់រៀបចំផែនការគ្រប់គ្រងពេលវេលាបានដោយរបៀបណា?
  - មនុស្សគ្រប់រូបមានពេល២៤ម៉ោងក្នុងមួយថ្ងៃ និង១៦៨ម៉ោងក្នុងមួយសប្តាហ៍ ប៉ុន្តែប្រសិនបើមនុស្សម្នាក់មិនរៀបចំផែនការពីរបៀបចំណាយពេលវេលាទេមិនប្រាកដថាពួកគេនឹងបញ្ចប់រាល់កិច្ចការអ្វីៗដែលគេចង់ធ្វើបានដោយជោគជ័យទេ។ ដូច្នេះ ការរៀបផែនការប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍មានសារៈខាន់ណាស់។ ការរៀបចំពេលវេលាក៏អាចជួយឱ្យមនុស្សម្នាក់មានទំនុកចិត្តកាន់តែច្រើន និងគ្រប់គ្រងពេលវេលាដែលមានបាន។ ទោះជាយ៉ាងនេះក្តី នៅពេលដែលនរណារៀបផែនការលម្អិត វាមានសារៈសំខាន់ដែរក្នុងការទុកពេលទំនេរដើម្បីសម្រាក ឬពេលវេលាសម្រាប់កិច្ចការដែលមិនបានគ្រោងទុក ពោលគឺនៅពេលដែលមានរឿងអ្វីមួយកើតឡើងភ្លាមៗ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☺ ចំណុចសម្រាប់ការពិភាក្សាពន្យល់អំពីទិដ្ឋភាព និងទស្សនៈនៃការគ្រប់គ្រងពេលវេលា

ព្រមទាំងសារៈសំខាន់របស់វា។ ប៉ុន្តែ នៅពេលពិភាក្សាពីចំណុចទាំងនេះ វាក៏មានសារៈសំខាន់ដែរក្នុងការទទួលស្គាល់ថា ខណៈពេលដែលការគ្រប់គ្រងពេលវេលាគឺជាជំនាញដ៏សំខាន់ដែលមនុស្សគ្រប់គ្នាត្រូវព្យាយាមអភិវឌ្ឍក៏ដោយ ពេលខ្លះការអនុវត្តវាអាចជួបប្រទះនឹងបញ្ហាប្រឈមដោយសារបទដ្ឋានយេនឌ័រអាចមានឥទ្ធិពល និងដាក់កំហិតលើការអនុវត្តនោះ។ ឧទាហរណ៍ ៖ មនុស្សម្នាក់ប្រហែលជាចង់នៅលេងខាងក្រៅឱ្យបានយូរ ឬចំណាយពេលយូរដើម្បីសិក្សាបន្ថែមក្រោយចប់ម៉ោងរៀន ប៉ុន្តែគេត្រូវជួយចម្អិនម្ហូបអាហារ និងសម្អាតផ្ទះ ហេតុដូច្នេះហើយគេត្រូវកំណត់ពេលកម្សាន្ត និងសិក្សាទៅតាមនោះដែរ។

☺ ដោយចងចាំពីចំណុចខាងលើ លោកគ្រូ អ្នកគ្រូក៏អាចជ្រើសរើសរំឭកសិស្សពីមេរៀនស្តីពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទង និងការចរចាដើម្បីមានលទ្ធភាពប្រឈមនឹងការដាក់កំហិតលើយេនឌ័រ។ ឧទាហរណ៍ ៖ ប្រសិនបើតួនាទីយេនឌ័រតម្រូវឱ្យកុមារជួយការងារផ្ទះបាយនៅពេលពួកគេចង់អានកាសែត ពេលនោះគេអាចមានលទ្ធភាពក្នុងការស្វែងរកការពិភាក្សាដោយស្មោះត្រង់ និងជឿជាក់ជាមួយសមាជិកគ្រួសារពីបំណងប្រាថ្នារបស់ខ្លួនក្នុងការត្រៀមខ្លួនសម្រាប់ការប្រឡងយកអាជីពមួយនាពេលអនាគត។

✉ **សារសំខាន់ៗ ៖**

☺ យើងម្នាក់ៗមានពេល ២៤ ម៉ោងក្នុង១ថ្ងៃ។ របៀបដែលប្រើពេលវេលានេះគឺអាស្រ័យលើយើងម្នាក់ៗជាអ្នករៀបចំ។

☺ ដើម្បីអាចគ្រប់គ្រងពេលវេលាឱ្យមានប្រសិទ្ធភាព មនុស្សម្នាក់ៗត្រូវតែចេះបែងចែករវាងកិច្ចការបន្ទាន់ និងកិច្ចការសំខាន់ ហើយត្រូវកំណត់អាទិភាពរបស់វា។

☺ ការគ្រប់គ្រងពេលវេលាប្រកបដោយប្រសិទ្ធភាពមានន័យថា ការរៀបចំផែនការប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ជាមុនដើម្បីបញ្ចូលទាំងកិច្ចការបន្ទាន់ និងសំខាន់។

## ឯកសារចែកជូនទី៤ ៖ ក្រដាសសកម្មភាពសម្រាប់បិទស្កុតស្អិតប្លាស្ទិករាងមូល

សូមបិទស្កុតស្អិតប្លាស្ទិករាងមូលមួយសម្រាប់ពេលវេលាដែលបានចំណាយលើការធ្វើសកម្មភាពចំនួនមួយម៉ោងៗ (លើរយៈពេល២៤ម៉ោង) ក្នុងតារាងខាងក្រោមនេះ។ ឧទាហរណ៍ ៖ ប្រសិនបើនរណាម្នាក់ចំណាយពេលសិក្សាបន្ថែម២ម៉ោងក្នុង១ថ្ងៃ និងកម្សាន្តមួយម៉ោង នោះពួកគេត្រូវបិទដូចខាងក្រោម ៖

| | |
|---|---|
| ការសិក្សាបន្ថែម | ● ● |
| ការកម្សាន្ត | ● |

| |
|---|
| ការងារផ្ទះ |
| រៀបចំខ្លួនទៅសាលារៀន |
| នៅសាលារៀន |
| ត្រលប់ទៅផ្ទះ |
| ញ៉ាំអាហារថ្ងៃត្រង់ |
| សិក្សាបន្ថែម |
| កម្សាន្ត |
| ធ្វើកិច្ចការសាលា |
| ជួយការងារក្នុងផ្ទះ |
| គេង |

ឯកសារចែកជូនទី៥ ៖ តារាងពេលវេលាគំរូ

| សកម្មភាព | ចំនួនម៉ោងក្នុងមួយថ្ងៃ | ចំនួនម៉ោងក្នុងមួយសប្តាហ៍ |
|---|---|---|
| គេង | | |
| ញ៉ាំអាហារពេលព្រឹក | | |
| ញ៉ាំអាហារថ្ងៃត្រង់ | | |
| ញ៉ាំអាហារពេលល្ងាច | | |
| ការងារ | | |
| រៀន | | |
| ធ្វើដំណើរ | | |
| ការថែទាំផ្ទាល់ខ្លួន | | |
| កិច្ចការប្រចាំថ្ងៃ | | |
| ការកម្សាន្ត | | |
| សរុប | | |

# មេរៀនទី៥ ៖ តើខ្ញុំសម្រេចចិត្តដោយរបៀបណា?[៥]

🕒 រយៈពេល ៖ ១ ម៉ោង

➲ វត្ថុបំណង ៖ ដើម្បីបង្កើតការយល់ដឹងពីការធ្វើសេចក្តីសម្រេចចិត្តដ៏ល្អ។

## ១. ការរៀបចំ

📖 សម្ភារៈដែលត្រូវការ ៖

☞ សម្រាប់គ្រូ៖ ឧបសម្ព័ន្ធទី២ ១ច្បាប់ ចំណុចនៃការសម្រេចចិត្ត ឯកសារចែកជូនទី៦៖ ជំហានប្រកបដោយប្រសិទ្ធភាពដែលជួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត(សិស្ស ម្នាក់១ច្បាប់) ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្តារខៀន និងដីស។

☞ សម្រាប់សិស្ស៖ សន្លឹកកិច្ចការសិស្សទំព័រទី៦៩-៧០។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ថតចម្លងឧបសម្ព័ន្ធ២ និងឯកសារចែកជូនទី៦ សម្រាប់ចែកសិស្សម្នាក់១ច្បាប់។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ ចាប់ផ្តើមសកម្មភាពដោយធ្វើលំហាត់ស្វ័យឆ្លុះបញ្ចាំង។ ឱ្យសិស្សម្នាក់ៗគិតពីថ្ងៃរបស់គេ ពោលគឺចាប់ពីពេលដែលពួកគេភ្ញាក់ពីគេងរហូតដល់ពេលនេះ។ សុំឱ្យសិស្សស្ម័គ្រចិត្តចែករំលែកជាមួយក្រុមទាំងមូលនូវការសម្រេចចិត្តមួយដែលពួកគេបានធ្វើក្នុងថ្ងៃនេះ។ លោកគ្រូ អ្នកគ្រូត្រូវកត់ត្រាការសម្រេចចិត្តទាំងនេះនៅលើក្តារខៀន។ ផ្អែកលើចម្លើយដែលគេឆ្លើយច្រើនគ្នាបំផុត (ឧទាហរណ៍ ៖ អ្វីដែលត្រូវស្លៀកពាក់ អ្វីដែលត្រូវបរិភោគ អ្នកដែលត្រូវនិយាយជាមួយ ផ្លូវដែលត្រូវដើរទៅផ្សារ ឬសាលា) ចូរជ្រើសរើសចំណុចនៃការសម្រេចចិត្តមួយដើម្បីពិភាក្សា។ វាមានសារៈសំខាន់ក្នុងការបញ្ជាក់ថា យើងធ្វើការសម្រេចចិត្តរៀងរាល់ថ្ងៃ ប៉ុន្តែជារឿយៗ យើងមិនបានគិតពីការសម្រេចចិត្តទាំងនេះទេ។

☞ បន្តសកម្មភាពដោយស្នើសុំឱ្យសិស្សគិតពីពេលវេលាដែលពួកគេធ្វើការសម្រេចចិត្តដ៏

---

[៥] សាលាសុខភាពសាធារណៈ/មជ្ឈមណ្ឌលសម្រាប់កម្មវិធីទំនាក់ទំនង Johns Hopkins Bloomberg. (២០១១). Go Girls! បំណិនជីវិតសហគមន៍សម្រាប់ក្មេងស្រី៖ សៀវភៅណែនាំអំពីការបណ្តុះបណ្តាល។ ទីក្រុងបាល់ទីម័រ នៃរដ្ឋម៉ារីលែន (បង្កើតឡើងក្រោមលក្ខខណ្ឌនៃ USAID គម្រោង SEARCH)

ពិបាកមួយ។ សុំឱ្យសិស្សបែរទៅរកអ្នកដែលអង្គុយនៅក្បែរពួកគេ និងពន្យល់ពីការសម្រេចចិត្តនោះ និងអ្វីដែលបានកើតឡើង។ សិស្សទាំងអស់ត្រូវចំណាយពេលប្រាំនាទីសម្រាប់ការពិភាក្សានេះ។

☞ ណែនាំឱ្យក្រុមស្គាល់នូវជំហានទាំងបីសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដ៏ល្អ ៖

១. ឈប់ ហើយបន្ទាប់មកគិត

២. ពិចារណាពីផលវិបាកផ្សេងៗនៃការសម្រេចចិត្តរបស់ប្អូន

៣. ស្គាល់ការពិត

☞ បន្តសកម្មភាពដោយលេងល្បែងស្តីពី «ចំណុចនៃការសម្រេចចិត្ត» ដែលផ្តល់ឱកាសមួយឱ្យសិស្សអនុវត្តជាក់ស្តែងនូវការធ្វើសេចក្តីសម្រេចចិត្ត (សូមមើលឧបសម្ព័ន្ធទី២ ៖ ចំណុចនៃការសម្រេចចិត្តរបស់ រស្មី និង ខេមរៈ)។

☞ ក្រោយពេលចប់ល្បែងនោះ ចូរសង្ខេបមេរៀនសំខាន់ៗឡើងវិញជាមួយនឹងការពិភាក្សាពីជំហានប្រកបដោយប្រសិទ្ធភាពសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។

☞ នៅចុងបញ្ចប់នៃសកម្មភាពនេះសូមចែកឯកសារចែកជូនទី៦៖ «ជំហានប្រកបដោយប្រសិទ្ធភាពដែលជួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត» ដល់សិស្សទាំងអស់ទុកជាឯកសារយកទៅផ្ទះ។ ប្រាប់សិស្សទាំងអស់ថា ពួកគេត្រូវរក្សាទុកឯកសារចែកជូននេះហើយយកវាត្រលប់មកវិញសម្រាប់មេរៀនបន្ទាប់។

*កិច្ចការផ្ទះ៖*

☞ ឱ្យសិស្សបើកសន្លឹកកិច្ចការរបស់ខ្លួននៅទំព័រទី៦៩និង៧០។

☞ អាន និងណែនាំសិស្សនូវអ្វីដែលពួកគេត្រូវធ្វើនៅផ្ទះ។

☞ ប្រាប់សិស្សពីសារៈសំខាន់នៃការកិច្ចការនេះសម្រាប់ការសិក្សានៅក្នុងមេរៀនបន្ទាប់។

## ៣. ការពង្រឹងចំណេះដឹង

**🗣 ចំណុចសម្រាប់ការពិភាក្សា ៖**

◈ តើចំណុចនៃការសម្រេចចិត្តមានអ្វីខ្លះនៅក្នុងសាច់រឿងនេះ?

◈ តើផលវិបាកនៃការសម្រេចចិត្តរបស់រស្មីមានអ្វីខ្លះ?

◈ តើម្នាក់ៗធ្លាប់ពុះពារ ឬស្វែងរកជំនួយក្នុងការធ្វើសេចក្តីសម្រេចចិត្តដែរឬទេនៅដំណាក់កាលណាមួយក្នុងជីវិតរបស់គេ?

◈ តើប្អូននឹងធ្វើការសម្រេចចិត្តប្រហាក់ប្រហែលគ្នាឬទេ ប្រសិនបើប្អូនស្ថិតក្នុងស្ថានភាពដូចគ្នា? ហេតុអ្វី?

◈ តើប្អូនអាចចែករំលែកយុទ្ធសាស្ត្រមួយចំនួនក្នុងចំណោមយុទ្ធសាស្ត្រនានាដែលមានប្រសិទ្ធភាព និងមិនមានប្រសិទ្ធភាពសម្រាប់ប្អូនដែលបានធ្វើការសម្រេចចិត្តណាមួយកន្លងមកបានដែរឬទេ?

◈ តើជំហានអ្វីខ្លះដែលប្អូនគិតថាមានប្រសិទ្ធភាពដែលជួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត?[៦]

☝ ជាទូទៅ មនុស្សម្នាក់ៗត្រូវគិតគូរពីទីកន្លែង ពេលវេលា និងស្ថានភាពដែលមាននៅពេលដែលធ្វើការសម្រេចចិត្តណាមួយ។ ជំហានមួយចំនួនដែលជួយក្នុងការធ្វើសេចក្តីសម្រេចចិត្តរួមមាន ៖

- ពិចារណាពីអ្វីដែលនឹងធ្វើឱ្យការសម្រេចចិត្តមានភាពងាយស្រួលបំផុតក្នុងការអនុវត្ត។
- គិតពីឧបសគ្គដែលអាចរាំងដល់ការសម្រេចចិត្ត។
- សាកល្បងធ្វើការសម្រេចចិត្តឡើងវិញដោយសុវត្ថិភាព ឬដោយខ្លួនឯង។
- ពិភាក្សាពីការសម្រេចចិត្ត និងផែនការអនុវត្តជាមួយអ្នកដែលជួយផ្តល់ការគាំទ្រ។
- គិតពីវិធីអនុវត្តការសម្រេចចិត្តរបស់ប្អូនដែលមានសុវត្ថិភាព។
- គិតពីរបៀបផ្សេងៗដែលការសម្រេចចិត្តរបស់ប្អូនអាចមានផលប៉ះពាល់ដល់អ្នកដទៃ។
- ជ្រើសរើសការសម្រេចចិត្តដែលមើលទៅសមស្របបំផុតដោយផ្អែកលើចំណេះដឹង គុណតម្លៃ និងគោលដៅបច្ចុប្បន្ន និងអនាគតរបស់ប្អូន។
- អនុវត្តការសម្រេចចិត្តរបស់ប្អូនទៅតាមផែនការ។
- ប្រសិនបើមានឧបសគ្គកើតឡើងនៅពេលអនុវត្តការសម្រេចចិត្ត ចូររៀបចំផែនការសកម្មភាពផ្សេងទៀត ឬគិតពីការសម្រេចចិត្តឡើងវិញ។
- ត្រូវចងចាំថា ទោះបីជាពួកគេមិនជួបឧបសគ្គក៏ដោយ ក៏ពួកគេមានសិទ្ធិវាយតម្លៃការសម្រេចចិត្តឡើងវិញ និងផ្លាស់ប្តូរចិត្តរបស់ពួកគេបានដែរ។
- ចូរគិតពីវិធីដែលសមស្របបំផុតក្នុងការចែករំលែកការសម្រេចចិត្តនោះទៅកាន់ក្រុមគ្រួសាររបស់ប្អូន ដោយរាប់បញ្ចូលទាំងឱកាស ពេលវេលា និងកាលៈទេសៈសមស្របដើម្បីកាត់បន្ថយការប្រឆាំង។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- នេះគឺជាលំហាត់សម្រាប់ការរៀនសូត្រមួយសម្រាប់មនុស្សវ័យក្មេងដែលពួកគេមួយចំនួនអាចមានសមត្ថភាពធ្វើសេចក្តីសម្រេចចិត្តបានល្អជាងអ្នកផ្សេងទៀត។ វាមានសារៈសំខាន់ក្នុងការពង្រីកការគោរព និងការលើកទឹកចិត្តដល់អ្នកគ្រប់គ្នាដើម្បីធានាថា សិស្សម្នាក់ៗមានអារម្មណ៍ថាដំណើរការ និងការព្យាយាមរបស់គេត្រូវបានគេឱ្យតម្លៃ។

[៦] ក្រុមការងារកម្មវិធីសិក្សាអំពីផ្លូវភេទ និងជំងឺអេដស៍អន្តរជាតិ (២០០៩). *Its All One*. ក្រុមប្រឹក្សាប្រជាជន។

✉ **សារសំខាន់ៗ ៖**

☺ ការសម្រេចចិត្តគឺជាសកម្មភាពនៃការធ្វើការជ្រើសរើសរវាងជម្រើសច្រើន។

☺ នៅពេលធ្វើការសម្រេចចិត្ត វាអាចជួយដល់ការគិតស្រមៃពីអ្វីដែលនឹងកើតឡើងនាពេលអនាគតនៅពេលដែលនរណាម្នាក់ជ្រើសរើសជម្រើសនីមួយៗក្នុងចំណោមជម្រើសខុសៗគ្នា។

☺ ការនិយាយជាមួយអ្នកដទៃក៏អាចជួយប្អូនឱ្យធ្វើការសម្រេចចិត្តបានល្អដែរ ប៉ុន្តែប្អូនត្រូវជ្រើសរើសអ្នកដែលប្អូននឹងពិភាក្សាជាមួយចំពោះការសម្រេចចិត្តនោះដោយប្រុងប្រយ័ត្ន។ បុគ្គលម្នាក់នេះគួរតែជាមនុស្សដែលប្អូនជឿទុកចិត្ត ហើយប្រសិនបើវាជាការសម្រេចចិត្តដ៏លំបាក ឬការសម្រេចចិត្តដែលពាក់ព័ន្ធនឹងមនុស្សពេញវ័យ ពេលនោះប្អូនត្រូវជ្រើសរើសមនុស្សពេញវ័យដែលគួរទុកចិត្តដើម្បីពិភាក្សាពីការសម្រេចចិត្តរបស់ប្អូន។

**ឧបសម្ព័ន្ធទី២ ៖ ចំណុចនៃការសម្រេចចិត្ត (របស់ស្មី និង ខេមរៈ)**

ចាប់ផ្តើមលេងល្បែង «ចំណុចនៃការសម្រេចចិត្ត» ដោយពន្យល់សិស្សថា លោកគ្រូ អ្នកគ្រូ នឹងអានរឿងរបស់ ខេមរៈ និង ស្មី។ ចូរប្រាប់សិស្សថា នៅពេលណាក៏ដោយដែលលោកគ្រូ អ្នកគ្រូឈប់អានរឿងហើយទះដៃពីរដង (ទះដៃ ទះដៃ) មានន័យថា ស្មី និង ខេមរៈ ចាំបាច់ត្រូវឈប់ និងបន្ទាប់មកធ្វើការសម្រេចចិត្ត។ សិស្សត្រូវធ្វើការជាក្រុមដើម្បីធ្វើការសម្រេចចិត្តឱ្យ ស្មី និង ខេមរៈ។

- (អាន) ៖ យុវជនម្នាក់ឈ្មោះ ខេមរៈ ឈប់រថយន្តរបស់គាត់ដើម្បីនិយាយជាមួយក្មេងស្រីម្នាក់ដែលមានឈ្មោះថាស្មី ហើយនៅទីបំផុតគាត់បានសួរនាងថា តើនាងចង់រួមដំណើរជាមួយគាត់ដែរឬទេ។
  លោកគ្រូ អ្នកគ្រូទះដៃចំនួនពីរដង (ទះដៃ ទះដៃ)

  **ឈប់ ហើយបន្ទាប់មកគិត!**

  **សួរសិស្ស ៖**

  - **ផលវិបាក ៖** តើអាចមានអ្វីកើតឡើង ប្រសិនបើស្មីយល់ព្រមជិះរថយន្តជាមួយខេមរៈ? តើអាចមានអ្វីកើតឡើង ប្រសិនបើនាងមិនយល់ព្រម?
  - **ដឹងពីការពិត ៖** តើ ស្មី ដឹងអ្វីខ្លះពី ខេមរៈ? តើនាងដឹងអ្វីខ្លះទៀតពីអ្នកដទៃដែលយល់ព្រមជិះឡានជាមួយ ខេមរៈ? ឬតើមានអ្នកដទៃចូលចិត្តគាត់ដែរឬទេ?

- (អាន) ៖ ស្មី យល់ព្រមជិះរថយន្តជាមួយខេមរៈ ហើយខេមរៈបានឈប់នៅហាងមួយ តាមផ្លូវទៅផ្ទះដើម្បីទិញតែឱ្យនាង។
  លោកគ្រូ អ្នកគ្រូទះដៃ ២ ដង (ទះដៃ ទះដៃ)

  **ឈប់ ហើយបន្ទាប់មកគិត!**

  **សួរសិស្ស ៖**

  - **ផលវិបាក ៖** តើអាចនឹងមានអ្វីកើតឡើង ប្រសិនបើ ស្មី យល់ព្រមផឹកតែជាមួយខេមរៈ? តើមានរឿងអ្វីកើតឡើង ប្រសិនបើនាងមិនយល់ព្រមផឹកតែជាមួយខេមរៈ?
  - **ដឹងពីការពិត ៖** ហេតុអ្វីបានជាខេមរៈ សុំឱ្យស្មីផឹកតែ?

- (អាន) ៖ ស្មី ប្រាប់ ខេមរៈ ថា នាងនឹងទៅហាងកាហ្វេជាមួយគាត់ ប្រសិនបើគាត់យល់ព្រមផឹកតែតែមួយភ្លែត ហើយបន្ទាប់មកជូននាងទៅផ្ទះ ដោយសារតែនាងនឹងត្រលប់ទៅផ្ទះវិញយឺតហើយ។ ខេមរៈក៏យល់ព្រម។ នៅក្នុងហាងគាត់បានបញ្ជាទិញតែ និងអាហារសម្រន់ជាបន្តបន្ទាប់ ហើយបន្តនិយាយជាមួយនាងរហូត។ ស្មី រំឭកគាត់ជាច្រើនដងថា នាងកំពុងតែយឺតម៉ោងហើយ ហើយគ្រួសាររបស់នាងនឹងបារម្ភពីនាង។ ខេមរៈខឹង ហើយនិយាយថា នាងជាមនុស្សរមិលគុណដោយនាងគួរតែដឹងគុណគាត់ដែលគាត់ជូននាងទៅ

ផ្ទះ ប៉ុន្តែនាងបែរជាបង្ខំគាត់ឱ្យប្រញាប់ទៅវិញ។ រស្មី ចាប់ផ្តើមមានអារម្មណ៍ភ័យខ្លាចនៅពេលដែលនាងមើលឃើញថាគាត់កំពុងតែមិនពេញចិត្ត និងខឹង។ ទីបំផុតពួកគេក៏ដើរចេញមកក្រៅ។ នៅពេលដែលនាងដើរចេញមកដល់ខាងក្រៅ នាងឃើញថាមេឃងងឹតទៅហើយ។ នាងត្រូវត្រលប់ទៅផ្ទះវិញ ហើយឥឡូវនេះនាងបារម្ភថាតើនាងអាចទុកចិត្តគាត់បានដែរឬទេ។

ទះដៃរបស់លោកគ្រូ អ្នកគ្រូពីរ២ដង (ទះដៃ ទះដៃ)

🚫 **ឈប់ ហើយបន្ទាប់មកគិត!**

**សួរសិស្ស ៖**

- **ផលវិបាក ៖** តើនាងអាចត្រលប់ទៅផ្ទះវិញដោយសុវត្ថិភាពបានដោយរបៀបណា? តើអាចមានអ្វីកើតឡើង ប្រសិនបើនាងព្យាយាមដើរទៅផ្ទះ? ឬឱ្យគាត់ជូននាងទៅផ្ទះ? តើអាចមានអ្វីកើតឡើង ប្រសិនបើនាងទាក់ទងមិត្តភក្តិ ឬសមាជិកគ្រួសារឱ្យមកយកនាងជំនួសវិញ?
- **ដឹងពីការពិត ៖** តើជម្រើសផ្សេងទៀតរបស់នាងមានអ្វីខ្លះ? តើនាងអាចសួរអ្នកផ្សេងបានដែរឬទេ? ឬទាក់ទងអ្នកផ្សេងឱ្យជួយ?

**ឯកសារចែកជូនទី៦ ៖ ជំហានប្រកបដោយប្រសិទ្ធភាពដែលជួយដល់ការធ្វើសេចក្ដីសម្រេចចិត្ត**

- គិតពិចារណាពីអ្វីដែលធ្វើឱ្យការសម្រេចចិត្តមានភាពងាយស្រួលបំផុតក្នុងការអនុវត្ត។
- គិតពីឧបសគ្គដែលអាចរារាំងដល់ការអនុវត្តការសម្រេចចិត្ត។
- សាកល្បងឡើងវិញ និងគិតពីការសម្រេចចិត្តរបស់ប្អូនដោយសុវត្ថិភាព ឬជាឯកជន។
- ពិភាក្សាពីការសម្រេចចិត្ត និងផែនការអនុវត្តជាមួយអ្នកដែលជួយផ្ដល់ការគាំទ្រ។
- គិតពីរបៀបការអនុវត្តការសម្រេចចិត្តរបស់ប្អូនដែលមានសុវត្ថិភាព។
- គិតពីរបៀបផ្សេងៗដែលការសម្រេចចិត្តរបស់ប្អូនអាចប៉ះពាល់ដល់អ្នកដទៃ។
- ជ្រើសរើសការសម្រេចចិត្តដែលមើលទៅសមស្របបំផុតដោយផ្អែកលើចំណេះដឹង គុណតម្លៃ ព្រមទាំងគោលដៅបច្ចុប្បន្ន និងអនាគតរបស់ប្អូន។
- អនុវត្តការសម្រេចចិត្តរបស់ប្អូនទៅតាមផែនការ។
- ប្រសិនបើមានឧបសគ្គកើតឡើងចំពោះការអនុវត្តការសម្រេចចិត្ត ចូររៀបចំផែនការសកម្មភាពផ្សេងទៀត ឬគិតឡើងវិញពីការសម្រេចចិត្តនោះ។
- ត្រូវចាំថា ទោះបីជាពួកគេមិនជួបឧបសគ្គក៏ដោយក៏ពួកគេមានសិទ្ធិវាយតម្លៃការសម្រេចចិត្តឡើងវិញ និងផ្លាស់ប្ដូរគំនិតរបស់គេបាន។
- ចូរគិតពីវិធីដែលសមស្របបំផុតក្នុងការចែករំលែកការសម្រេចចិត្តនោះទៅកាន់ក្រុមគ្រួសាររបស់ប្អូន ដោយរាប់បញ្ចូលទាំងឱកាស ពេលវេលា និងកាលៈទេសៈសមស្របដើម្បីកាត់បន្ថយការជំទាស់។

# មេរៀនទី៦ ៖ ការគ្រប់គ្រងប្រាក់

🕒 រយៈពេល ៖ ៤៥ នាទី

➲ វត្ថុបំណង ៖ ដើម្បីណែនាំសិស្សពីគោលគំនិតនៃការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួនដែលជាធនធានដ៏សំខាន់មួយ។

## ១. ការរៀបចំ

📖 សម្ភារៈដែលត្រូវការ ៖

☞ សម្រាប់គ្រូ៖ ក្ដារខៀន និងដីស ឬក្រដាសផ្ទាំងធំ និងហ្វឺត និងស្កុត កូនបាល់ (អាចជាបាល់ដែលរុំដោយអំបោះ រុំដោយស្រោមជើង ឬរុំដោយក្រដាស) ប័ណ្ណពាសន្លឹក (ឬក្រដាស) ដោយសរសេរពាក្យមួយក្នុងចំណោមពាក្យខាងក្រោមនេះ៖ «ផ្ទាល់ខ្លួន» «បន្ទាន់» «ឱកាសនាពេលអនាគត»។

☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

☞ សរសេរចំណងជើងដាក់លើក្ដារខៀន។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

**ផ្នែកទី ១**

🕒 រយៈពេល ៖ ១៥ នាទី

**ហេតុអ្វីបានជាយើងត្រូវសន្សំប្រាក់? បោះបាល់ៗ**

☞ សកម្មភាពនេះ គឺជាការបង្ហាញពីការគ្រប់គ្រងប្រាក់ ហើយវាគឺជាការបន្តមួយពីសកម្មភាពពីមុនៗមកដោយផ្ដោតលើការធ្វើសេចក្ដីសម្រេចចិត្ត និងការគ្រប់គ្រងពេលវេលា។ ដូចគ្នាទៅនឹងប្រធានបទចំនួន២ខាងលើ ការគ្រប់គ្រងប្រាក់គឺជាជំនាញដែលយើងអាចប្រើ និងទទួលផលប្រយោជន៍ពីជីវិតប្រចាំថ្ងៃរបស់យើង និងទទួលបានក្នុងរយៈពេលវែង។

☞ សុំឱ្យសិស្សឈរជារង្វង់។ ប្រាប់ពួកគេថា ពួកគេនឹងលេងល្បែងមួយដែលមានឈ្មោះថា «ការបោះបាល់» ហើយណែនាំពីការលេងល្បែងសិក្សានេះ ៖ លោកគ្រូ អ្នកគ្រូត្រូវនិយាយប្រយោគមិនពេញលេញមួយឃ្លា ហើយបោះបាល់ទៅឱ្យសិស្សណាម្នាក់នៅក្នុងរង្វង់នោះ។

សិស្សនោះត្រូវនិយាយប្រយោគដែលលោកគ្រូ អ្នកគ្រូនិយាយមិនទាន់ចប់ឡើងវិញ ហើយបន្ទាប់មកថែមពាក្យរបស់ខ្លួនដើម្បីឱ្យប្រយោគនោះមានន័យពេញលេញ។

☝ ឧទាហរណ៍ ៖

- លោកគ្រូ អ្នកគ្រូនិយាយថា ៖ ខ្ញុំសន្សំប្រាក់ដើម្បី ……………។
- សិស្សត្រូវនិយាយថា ៖ ខ្ញុំសន្សំប្រាក់ដើម្បី «ទិញខ្មៅដៃថ្មី»។

☞ បន្ទាប់ពីឆ្លើយរួចហើយ សិស្សនោះនឹងបោះបាល់ទៅសិស្សម្នាក់ទៀតនៅក្នុងរង្វង់។ សិស្សនេះត្រូវធ្វើរឿងដដែលដោយនិយាយឡើងវិញនូវអ្វីដែលលោកគ្រូ អ្នកគ្រូបាននិយាយ និងបន្ថែមពាក្យដើម្បីឱ្យប្រយោគមានខ្លឹមសារពេញលេញ ប៉ុន្តែត្រូវប្រើពាក្យ(ជម្រើស)ថ្មី។

☝ ឧទាហរណ៍ ៖

- សិស្សនិយាយថា ៖ ខ្ញុំសន្សំប្រាក់ដើម្បី - ទិញអំណោយឱ្យប្អូនប្រុសរបស់ខ្ញុំ។

☞ សកម្មភាពនេះគួរតែធ្វើឡើងចំនួនបីជុំដោយប្រើប្រយោគចាប់ផ្តើមខុសៗគ្នាសម្រាប់ជុំនីមួយៗ។ លោកគ្រូ អ្នកគ្រូត្រូវសម្រេចចិត្តពីពេលវេលាដែលត្រូវប្តូរទៅកាន់ប្រយោគថ្មី(នៅពេលសិស្សចាប់ផ្តើមធុញទ្រាន់ ឬជិនណាយជាមួយការប្រើប្រយោគមួយ សូមបន្តទៅប្រយោគបន្ទាប់)។ លំហាត់នេះដើរតួជាល្បែងថាមពល និងរក្សាភាពរស់រវើករបស់វា ។

☝ ប្រយោគទាំងបី ឬក្នុងមួយជុំៗ រួមមាន ៖

- ក្មេងស្រីអាយុដំណាលខ្ញុំសន្សំប្រាក់ដើម្បី ……………………………។
- ក្មេងប្រុសអាយុដំណាលខ្ញុំសន្សំប្រាក់ដើម្បី ……………………………។
- មនុស្សពេញវ័យច្រើនតែសន្សំប្រាក់ដើម្បី ………………………………។

☞ ក្រោយពីជុំទី៣ លោកគ្រូ អ្នកគ្រូត្រូវសង្ខេបការឆ្លើយតបទាំងអស់ឡើងវិញ។ ចូរលើកឡើងពីភាពខុសគ្នា និងភាពស្រដៀងគ្នារវាងហេតុផលដែលក្មេងស្រី ក្មេងប្រុស និងមនុស្សពេញវ័យសន្សំប្រាក់។

**ផ្នែកទី ២**

🕒 **រយៈពេល** ៖ ៣០ នាទី

**ហេតុផលដែលត្រូវសន្សំប្រាក់ ៖**

☞ នៅក្នុងផ្នែកដំបូងនៃសកម្មភាពនេះ សិស្សត្រូវមានហេតុផលផ្សេងៗគ្នាជាច្រើនក្នុងការសន្សំប្រាក់។ ភាគច្រើនទាក់ទងទៅនឹងហេតុផលមួយក្នុងចំណោមហេតុផលសំខាន់ៗដូចខាងក្រោម ហើយលោកគ្រូ អ្នកគ្រូត្រូវលើកឡើងដោយសង្ខេប ៖

១. ហេតុផលសំខាន់ដំបូងគឺ ៖ ការប្រើប្រាស់ផ្ទាល់ខ្លួន ឬគ្រួសារ ដែលអាចមានដូចជា ម្ហូបអាហារ សម្លៀកបំពាក់ ឈ្នួលផ្ទះ អាហារសម្រន់ ការថែទាំសក់ សំឡីអនាម័យ ឡេលាបស្បែក ហ្គាសសម្រាប់ចម្អិនជាដើម ។ល។

២. ហេតុផលសំខាន់ទី២គឺ ៖ ករណីបន្ទាន់ ករណីដែលមិនបានរំពឹងទុកផ្សេងៗ ដែលយើងត្រូវដោះស្រាយភ្លាមៗ។ ឧទាហរណ៍មានដូចជា ៖ ជំងឺ គ្រោះថ្នាក់ គ្រោះធម្មជាតិ ចោរកម្ម អគ្គិភ័យ ឪពុក ឬម្ដាយបាត់បង់ការងារ ការប្រមូលផលកសិកម្មមិនបានល្អ ។ល។

៣. ហេតុផលសំខាន់ទី៣គឺ ៖ ឱកាសនាពេលអនាគត ដូចជាគំនិតទាំងឡាយដែលបុគ្គលម្នាក់ចំនួនក្នុងចំណោមប្អូនមានសម្រាប់ពេលអនាគត។ យើងអាចសន្សំប្រាក់ដើម្បីបំពេញគោលដៅទាំងនេះ។ យើងអាចសន្សំប្រាក់ដើម្បីបង់ថ្លៃសិក្សា ថ្លៃសិក្សាបន្ថែម ជួយលើការចំណាយក្នុងគ្រួសារ ទិញសម្លៀកបំពាក់ថ្មីសម្រាប់ពិធីបុណ្យ។ល។ (ការអប់រំអាពាហ៍ពិពាហ៍ ការបណ្ដុះបណ្ដាល ឬសាលាជំនាញ ការអប់រំរបស់កូនៗ ផ្ទះ ឬដី ដើមទុនសម្រាប់ចាប់ផ្ដើមអាជីវកម្ម។ល។)

☞ រៀបចំកន្លែងមួយក្នុងបន្ទប់សម្រាប់ហេតុផលនីមួយៗក្នុងចំណោមហេតុផលសំខាន់ៗទាំង៣នេះ (ជ្រុង ទ្វារ ឬបង្អួចក្នុងបន្ទប់ ឬបើសិននៅខាងក្រៅបន្ទប់ ចូរជ្រើសរើស ឬកំណត់ទីតាំងខុសៗគ្នាចំនួន៣ ដូចជាដើមឈើ គុម្ពោត ឬផ្ទាំងថ្មដែលនៅក្បែរនោះ)។ លោកគ្រូ អ្នកគ្រូត្រូវប្រើប័ណ្ណទាំង៣ដែលសរសេរពាក្យ «ផ្ទាល់ខ្លួន «បន្ទាន់» និង«ឱកាសនាពេលអនាគត»ដើម្បីកំណត់ទីតាំងទាំង៣ឱ្យបានច្បាស់លាស់ដោយដាក់ប័ណ្ណ១នៅតាមទីកន្លែងនីមួយៗដែលបានកំណត់។

☞ ឱ្យសិស្សសម្រេចថា តើមូលហេតុណាមួយក្នុងចំណោមមូលហេតុសំខាន់ៗទាំង៣ដែលត្រូវសន្សំប្រាក់មានអាទិភាពខ្ពស់បំផុតរបស់ពួកគេ។ សិស្សម្នាក់ៗត្រូវជ្រើសរើសហេតុផលមួយហើយទៅឈរនៅទីតាំងដែលបានកំណត់សម្រាប់ហេតុផលនោះ។ ការសម្រេចចិត្ត និងការទៅឈរនៅទីកន្លែងសមស្របត្រូវធ្វើឡើងតែក្នុងរយៈពេល១៥វិនាទីប៉ុណ្ណោះ ដោយចាប់ផ្ដើមនៅពេលដែលលោកគ្រូ អ្នកគ្រូនិយាយពាក្យថា «ទៅ!»។

☞ ក្រុមនីមួយៗក្នុងចំណោមក្រុមទាំង៣(ដែលឈរនៅតាមទីតាំងនីមួយៗ)ត្រូវចំណាយពេល២នាទីដើម្បីពិភាក្សាពីអាទិភាពដែលពួកគេបានជ្រើសរើស និងមូលហេតុនៃការជ្រើសរើស។ (ចំណាំ ៖ ប្រសិនបើសិស្សទាំងអស់ជ្រើសរើសចំណុចសំខាន់តែ១ ឬ២ លោកគ្រូ អ្នកគ្រូត្រូវរកអ្នកស្ម័គ្រចិត្តឱ្យ «ជ្រើសរើស» ចំណុចសំខាន់ដែលពុំមានគេជ្រើសរើស ហើយសុំឱ្យពួកគេទៅកន្លែងដែលមិនមានចំនួនសិស្សគ្រប់គ្រាន់)។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

តើអ្វីជាហេតុផលល្អដែលត្រូវសន្សំប្រាក់?

- មិនមានចម្លើយដែលខុសនោះទេសម្រាប់សំណួរដែលសួរថា ៖ តើហេតុផលណាមួយក្នុង

ចំណោមហេតុផលទាំងនេះដែលមានសារៈសំខាន់បំផុត? ហេតុផលដែលត្រូវសន្សំប្រាក់ទាំងអស់សុទ្ធតែល្អ ហើយសារៈសំខាន់របស់វាគឺអាស្រ័យទៅលើតម្រូវការ និងការចង់បានរបស់បុគ្គលឬគ្រួសារនីមួយៗ។ កម្រិតនៃភាពសំខាន់ក៏អាចផ្លាស់ប្តូរទៅតាមពេលវេលាដែរ។ ជាក់ស្តែង វាអាចមានការលំបាកក្នុងការសន្សំប្រាក់សម្រាប់ហេតុផលទាំង៣នេះ។ ជូនកាលប្អូនត្រូវសម្រេចចិត្តចំពោះអ្វីដែលមានសារៈសំខាន់បំផុតសម្រាប់ប្អូន។ ដើម្បីធ្វើឱ្យដំណើរការនៃការសម្រេចចិត្តកាន់តែងាយស្រួលប្អូនអាចសួរខ្លួនឯងថា តើអ្វីដែលបន្ទាន់បំផុត បន្ទាប់មកសម្រេចចិត្តជ្រើសរើសអាទិភាពនៃការសន្សំប្រាក់របស់ប្អូន។ បុគ្គលខ្លះក៏អាចសួរខ្លួនឯងបានដែរថា តើតម្រូវការនៃការសន្សំប្រាក់របស់ពួកគេគឺសម្រាប់អ្វីមួយក្នុងពេលបច្ចុប្បន្ន ឬសម្រាប់ពេលវេលាដែលនឹងមកដល់ឆាប់ៗ ឬអនាគតវែងឆ្ងាយ?

- តើជំហានសំខាន់ៗមួយចំនួនក្នុងការសន្សំប្រាក់មានអ្វីខ្លះ?
  - ការសន្សំប្រាក់អាចជួយយើងក្នុងការចាប់ផ្តើមអាជីវកម្ម ឆ្លើយតបទៅនឹងគ្រោះអាសន្ន ឬទិញអ្វីមួយដែលយើងចង់បានខ្លាំង។ យើងក៏ដឹងដែរថា តើការសន្សំប្រាក់មានភាពលំបាកយ៉ាងណា? ដើម្បីធ្វើឱ្យវាកាន់តែមានភាពងាយស្រួល យើងអាចអនុវត្តតាមជំហានមួយចំនួនដូចខាងក្រោមដែលជួយយើងក្នុងការសន្សំប្រាក់ ៖

    ១) ជ្រើសរើសគោលដៅនៃការសន្សំប្រាក់

    ២) សន្សំប្រាក់ឱ្យបានទៀងទាត់(ទុកប្រាក់មួយចំនួនរបស់ប្អូនរៀងរាល់សប្តាហ៍ ឬខែ)

    ៣) សន្សំប្រាក់នៅកន្លែងដែលមានសុវត្ថិភាព (វាអាចជាការផ្ញើនៅមនុស្សចាស់ដែលប្អូនទុកចិត្ត ឬនៅធនាគារ)

- តើមានអ្វីកើតឡើង ប្រសិនបើក្មេងស្រីម្នាក់ត្រូវការប្រាក់ដើម្បីទិញរបស់ផ្សេងៗ ដូចជាតម្រូវការផ្ទាល់ខ្លួន ឬដើម្បីដោះស្រាយករណីបន្ទាន់ ប៉ុន្តែនាងមិនមានប្រាក់ផ្ទាល់ខ្លួនទេ?
  - ចម្លើយអាចមានភាពខុសគ្នាទូលំទូលាយ ដោយរាប់ចាប់ពី ៖ មិនទិញរបស់របរអ្វីទេ ឃ្លាន ឬធ្វើការដើម្បីរកប្រាក់ ឬសុំ ឬខ្ចីប្រាក់ពីអ្នកដទៃ។
  - នៅពេលដែលក្មេងស្រីត្រូវការប្រាក់ដើម្បីទិញរបស់ផ្ទាល់ខ្លួន ជួយក្រុមគ្រួសារលើការចំណាយម្ហូបអាហារ ឬឈ្នួលផ្ទះ ឬដោះស្រាយគ្រោះអាសន្នដែលអាចកើតមាន ពួកគេជួនកាលអាចនឹងរកវិធីផ្សេងដើម្បីទទួលបានប្រាក់នោះ ប្រសិនបើពួកគេមិនមានប្រាក់សន្សំផ្ទាល់ខ្លួនគ្រប់គ្រាន់ទេ។ ពេលខ្លះ សម្រាប់មនុស្សវ័យក្មេងមួយចំនួន ពួកគេនឹងទៅរកមនុស្សផ្សេងៗដូចជា អ្នកលក់ ឬអ្នកផ្សេងទៀតដើម្បីសុំខ្ចីប្រាក់ ឬសុំសងប្រាក់នៅពេលក្រោយសម្រាប់របស់ដែលត្រូវការពេលនេះ (ឥណទាន)។ នៅក្នុងស្ថានភាពទាំងនេះ មនុស្សមួយចំនួន(បុរស)អាចបញ្ចុះបញ្ចូលគំនិតទាក់ទងនឹងផ្លូវភេទដែលជាផ្នែកមួយនៃការចរចារ ៖ ដោយផ្តល់ប្រាក់ ឬឥណទានជាថ្នូរនឹងផ្លូវភេទ។ ករណីនេះអាចកើតឡើងនៅគ្រប់ទីកន្លែង និងពេលវេលា ឬអាចរំពឹងទុកថានឹងកើតឡើងនៅពេលក្រោយ។ ចំណុចនេះគឺជា

ស្ថានភាពដ៏គ្រោះថ្នាក់មួយសម្រាប់មនុស្សវ័យក្មេង។ ក្នុងករណីបែបនេះ បើទោះបីជាបុគ្គលម្ខាងទៀតជាអ្នកខុស (ហើយក៏មានច្បាប់ប្រឆាំងនឹងអាកប្បកិរិយា និងសកម្មភាពបែបនេះ) ក៏ដោយ ក៏វានៅតែជាហានិភ័យដ៏ធំមួយដដែល។ វាអាចនឹងមានការលំបាកក្នុងការបដិសេធចំពោះមនុស្សម្នាក់នៅពេលដែលយើងមានអារម្មណ៍ថាអ្នកជំពាក់គេ។ ហេតុផលដ៏សំខាន់មួយក្នុងការសន្សំប្រាក់គឺសម្រាប់ពេលដែលមានតម្រូវការផ្សេងៗដូចជា ៖ តម្រូវការរបស់របរផ្ទាល់ខ្លួន ការប្រើប្រាស់នាពេលអនាគត ឬករណីបន្ទាន់។ នៅពេលដែលយើងមានប្រាក់ យើងអាចប្រើប្រាស់ប្រាក់ផ្ទាល់របស់យើងជាជាងការបណ្ដោយខ្លួនចូលទៅក្នុងស្ថានភាពដ៏គ្រោះថ្នាក់ដើម្បីទទួលបានប្រាក់។ យើងនឹងនិយាយពីបញ្ហានេះបន្ថែមទៀតនៅក្នុងមេរៀនបន្ទាប់។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- និយាយពីជម្រើសនៃការប្រើសេវាធនាគារក្រោយពីសួរសិស្សរួចហើយថា តើគេដឹងអំពីសេវាធនាគារ គណនីធនាគារ ។ល។ ឬមិននិយាយពីរឿងនេះទេ ប្រសិនបើសិស្សហាក់ដូចជាមានវ័យក្មេងពេកក្នុងការពិភាក្សាពីសេវាកម្មធនាគារ។ វាជាការល្អក្នុងការសិក្សាស្វែងយល់ពីចំណុចនេះមុនពេលឈានដល់ដំណាក់កាលនៃការពិភាក្សា។
- សិស្សអាចមានកម្រិតនៃការយល់ដឹងខុសៗគ្នាយ៉ាងទូលំទូលាយទាក់ទងនឹងប្រាក់ ហិរញ្ញវត្ថុ និងការសន្សំប្រាក់ ដោយអាស្រ័យលើមជ្ឈដ្ឋានដែលពួកគេរស់នៅ។ ចំណុចនេះក៏អាចជាប្រធានបទមួយដែលពិបាក ព្រមទាំងត្រូវដោះស្រាយឱ្យបានហ្មត់ចត់ដែរ។ ទន្ទឹមគ្នានេះដែរ សកម្មភាពនេះគឺជាមធ្យោបាយដ៏ល្អមួយក្នុងការណែនាំសិស្សឱ្យដឹងពីភាពឯករាជ្យផ្នែកហិរញ្ញវត្ថុដែលជាទិដ្ឋភាពសំខាន់មួយនៃជីវិត។

# មេរៀនទី៧ ៖ តើ ស៊ីណារតន៍ត្រូវធ្វើអ្វី?[៧]

🕒 **រយៈពេល** ៖ ១ ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីយល់ពីរបៀបដែលបំណិន(ជំនាញ)សំខាន់ៗមួយចំនួនជួយយើងឱ្យសម្រេចបាននូវបំណងប្រាថ្នារបស់យើង។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

☞ សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្ដារខៀន និងដីស ឯកសារចែកជូនទី៧ ៖ «ឥឡូវ មិត្តទាំង១០នាក់» (សិស្សម្នាក់១ច្បាប់) សាច់រឿងចំនួន៤ឈុត ដែលឈុតនីមួយៗដកស្រង់ចេញពីឧបសម្ព័ន្ធទី៣ ៖ សាច់រឿងនេះត្រូវថតចម្លង ឬសរសេរទុកជាមុន។

☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន** ៖

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ ថតចម្លងឯកសារចែកជូនទី៧ និងឧបសម្ព័ន្ធទី៣ ដើម្បីចែកសិស្ស និងធ្វើការពិភាក្សា។

☞ អាន និងសិក្សាពីក្របខ័ណ្ឌចំណេះដឹងនៃមេរៀនដើម្បីជាជំនួយបន្ថែមដល់ការបង្រៀន។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ គោលដៅរបស់សកម្មភាពនេះ គឺដើម្បីយល់ពីរបៀបនៃបំណិនផ្សេងៗដែលបានសិក្សានៅក្នុងសកម្មភាពមុនៗអាចផ្ដល់ផលប្រយោជន៍ចំពោះយើងក្នុងស្ថានភាពខុសៗគ្នា។ បំណិនទាំងនេះរួមមានការធ្វើសេចក្ដីសម្រេចចិត្ត ការចរចា ការចាត់អាទិភាព និងការគ្រប់គ្រងពេលវេលា ដែលសុទ្ធតែជាជំនាញសំខាន់ៗទាំងអស់ក្នុងការជួយនាំផ្លូវយើងក្នុងស្ថានភាពផ្សេងៗនៅក្នុងជីវិត។

☞ បែងចែកសិស្សជា ៤ ក្រុម។

☞ ឱ្យសាច់រឿងមួយឈុតៗដល់ក្រុមនីមួយៗ ហើយឱ្យពួកគេអានរឿងនោះជាមួយគ្នាដោយយក

---

[៧] ICRW (២០១៥) *ការធ្វើផែនការជាមុនសម្រាប់ផ្ដល់ភាពអង់អាច និងសមត្ថភាពធ្វើការរបស់ក្មេងស្រី, (PAGE)*, មូលនិធិ McArthur, ទីក្រុងញ៉ូវ ដេលី។

ចិត្តទុកដាក់ (សូមមើលឧបសម្ព័ន្ធទី ៣)។

☞ ដោយផ្អែកលើសាច់រឿង ក្រុមនីមួយៗត្រូវ ៖

- ☝ ពិភាក្សាពីស្ថានភាព និងកំណត់ពីទ្វេរគ្រោះ ឬបញ្ហាដែលត្រូវដោះស្រាយ។
- ☝ ពិភាក្សាលម្អិតពីការសម្រេចចិត្តរបស់ក្មេងស្រីនៅក្នុងសាច់រឿង ដែលត្រូវតែធ្វើការសម្រេចចិត្ត ដោយរាប់បញ្ចូលទាំងដំណើរការ បំណិន និងជំហានដែលពាក់ព័ន្ធនឹងការធ្វើសេចក្ដីសម្រេចចិត្តនោះ។
- ☝ ពិភាក្សាពីជម្រើសផ្សេងៗឱ្យបានច្រើនតាមដែលអាចធ្វើបាន និងគិតពីផលវិបាក ឬលទ្ធផលនៃការសម្រេចចិត្តនីមួយៗ។
- ☝ រៀបចំបទបង្ហាញខ្លីមួយពីចំណុចសម្រាប់ការពិភាក្សាសំខាន់ៗដែលនឹងត្រូវបង្ហាញទៅសិស្សទាំងអស់។ បទបង្ហាញត្រូវឆ្លើយទៅសំណួរចំនួន៣ខាងក្រោម ៖
  ១. តើមានទ្វេគ្រោះអ្វីខ្លះនៅក្នុងសាច់រឿងដែលគេផ្ដល់ឱ្យ?
  ២. ផ្អែកលើសាច់រឿងដែលគេផ្ដល់ឱ្យ តើការសម្រេចចិត្តអ្វីដែលស៊ីណារតន៍ត្រូវធ្វើមុនគេ?
  ៣. ហេតុអ្វីបានជានាងត្រូវជ្រើសរើសយកការសម្រេចចិត្តមួយនោះ? តើការសម្រេចចិត្តរបស់នាងត្រូវផ្អែកលើមូលដ្ឋានអ្វី?

☞ ទុកពេល១៥នាទី ឱ្យក្រុមទាំងអស់បញ្ចប់ការងារនេះ បន្ទាប់មកក្រុមនីមួយៗត្រូវធ្វើបទបង្ហាញទៅកាន់ក្រុមធំ។

☞ បន្ទាប់ពីក្រុមទាំងអស់ធ្វើបទបង្ហាញហើយ ចូរសម្របសម្រួលឱ្យមានការពិភាក្សាជាក្រុមដោយផ្អែកលើសាច់រឿង។ ចែកឯកសារចែកជូនទី៧ ៖ «ឥឡូវ មិត្តទាំង១០នាក់» ដល់សិស្សទាំងអស់ដើម្បីទុកជាឯកសារយោងក្នុងពេលពិភាក្សា និងយកទៅផ្ទះ។ ការពិភាក្សានេះគួរតែបញ្ចូលការពិនិត្យមើលឡើងវិញលើទស្សនៈនៃ «មិត្តទាំង៥នាក់» ដែលដកស្រង់ចេញពីសកម្មភាពនៃការកំណត់គោលដៅក៏ដូចជាការណែនាំឱ្យស្គាល់មិត្តភក្តិ«ថ្មី» ចំនួន៥នាក់ដើម្បីឱ្យបាន «មិត្តទាំង១០» ។

## ៣. ការពង្រឹងចំណេះដឹង

**🗣 ចំណុចសម្រាប់ការពិភាក្សា ៖**

- ⟐ តើសិស្សមានអារម្មណ៍ដូចម្ដេចនៅពេលកំពុងអនុវត្តសកម្មភាពនេះ?
- ⟐ តើយុទ្ធសាស្ត្រខុសៗគ្នាមានអ្វីខ្លះដែលគេប្រើប្រាស់រហូតឈានដល់ការសម្រេចចិត្ត ឬដំណោះស្រាយមួយចំពោះបញ្ហាដែលកំពុងកើតឡើង? តើមាននរណាម្នាក់គិតឃើញពីបំណិនណាមួយដែលបានពិភាក្សាកាលពីពេលមុន ដែលគេអាចអនុវត្តបាននៅទីនេះដែរឬទេ? តើមានបំណិនណាខ្លះ?

- តើការគ្រប់គ្រងពេលវេលាដើរតួនាទីមួយសម្រាប់ករណីណាមួយក្នុងចំណោមករណីទាំងនេះដែរឬទេ?
  - មនុស្សម្នាក់អាចព្យាយាមព្យាករណ៍ និងត្រៀមខ្លួនសម្រាប់រឿងផ្សេងៗដែលកើតឡើងជាយថាហេតុ ជាពិសេសប្រសិនបើនរណាម្នាក់ដឹងថា លទ្ធភាពនៃព្រឹត្តិការណ៍បែបនោះអាចកើតឡើងជាញឹកញាប់នៅក្នុងគ្រួសាររបស់ខ្លួន។ ក្នុងករណីឈុតទី១ ប្រសិនបើស៊ីណារតន៍ដឹងថា ភ្ញៀវមកលេងផ្ទះរបស់នាងជាញឹកញាប់ ពេលនោះនាងអាចគិតស្មានពីរឿងនេះ និងត្រៀមចិត្តសម្រាប់ការមកលេងនោះជាមុន។ ដោយសារតែគេផ្តល់កាលបរិច្ឆេទប្រឡងឱ្យសិស្សដឹងជាមុន នាងអាចត្រៀមខ្លួនសម្រាប់ការប្រឡងរបស់នាងដោយសិក្សាជាប្រចាំតាមដែលអាចធ្វើទៅបាន។ ម៉្យាងទៀត ដោយសារតែភ្ញៀវមកលេងជាញឹកញាប់ នាងក៏អាចត្រៀមចិត្តដោយខ្លួនឯងដើម្បីបែងចែកពេលវេលាខ្លះសម្រាប់ការងារផ្ទះដែលត្រូវធ្វើនៅពេលភ្ញៀវមកលេង។ ទាក់ទងនឹងការគ្រប់គ្រងពេលវេលា ស៊ីណារតន៍ អាចពិភាក្សាពីកិច្ចការទាំងនេះជាមួយម្តាយរបស់នាង និងត្រូវប្រាកដថានាងបញ្ចប់កិច្ចការទាំងអស់ក្នុងរយៈពេលប្រហែលជា១ម៉ោងដើម្បីឱ្យនាងអាចមានពេលវេលានៅសល់ដើម្បីសិក្សា។
- តើការកំណត់អាទិភាព(ការចាត់អាទិភាព)ជាកត្តាដែលអាចកើតមានក្នុងករណីទាំងនេះដែរឬទេ?
  - មានពេលជាច្រើនដែលគេរំពឹងទុកថាក្មេងស្រីត្រូវចូលរួមទទួលភ្ញៀវដែលមកលេងផ្ទះរបស់ពួកគេ ឬធ្វើកិច្ចការផ្ទះប្រចាំថ្ងៃ ដែលធ្វើឱ្យប៉ះពាល់ដល់អាទិភាពផ្ទាល់ខ្លួនរបស់នាង។ វាមានសារៈសំខាន់ណាស់សម្រាប់ស៊ីណារតន៍ក្នុងការនិយាយជាមួយម្តាយ ឬបងរបស់នាងពីមូលហេតុដែលមានសារៈសំខាន់សម្រាប់នាងក្នុងការធ្វើអ្វីមួយដែលនាងចូលចិត្តក្នុងពេលដែលនាងកំពុងយកចិត្តទុកដាក់លើការទទួលខុសត្រូវរបស់នាងនៅក្នុងផ្ទះដែរ។ ក្នុងពេលជាមួយគ្នានេះដែរ នាងអាចចាប់ផ្តើមនិយាយជាមួយបងប្រុសរបស់នាងឱ្យជួយនាង ដូច្នេះនាងមានពេលធ្វើអ្វីដែលនាងចង់ធ្វើ ហើយបងប្រុសនាងក៏អាចធ្វើដូច្នោះដែរ។ នៅក្នុងឈុតនេះ នៅពេលដែលស៊ីណារតន៍ ត្រូវត្រៀមខ្លួនសម្រាប់ការប្រឡងរបស់នាង វាគួរតែជាអាទិភាពរបស់នាង។ នាងចាំបាច់ត្រូវនិយាយពីកិច្ចការនេះជាមួយជីដូន និងម្តាយរបស់នាង ហើយពន្យល់ពួកគាត់ពីមូលហេតុដែលវាមានសារៈសំខាន់សម្រាប់នាងក្នុងការសិក្សានៅដំណាក់កាលនេះ។ ការទទួលខុសត្រូវលើកិច្ចការផ្ទះគឺជាកិច្ចការរួម ហើយស៊ីណារតន៍ត្រូវមានលទ្ធភាពរៀបចំសកម្មភាពរបស់នាងបន្តិចម្តងៗនៅក្នុងគ្រួសារដោយពុំមានការមិនគោរពចំពោះនរណាម្នាក់ ឬធ្វើឱ្យប៉ះពាល់ដល់នរណាម្នាក់ឡើយ។
- តើការធ្វើសេចក្តីសម្រេចចិត្តរួមចំណែកចំពោះករណីទាំងនេះដោយរបៀបណា?
  - មនុស្សម្នាក់ៗត្រូវគិតដោយស្ងប់ស្ងាត់ គិតពីផលវិបាកផ្សេងៗ និងរបៀបដែលវាប៉ះពាល់ដល់គោលដៅ និងបំណងប្រាថ្នា (ការធ្វើសេចក្តីសម្រេចចិត្ត) របស់យើង។ នៅក្នុងឈុតទី២

គេត្រូវធ្វើការសម្រេចចិត្តបន្ទាប់ពីមានការគិតគូរពិចារណាល្អិតល្អន់ច្រើនដង។ ប្រសិនបើស៊ីណារតន៍ជ្រើសរើសការប្រើពាក្យសម្តីធ្ងន់ៗទៅលើក្រុមក្មេងប្រុសដែលកំពុងបៀតបៀនផ្លូវភេទរបស់នាងនៅតាមដងផ្លូវភ្លាមៗតែម្តង នាងអាចនឹងប្រឈមមុខនឹងការគំរាមកំហែងលើរាងកាយកាន់តែធំជាងមុនដោយសារតែពួកគេមានគ្នាច្រើន។ ដូច្នេះហើយ នាងអាចជ្រើសយកការត្រលប់ទៅផ្ទះឱ្យបានឆាប់រហ័ស។ ជំនួសឱ្យការប្រាប់ឪពុករបស់នាងភ្លាមៗនូវអ្វីដែលបានកើតឡើង នាងអាចទុកពេលវេលាឱ្យខ្លួនឯងដើម្បីឱ្យស្ងប់អារម្មណ៍ ទុកកាបូបរបស់នាង ឬញ៉ាំទឹកមួយកែវ ។ល។ ដើម្បី ឱ្យនាងអាចគិតយ៉ាងស្ងប់ស្ងាត់ និងច្បាស់លាស់ពីអ្វីដែលត្រូវនិយាយ និងពិចារណាពីផលវិបាកផ្សេងៗ ដោយសារតែវាអាចមានលទ្ធភាពដែលថាឪពុកនាងអាចឱ្យនាងឈប់រៀនព្រោះតែការបៀតបៀននេះ។ ដោយសារតែនាងចង់បន្តការសិក្សា ស៊ីណារតន៍អាចនិយាយដោយស្ងប់ស្ងាត់ជាមួយឪពុករបស់នាងថា នាងបានគិតពីសារៈសំខាន់នៃការមានអ្នកអមដំណើរនៅពេលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ។ ដោយផ្អែកលើការឆ្លើយតបរបស់ឪពុកនាង នាងអាចបន្ថែមដោយពិភាក្សាពីរបៀបដោះស្រាយការគំរាមកំហែងនេះសម្រាប់រយៈពេលវែង និងវិធានការអ្វីខ្លះដែលត្រូវអនុវត្ត។

- តើផ្នែកនៃការប្រាស្រ័យទាក់ទង និងការចរចាណាខ្លះដែលរួមចំណែកក្នុងករណីទាំងនេះ?
  - នៅក្នុងឈុតទី១ ស៊ីណារតន៍អាចខិតខំប្រឹងប្រែងបង្ហាញឱ្យបានច្បាស់ពីតម្រូវការរបស់នាង និងពេលវេលា ទីកន្លែង និងស្ថានភាពមួយដែលម្តាយរបស់នាងអាចមានការបើកទូលាយច្រើនក្នុងការស្តាប់នាង និងទទួលយកសំណើរបស់នាង។ ប្រសិនបើ ស៊ីណារតន៍ ស្រាប់តែខឹង ហើយមិនព្រមធ្វើកិច្ចការផ្ទះ ឪពុកម្តាយរបស់នាងអាចនឹងខឹងដូចគ្នាដែរ និងមានប្រតិកម្មតបវិញដោយមិនអនុញ្ញាតឱ្យនាងទៅសាលារៀន។ ស៊ីណារតន៍ អាចពិភាក្សារឿងនេះនៅពេលដែលបរិយាកាសអំណោយផល ដែលធ្វើឱ្យឪពុកម្តាយរបស់នាងស្តាប់នូវអ្វីដែលនាងត្រូវនិយាយ។
  - *ជាឧទាហរណ៍មួយទៀត* នៅក្នុងឈុតទី៣ ស៊ីណារតន៍ អាចរង់ចាំរហូតទាល់តែឪពុក ម្តាយរបស់នាងឈប់ឈ្លោះគ្នា និងរហូតទាល់តែមានភាពស្ងប់ស្ងាត់នៅក្នុងផ្ទះដូចធម្មតាវិញ។ នៅពេលដែលភាពស្ងប់ស្ងាត់ក្នុងគ្រួសារកើតឡើងវិញ នាងអាចស្នើសុំជួយធ្វើការងារជុំវិញផ្ទះ ឬរៀបចំទឹកតែជូនឪពុកម្តាយរបស់នាង ហើយបន្ទាប់មកនិយាយប្រាប់គាត់ពីការចុះឈ្មោះចូលហាត់របាំ។ នាងត្រូវវាយតម្លៃស្ថានភាព និងដោះស្រាយនូវការព្រួយបារម្ភនានាដែលឪពុកម្តាយរបស់នាងមាន ដែលក្នុងករណីនេះពួកគាត់ប្រហែលជាព្រួយបារម្ភពីសុវត្ថិភាពរបស់នាង ប្រសិនបើនាងទៅតែម្នាក់ឯង ដូច្នេះនាងក៏អាចប្រាប់គាត់ថាមិត្តភក្តិរបស់នាងមួយចំនួនក៏ចូលរួមហាត់របាំជាមួយនាងដែរ ដែលនេះមានន័យថាពួកគេនឹងធ្វើដំណើររួមគ្នានៅពេលល្ងាច ហើយពួកគេនឹងមានសុវត្ថិភាពដោយសារមានគ្នាច្រើន។ នាងក៏អាច

លើកឡើងនូវជម្រើសបន្ថែមទៀត ដូចជាពួកគេនឹងធ្វើដំណើរតាមផ្លូវធំតែប៉ុណ្ណោះពេលត្រលប់មកផ្ទះវិញ មិនមែនតាមផ្លូវកាត់ទេ។ ដែលការធ្វើដំណើរនេះធ្វើឱ្យគេមានសុវត្ថិភាពជាងធ្វើដំណើរតាមផ្លូវកាត់ដែលស្ងាត់ ងងឹត ឬពុំមានពន្លឺភ្លើងច្បាស់។

- វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា បំណិនដែលបានរៀនពីមុនៗត្រូវបានគេប្រើប្រាស់ជាវិធីសាស្រ្ត(បច្ចេកទេស)ក្នុងឧទាហរណ៍ខាងលើ។ ហេតុដូច្នេះហើយ គេនឹងប្រើប្រាស់បំណិនផ្សេងៗរួមគ្នាកាន់តែញឹកញាប់ទៅតាមសកម្មភាពអ្វីដែលគេយល់ឃើញថាសមស្របបំផុតចំពោះបំណិនទាំងនោះ។

**គន្លឹះសម្រាប់គ្រូបង្រៀន**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- បើកចិត្តឱ្យទូលាយ និងមិនលម្អៀងចំពោះការឆ្លើយតបរបស់សិស្សដោយសារតែពុំមានការឆ្លើយតបដែលកំណត់ច្បាស់លាស់ថាអាចប្រើការបានក្នុងឈុតផ្សេងៗដែលគេផ្តល់ឱ្យទេ។
- ប្រុងប្រយ័ត្នក្នុងការចៀសវាងការវិនិច្ឆ័យផ្ទាល់ខ្លួននៅពេលកំពុងពិភាក្សាជាមួយក្រុម។
- ចូរចងចាំថា ទិដ្ឋភាពសំខាន់របស់លំហាត់នេះគឺសម្រាប់សិស្សក្នុងការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវបំណិនដែលពួកគេបានរៀនរហូតមកដល់ពេលនេះ។

**សារសំខាន់ៗ ៖**

- បំណិនខុសៗគ្នា ដូចជាការគ្រប់គ្រងពេលវេលា និងប្រាក់ ការកំណត់អាទិភាព ការធ្វើសេចក្តីសម្រេចចិត្ត ការប្រាស្រ័យទាក់ទង និងការចរចា គឺជាគន្លឹះក្នុងការសម្រេចគោលដៅនិងបំណងប្រាថ្នារបស់យើង។
- ការសម្រេចបំណងប្រាថ្នារបស់យើងភាគច្រើនស្ថិតនៅក្នុងដៃរបស់យើង ដោយមានការគាំទ្រពីអ្នកដទៃ និងធនធានមួយចំនួន។

ឧបសម្ព័ន្ធទី៣ ៖ សាច់រឿង(ឈុត)

**១. ប្រធានបទ ៖ ការទទួលខុសត្រូវក្នុងគេហដ្ឋាន និងការសិក្សា**

សុីណារតន៍ គឺជាសិស្សរៀននៅសាលាមធ្យមសិក្សាបឋមភូមិ។ ល្ងាចនេះ សុីណារតន៍ត្រលប់មកពីសាលារៀនវិញ។ នាងត្រូវខិតខំសិក្សាមុខវិជ្ជាគណិតវិទ្យានៅក្នុងសប្តាហ៍នេះ ព្រោះនាងត្រូវប្រឡងនៅថ្ងៃស្អែក។ នៅពេលដែលនាងមកដល់ផ្ទះភ្លាម នាងស្រូតរូតទៅបន្ទប់របស់នាងដើម្បីសិក្សា ចៃដន្យសាច់ញាតិរបស់នាងនឹងមកលេងផ្ទះនាងក្នុងពេលបន្តិចទៀត។ ពេលនោះ ជីដូន និងម្តាយរបស់នាងបានប្រាប់នាងឱ្យជួយធ្វើម្ហូបអាហារ និងសម្អាតផ្ទះ។ ទន្ទឹមគ្នានោះដែរ បងប្រុសរបស់នាងកំពុងលេងនៅវានហាលក្រៅផ្ទះ។ តើសុីណារតន៍គួរធ្វើយ៉ាងណា?

**២. ប្រធានបទ ៖ ការប្រឈមមុខនឹងការបៀតបៀន**

សុីណារតន៍ គឺជាសិស្សរៀននៅសាលាមធ្យមសិក្សាបឋមភូមិ។ ថ្ងៃមួយ នៅតាមផ្លូវត្រលប់ពីសាលាទៅផ្ទះវិញមានក្មេងប្រុសមួយក្រុមឈរក្បែរអ្នកលក់ការ៉េមបានស្រែកហៅនាង ហើយដើរតាមនាង។ ពួកគេបានប្រើពាក្យលេបខាយទាក់ទងនឹងផ្លូវភេទដើម្បីស្រែកដាក់នាង។ ដោយសារតែពួកគេមានគ្នាច្រើន ហើយមេឃក៏កំពុងតែចាប់ផ្តើមងងឹត នាងមិនបានឆ្លើយតបនឹងពួកគេទេ ផ្ទុយទៅវិញនាងដើរកាន់តែលឿនដើម្បីប្រញាប់ទៅដល់ផ្ទះ។ នាងទៅដល់ផ្ទះដោយមានសភាពភ័យខ្លាច និងច្របូកច្របល់។ នៅពេលនោះ ឪពុករបស់នាងនៅផ្ទះ ហើយសួរនាងថា មានរឿងអ្វីកើតឡើង។ តើ សុីណារតន៍ គួរឆ្លើយដូចម្តេច?

**៣. ប្រធានបទ៖ ការដើរលេង**

សុីណារតន៍ គឺជាសិស្សរៀននៅសាលាមធ្យមសិក្សាបឋមភូមិ។ ថ្នាក់ហាត់របាំ និងល្ខោនទើបតែចាប់ផ្តើមមាននៅសាលារៀនរបស់នាង។ ថ្នាក់នេះនឹងចាប់បង្រៀនពីម៉ោង៦ល្ងាចដល់ម៉ោង ៨ យប់ ជារៀងរាល់ថ្ងៃ។ សុីណារតន៍ ចាប់អារម្មណ៍ក្នុងការចុះឈ្មោះរៀនថ្នាក់នេះយ៉ាងខ្លាំង ប៉ុន្តែក្រុមគ្រួសាររបស់នាងមិនអនុញ្ញាតឱ្យនាងនៅក្រៅផ្ទះក្រោយម៉ោង ៧ យប់ទេ។ ថ្ងៃនោះ សុីណារតន៍ ត្រលប់ទៅផ្ទះវិញជាមួយនឹងពាក្យសុំចុះឈ្មោះចូលរៀន។ ប៉ុន្តែនៅពេលដែលនាងចូលដល់ក្នុងផ្ទះ នាងក៏ឃើញថាម្តាយ និងឪពុករបស់នាងទើបតែឈ្លោះគ្នា ហើយបរិយាកាសក្នុងផ្ទះកំពុងតែមានភាពតានតឹង។ សុីណារតន៍ មិនប្រាកដថាតើនាងគួរនិយាយពីថ្នាក់ហាត់របាំ និងល្ខោនក្នុងស្ថានភាពបែបនេះ ឬយ៉ាងណាទេ ប៉ុន្តែនាងពិតជាចង់ចុះឈ្មោះចូលរៀនខ្លាំងណាស់ ហើយកាលបរិច្ឆេទចុងក្រោយសម្រាប់ការចុះឈ្មោះនេះគឺនៅសល់តែមួយថ្ងៃទៀតប៉ុណ្ណោះ។ តើសុីណារតន៍គួរធ្វើយ៉ាងណា?

**៨. ប្រធានបទ ៖ ថ្នាក់ឧត្តមសិក្សា**

ស៊ីណារតន៍ គឺជាសិស្សរៀននៅសាលាមធ្យមសិក្សាបឋមភូមិ។ នាងគឺជាក្មេងឆ្លាត ហើយចង់ក្លាយជាអ្នកវិទ្យាសាស្រ្ត។ នាងចង់បន្តការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ នៅមហាវិទ្យាល័យទូទៅមួយ។ ប៉ុន្តែឪពុកម្តាយរបស់នាងបានប្រាប់នាងជាច្រើនលើករួចមកហើយថា ក្មេងស្រីនៅក្នុងគ្រួសាររបស់ពួកគេត្រូវរៀបការនៅវ័យក្មេងដែលមានអាយុចន្លោះពី ១៥ ទៅ ១៧ ឆ្នាំ ហើយឪពុកម្តាយរបស់នាងកំពុងស្វែងរកដៃគូដែលស័ក្តិសមសម្រាប់នាង។ ក្រៅពីនេះចាស់ៗនៅក្នុងគ្រួសារនេះមិនអនុញ្ញាតឱ្យក្មេងស្រីទៅណាឆ្ងាយដូចជាការចូលទៅទីក្រុងដើម្បីសិក្សានៅមហាវិទ្យាល័យទូទៅឡើយ។ ទោះជាយ៉ាងនេះក្តី ស៊ីណារតន៍ ប្រាកដក្នុងចិត្តថានាងចង់សិក្សាបន្ថែម ហើយមិនចង់រៀបការមុននាងមានអាយុ ២៥ឆ្នាំទេ។ តើ ស៊ីណារតន៍គួរធ្វើយ៉ាងណា?

**ឯកសារចែកជូនទី៧ ៖ ឥឡូវ មិត្តទាំង១០នាក់!**

យើងត្រូវការបំណិនចម្រុះដើម្បីដោះស្រាយបញ្ហាជីវិតប្រចាំថ្ងៃ ក៏ដូចជាដើម្បីសម្រេចបាននូវគោលដៅ និងបំណងប្រាថ្នាជាក់លាក់នានា។ នៅក្នុងមេរៀនស្តីពីការកំណត់គោលដៅ យើងបាននិយាយពីមិត្តទាំង៥ ៖

- **ហេតុអ្វី?** ហេតុផលសម្រាប់ការធ្វើការឆ្ពោះទៅរកគោលដៅមួយ។
- **នរណា?** អ្នកដែលនឹងអនុវត្តផែនការ។
- **របៀបណា?** សកម្មភាពជាជំហានៗដែលចាំបាច់។
- **ពេលណា?** ពេលវេលាដែលជំហាននីមួយៗត្រូវបានអនុវត្ត និងគោលដៅដែលត្រូវសម្រេចឱ្យបាន។
- **អ្វី?** ធនធានដែលត្រូវការដើម្បីសម្រេចគោលដៅ។




ឥឡូវនេះយើងណែនាំមិត្តចំនួន៥នាក់បន្ថែមទៀតដែលជួយយើងឱ្យសម្រេចបានគោលដៅរបស់យើង។ មិត្តទាំង៥នាក់នេះផ្តល់ភាពក្លាហានដល់យើងនូវបំណិនផ្សេងៗ ដើម្បីបំពេញបំណងប្រាថ្នារបស់យើង ៖

- ការកំណត់អាទិភាព
- ការគ្រប់គ្រងពេលវេលា
- ការគ្រប់គ្រងប្រាក់កាស
- ការធ្វើសេចក្តីសម្រេចចិត្ត
- ការប្រាស្រ័យទាក់ទង និងការចរចា




- តើយើងរៀនអ្វីខ្លះពីរឿងនេះ?

*ការសម្រេចបំណងប្រាថ្នារបស់យើងគឺស្ថិតនៅក្នុងដៃរបស់យើង!*

ខណៈពេលដែលដៃម្ខាងនិយាយពីវិធីកំណត់គោលដៅ ដៃម្ខាងទៀតនិយាយពីរបៀបសម្រេចគោលដៅទាំងនោះ។ ការអនុវត្តជំនាញទាំងនេះនឹងនាំយើងឆ្ពោះទៅរកការសម្រេចបំណងប្រាថ្នារបស់យើង។ ដូច្នេះហើយ ភាពជោគជ័យរបស់យើងភាគច្រើនអាស្រ័យលើខ្លួនយើងផ្ទាល់ និងអាស្រ័យលើឥទ្ធិពលរបស់ **មិត្តទាំងដប់** របស់យើង។

### ក្របខណ្ឌចំណេះដឹង

#### តើការកំណត់អាទិភាពជាអ្វី? ហេតុអ្វីបានជាវាមានសារៈសំខាន់?

ការកំណត់អាទិភាព គឺជាការអនុវត្តការជ្រើសរើសអ្វីដែលត្រូវធ្វើ និងពេលដែលត្រូវធ្វើ។ ដើម្បីកំណត់អាទិភាពឱ្យមានប្រសិទ្ធិភាព យើងត្រូវមានលទ្ធភាពស្គាល់អ្វីដែលសំខាន់ និងមើលឃើញពីភាពខុសគ្នារវាង «សំខាន់» និង «បន្ទាន់»។ មិនមែនគ្រប់កិច្ចការទាំងអស់សុទ្ធតែសំខាន់ដូចគ្នាទេ។ លើសពីនេះទៅទៀត កិច្ចការដូចគ្នាអាចមានភាពខុសគ្នាចំពោះភាពបន្ទាន់ពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើឱ្យការកំណត់អាទិភាពមានសារៈសំខាន់។

**កិច្ចការសំខាន់** ៖ គឺទាក់ទងនឹងគោលដៅនៃជីវិតរបស់មនុស្សម្នាក់ដែលជាទូទៅវាមានលក្ខណៈសម្រាប់រយៈពេលវែង និងជាយុទ្ធសាស្ត្រចំពោះ សុខភាព និងសុខុមាលភាព ភាពសំខាន់ និងទាក់ទងនឹងផលិតភាពខ្ពស់។ ឧទាហរណ៍ ៖ សុខភាព ការសន្សំប្រាក់ និងការអប់រំ។

**កិច្ចការបន្ទាន់** ៖ គឺពាក់ព័ន្ធនឹងកត្តាពេលវេលា ពោលគឺ ជាទូទៅគឺជាការប្តេជ្ញាចិត្តសម្រាប់រយៈពេលខ្លី បន្ទាន់ជានិច្ច ពឹងផ្អែកច្រើនទៅលើកាលបរិច្ឆេទកំណត់ជាក់លាក់ និងអាចសំខាន់ឬមិនសំខាន់។ ឧទាហរណ៍ ៖ ការមើលថែឪពុកម្តាយ ឬកូនឈឺ ការទូទាត់ការចំណាយផ្សេងៗ ការមានភ្ញៀវមកផ្ទះភ្លាមៗ។

ការកំណត់អាទិភាពមានសារៈសំខាន់ជាពិសេសនៅពេលដែលពេលវេលាមានកំណត់ ហើយតម្រូវការហាក់ដូចជាគ្មានដែនកំណត់។ វាជួយយើងក្នុងការបែងចែកពេលវេលានៅពេលដែលត្រូវការចាំបាច់បំផុត ហើយប្រើវាដោយភាពឆ្លាតវៃបំផុត។ ដោយមានការកំណត់អាទិភាពបានល្អ យើងអាចគ្រប់គ្រងលើភាពអាសន្ន កាត់បន្ថយភាពតានតឹងធ្ងន់ធ្ងរ ប្រើប្រាស់ពេលវេលាដើម្បីសម្រេចគោលដៅជីវិត និងសម្រេចបានលទ្ធផលខ្ពស់ចំពោះការវិនិយោគពេលវេលា។

### ការគ្រប់គ្រងសាច់ប្រាក់ ៖ ការអប់រំផ្នែកហិរញ្ញវត្ថុសម្រាប់ក្មេងស្រីជំទង់ និងស្ត្រីវ័យក្មេង

ក្មេងស្រីជំទង់ និងស្ត្រីវ័យក្មេងឈរនៅមាត់ច្រកនៃភាពពេញវ័យ និងអនាគតដែលពោរពេញដោយការទទួលខុសត្រូវ។ តាមធម្មតាគេមើលឃើញខ្លួនឯងថានៅជាប់គាំងនៅចន្លោះរវាងការពឹងផ្អែកលើអ្នកមើលថែខ្លួនពីវ័យកុមារ និងភាពឯករាជ្យដែលគេប្រាថ្នាចង់បាននៅពេលពេញវ័យជំទង់។ នេះគឺជាពេលវេលានៃការដកស្រង់បទពិសោធន៍ជាមួយនឹងទំនាក់ទំនងសង្គមថ្មីៗក៏ដូចជាចាប់ផ្តើមដឹង និងទទួលខុសត្រូវលើផ្នែកហិរញ្ញវត្ថុ។ ពេលវេលាដ៏ច្របូកច្របល់ ក៏ជារយៈពេលមួយនៃការរៀបចំទទួលយកតួនាទីផ្នែកសេដ្ឋកិច្ចដែលយុវវ័យនឹងទទួលយកក្នុងនាមជាមនុស្សពេញវ័យ។ ការរៀនសូត្រពីរបៀបគ្រប់គ្រងប្រាក់ និងស្វែងរក

ទ្រព្យសម្បត្តិមានសារៈសំខាន់ណាស់ចំពោះការលូតលាស់ និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ព្រមទាំងលទ្ធភាពចាប់យកឱកាសដែលមាន។

## ហេតុអ្វីបានជាការអប់រំផ្នែកហិរញ្ញវត្ថុមានសារៈសំខាន់ចំពោះក្មេងស្រីជំទង់ និងស្ត្រីវ័យក្មេង?

នៅកម្រិតមូលដ្ឋាន ការអប់រំផ្នែកហិរញ្ញវត្ថុផ្តោតលើទស្សនៈចំពោះប្រាក់កាស និងវិធីសាស្ត្រគ្រប់គ្រងវាឱ្យបានល្អ។ វាជួយលើកកម្ពស់ការសន្សំប្រាក់ទៀងទាត់ ការចំណាយដោយប្រុងប្រយ័ត្ន និងវិធីប្រើប្រាស់ធនធានឱ្យមានប្រយោជន៍បំផុត។ បំណិនទាំងនេះគឺជាគ្រឹះដ៏សំខាន់សម្រាប់ក្មេងស្រី និងស្ត្រីវ័យក្មេងដែលកំពុងផ្លាស់ប្តូរពីភាពជាអ្នកពឹងផ្អែកលើអ្នកដទៃទៅជាអ្នកដើរតួ និងមានការទទួលខុសត្រូវដោយឯករាជ្យ។ យុវវ័យកំពុងប្រែប្រួលពីការពឹងផ្អែកលើក្រុមគ្រួសារទៅជាការរកប្រាក់ចំណូល និងធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុដោយឯករាជ្យ។ យុវវ័យត្រូវសិក្សាពីរបៀបគ្រប់គ្រងប្រាក់ ស្វែងរកឱកាសរកចំណូល រៀបចំផែនការ និងចំណាយសម្រាប់ការចាយវាយផ្សេងៗ ព្រមទាំងរៀបចំផែនការសម្រាប់អនាគត។ លើសពីនេះទៅទៀត យុវវ័យនឹងបានឃើញថា ការទទួលខុសត្រូវមានការកើនឡើង ដោយសារតែការរៀបចំក្នុងផ្ទះ អាពាហ៍ពិពាហ៍ កូនៗ ការងារ និងរបៀបរស់នៅ បានបង្កើននូវសម្ពាធដល់ពួកគេ។ ការអប់រំផ្នែកហិរញ្ញវត្ថុធ្វើឱ្យមនុស្សមានលទ្ធភាពគ្រប់គ្រង និងដោះស្រាយបញ្ហានេះបានយ៉ាងច្រើន។ ការគ្រប់គ្រងប្រាក់បានល្អអាចកាត់បន្ថយហានិភ័យមួយចំនួនក្នុងជីវិត និងពង្រឹងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់អនាគត។

# ជំពូកទី៣ ៖ ភាពជាអ្នកដឹកនាំ

## ទិដ្ឋភាពទូទៅ

ការប្រែប្រួលពីកុមារភាពទៅវ័យជំទង់គឺជាពេលវេលានៃជីវិតដែលមនុស្សវ័យក្មេងឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនទាំងផ្លូវកាយ និងផ្លូវចិត្ត។ ជាមួយនឹងការផ្លាស់ប្តូរទាំងនេះ ជាពិសេស ចំពោះក្មេងស្រីវ័យជំទង់ដែលជាញឹកញាប់ ត្រូវប្រឈមនឹងសម្ពាធនានានៅសាលារៀន រួមទាំងការងារផ្ទះ និងការទទួលខុសត្រូវក្នុងគ្រួសារ។ ត្រង់ចំណុចនេះ បន្ថែមទៅលើការស្គាល់ខ្លួនឯង និងការជឿជាក់លើខ្លួនឯងឱ្យកាន់តែច្បាស់ វាក៏មានសារៈសំខាន់ខ្លាំងណាស់ដែរសម្រាប់ក្មេងស្រីក្នុងការដឹង និងយល់ពីសក្តានុពលរបស់ពួកគេចំពោះភាពជាអ្នកដឹកនាំ។ តាមរយៈការប្រើប្រាស់សក្តានុពលនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ពួកគេអាចបង្កើតការផ្លាស់ប្តូរដែលចាំបាច់ដើម្បីប្រមូលយកទាំងការគាំទ្រ និងធនធានផ្សេងៗដែលពួកគេអាចនឹងមិនទទួលបានដោយសារតែភាពលម្អៀង និងការរើសអើងផ្នែកយេនឌ័រ។ ភាពជាអ្នកដឹកនាំគឺជាទស្សនៈមួយដែលគេអាចយកទៅប្រើប្រាស់នៅក្នុងបរិបទនៃជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ និងទំនាក់ទំនងនៅក្នុងផ្ទះ ក្រុមគ្រួសារ សាលារៀន និងក្រុមមិត្តភក្តិ។ ភាពជាអ្នកដឹកនាំអាចរីកចម្រើនឈានទៅដល់ការប្រាស្រ័យទាក់ទងជាសាធារណៈកាន់តែធំទូលាយនៅក្នុងសង្គម គ្រឹះស្ថានអប់រំ វិសាលភាពការងារ សហគមន៍ និងក្រុមដែលមានចំណាប់អារម្មណ៍។ នៅក្នុងមេរៀននេះ គេណែនាំពីភាពជាអ្នកដឹកនាំក្នុងលក្ខណៈជាទស្សនៈមួយដែលភ្ជាប់ជាមួយនឹងភាពជាក់ស្តែងដែលក្មេងស្រីជំទង់ និងស្ត្រីជាច្រើនជួបប្រទះនៅក្នុងបរិយាកាសសង្គមដែលពួកគេប្រហែលជាមិនត្រូវបានលើកឱ្យធ្វើជាអ្នកដឹកនាំប្រកបដោយសក្តានុពលភាពឡើយ។

🕘 រយៈពេល ៖ ៤៥ នាទី

❐ ចំនួនលំនាំបង្រៀនសរុប ៖ ១ មេរៀន

**វត្ថុបំណង ៖**

- ☺ ដើម្បីអភិវឌ្ឍការយល់ដឹងជាមូលដ្ឋានពីភាពជាអ្នកដឹកនាំ។
- ☺ ដើម្បីអាចទទួលស្គាល់លក្ខណៈសម្បត្តិភាពជាអ្នកដឹកនាំផ្ទាល់របស់នរណាម្នាក់ដែលមាន។

# មេរៀនទី៨ ៖ នរណាជាអ្នកដឹកនាំ[៨]

🕒 រយៈពេល ៖ ៤៥ នាទី

➲ វត្ថុបំណង ៖ ដើម្បីរៀនសូត្រធ្វើជាអ្នកដឹកនាំក្នុងជីវិតផ្ទាល់របស់ខ្លួន។

## ១. ការរៀបចំ

📖 សម្ភារៈដែលត្រូវការ ៖

☞ សម្រាប់គ្រូ៖ ក្ដារខៀន និងដីស ឬក្រដាសផ្ទាំងធំ និងហ្វឺត និងកូនបាល់ (បាល់ក្រដាស បាល់មូរពីស្រោមជើង ។ល។)

☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន ៖**

☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។

☞ អាន និងសិក្សាពីក្រខ័ណ្ឌចំណេះដឹងនៃមេរៀន។

☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។

☞ ប្រមូលធនធានចាំបាច់ទាំងអស់ផ្សេងៗទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្ដីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

☞ សរសេរចំណងជើងមេរៀន «នរណាជាអ្នកដឹកនាំ?» នៅលើក្ដារខៀន និងសុំឱ្យសិស្សចែករំលែកពីការជឿជាក់របស់ពួកគេថាតើមេរៀននេះនឹងផ្ដោតលើអ្វី។

☞ បន្ទាប់មក សុំឱ្យសិស្សម្នាក់ផ្ដល់ឧទាហរណ៍ផ្សេងៗរបស់អ្នកដឹកនាំណាម្នាក់ជាសាធារណៈ។ លោកគ្រូអ្នកគ្រូត្រូវកត់ឈ្មោះអ្នកដឹកនាំដែលសិស្សបានលើកឡើងនៅលើក្ដារខៀន (អ្នកដឹកនាំទាំងនោះអាចជាបុគ្គលនានាក្នុងប្រវត្តិសាស្ត្រ កីឡា សិល្បៈ វិទ្យាសាស្ត្រ ធុរកិច្ច ឬនយោបាយ ឬពីវិស័យផ្សេងៗទៀត)។

☞ បន្តសកម្មភាពដោយលេងល្បែងដែលមានឈ្មោះថា «បាល់អំណាច»។ ពន្យល់សិស្សថា អ្នកដែលមានបាល់អំណាចគឺជាអ្នកកាន់អំណាច។ លើសពីនេះទៅទៀត ត្រូវពន្យល់ថា ៖

---

[៨] ICRW(២០១៥) *ការធ្វើផែនការជាមុនសម្រាប់ការផ្ដល់ភាពអង់អាច និងការងារដល់ក្មេងស្រី (គេហទំព័រ)*, មូលនិធិ McArthur ទីក្រុងញូវដេលី

*កម្មវិធីសិក្សាការអភិវឌ្ឍយុវជនដែលមានការសម្របសម្រួល ។ សមាគមASPIRA* ។ ទាញយកនៅថ្ងៃ ១៥ ធ្នូ ២០១៦ ពី http://www.aspira.org/book/facilitated-youth-development-curriculum

- ☝ អ្នកកាន់អំណាចមានអំណាចក្នុងការនិយាយ។ បុគ្គលម្នាក់នេះត្រូវប្រាប់ឈ្មោះរបស់ខ្លួន និងនិយាយពីអ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់របស់គេ ឬនៅក្នុងសហគមន៍របស់គេ។ អ្នកកាន់អំណាចម្នាក់ៗត្រូវនិយាយពីគុណសម្បត្តិចំនួន២ចំណុចរបស់អ្នកដឹកនាំដែលគេបានជ្រើសរើស ហើយដែលគេគិតថាធ្វើឱ្យបុគ្គលនោះក្លាយជាអ្នកដឹកនាំ។ គេមានពេល២នាទីសម្រាប់រៀបរាប់។ មានតែអ្នកកាន់អំណាច ពោលគឺសិស្សដែលមានបាល់អំណាចក្នុងដៃក្នុងពេលណាមួយប៉ុណ្ណោះដែលអាចនិយាយបាន។
- ☝ អ្នកកាន់អំណាចមានសិទ្ធិសម្រេចចិត្តថាតើនរណាត្រូវនិយាយបន្ទាប់ ដោយបោះបាល់ទៅឱ្យអ្នកនោះ។ អ្នកកាន់អំណាចថ្មីត្រូវធ្វើរឿងដូចគ្នានេះ ៖ ប្រាប់ឈ្មោះរបស់ខ្លួន និងនិយាយពីអ្នកដឹកនាំម្នាក់ដែលគេបានស្គាល់ក្នុងជីវិត ឬសហគមន៍របស់គេ។ ល្បែងនេះចាប់ផ្ដើមដោយលោកគ្រូ អ្នកគ្រូ បោះបាល់អំណាចទៅឱ្យសិស្សណាម្នាក់ដែលក្លាយជាអ្នកកាន់អំណាចទី១។

☞ នៅពេលដែលអ្នកកាន់អំណាចម្នាក់ៗនិយាយ សូមកត់ពាក្យគន្លឹះៗដែលពួកគេបានលើកឡើងនៅលើក្ដារខៀនជាឧទាហរណ៍ផ្សេងៗស្ដីពីគុណសម្បត្តិរបស់អ្នកដឹកនាំ។ សិស្ស (អ្នកកាន់អំណាច) អាចនិយាយពីគុណសម្បត្តិដូចខាងក្រោម ៖

- ☝ អ្នកដឹកនាំរូបនេះស្ដាប់ និងយកគំនិត ឬយោបល់អ្នកដទៃទៅពិចារណា។
- ☝ អ្នកដឹកនាំដែលមានទឹកចិត្តគិតពីអ្នកដទៃ។
- ☝ អ្នកដឹកនាំដែលមានវោហារសព្ទ។

☞ គុណសម្បត្តិរបស់អ្នកដឹកនាំអាចមានដូចជា ភាពក្លាហាន ការដាក់ខ្លួន សុចរិត លក្ខណៈសម្បត្តិរឹងមាំ។ល។

☞ ក្រោយពីសិស្សពីរបីនាក់បាននិយាយរួចហើយ លោកគ្រូ អ្នកគ្រូអាចបញ្ចប់ល្បែងនេះបាន។

☞ ជំហានចុងក្រោយរបស់សកម្មភាពនេះគឺការពិភាក្សាជាក្រុម ដែលក្រុមទាំងមូលត្រូវចូលរួម និងពិភាក្សាគ្នាពីអ្នកដឹកនាំ និងគុណសម្បត្តិនៃភាពជាអ្នកដឹកនាំដោយផ្អែកលើកំណត់ត្រានៅលើក្ដារខៀន។ ការពិភាក្សានេះគួរទុកពេលខ្លះឱ្យសិស្សគិតពីគុណសម្បត្តិនៃភាពជាអ្នកដឹកនាំផ្ទាល់របស់ខ្លួនគេដែរ។

## ៣. ការពង្រឹងចំណេះដឹង

**🗣 ចំណុចសម្រាប់ការពិភាក្សា ៖**

◈ តើមនុស្សកើតមកដោយមានគុណសម្បត្តិនៃភាពជាអ្នកដឹកនាំទាំងនេះ ឬក៏ប្អូនគិតថាគេអាចអភិវឌ្ឍគុណសម្បត្តិទាំងនេះបាន?

- ☝ យើងទាំងអស់គ្នាមានគុណសម្បត្តិពិសេសខុសៗគ្នា។ អ្នកខ្លះអាចពូកែស្ដាប់ អ្នកខ្លះអាចពូកែនិយាយ ឬចរចា និងអ្នកខ្លះទៀតអាចពូកែសម្រុះសម្រួលរវាងមនុស្ស ការដោះស្រាយ

ទំនាស់តាមរយៈការពិភាក្សា។ល។ ឧទាហរណ៍នីមួយៗក្នុងចំណោមឧទាហរណ៍ទាំងនេះ អាចនាំឱ្យមនុស្សម្នាក់ក្លាយជាអ្នកដឹកនាំល្អនៅក្នុងក្រុមគ្រួសារ នៅសាលារៀន នៅកន្លែងធ្វើការ ឬសូម្បីតែនៅក្នុងស្ថានភាពជាក់លាក់មួយចំនួននៅក្នុងពេលវេលាជាក់ស្តែងនានា។

- តើនរណាម្នាក់ក៏អាចធ្វើជាអ្នកដឹកនាំបានដែរមែនទេ?
  - មែន! *គ្រប់គ្នាគឺជាអ្នកដឹកនាំ*។ មនុស្សម្នាក់ត្រូវឆ្លុះបញ្ចាំងពីគុណសម្បត្តិនៃភាពជាអ្នកដឹកនាំផ្ទាល់របស់ខ្លួន។ មនុស្សម្នាក់មិនចាំបាច់ទាល់តែមានក្រុម ឬមនុស្សសម្រាប់ដឹកនាំ *ដើម្បី*ក្លាយជាអ្នកដឹកនាំទេ។ ការមានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងស្វែងរកដំណោះស្រាយលើបញ្ហាប្រចាំថ្ងៃរបស់យើងក៏ជាអាកប្បកិរិយានៃភាពជាអ្នកដឹកនាំដែរ។ គេអាចបង្ហាញគុណសម្បត្តិនៃភាពជាអ្នកដឹកនាំនៅក្នុងជីវិតប្រចាំថ្ងៃរបស់គេបាន។

- តើប្អូនអាចឱ្យឧទាហរណ៍មួយពីពេលណាមួយក្នុងជីវិតផ្ទាល់របស់ប្អូនដែលប្អូនមានអារម្មណ៍ថាប្អូនបានបង្ហាញពីលក្ខណៈនៃភាពជាអ្នកដឹកនាំផ្ទាល់របស់ប្អូន ឬត្រូវបានគេប្រាប់ឱ្យទទួលខុសត្រូវ ឬដឹកនាំអ្វីមួយបានដែរឬទេ? តើមនុស្សម្នាក់ដឹងថាគេមានគុណសម្បត្តិជាអ្នកដឹកនាំដោយរបៀបណា?
  - អ្នកដឹកនាំល្អគឺពូកែក្នុងការកំណត់គោលដៅបានច្បាស់លាស់។ ពួកគេមានបំណិនទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពដែលធ្វើឱ្យពួកគេមានលទ្ធភាពបង្ហាញច្បាស់លាស់ពីតម្រូវការរបស់គេទៅកាន់អ្នកដទៃ ក៏ដូចជាយល់ពីតម្រូវការរបស់អ្នកនៅជុំវិញខ្លួនរបស់គេដែរ។ ចំណុចទាំងនេះគឺជាគុណសម្បត្តិដែលមនុស្សម្នាក់ៗអាចអភិវឌ្ឍបាន។ មនុស្សម្នាក់ៗនឹងត្រូវបង្ហាញពីទិដ្ឋភាពនៃភាពជាអ្នកដឹកនាំដែលមានសក្តានុពលភាពនៅក្នុងជីវិតផ្ទាល់របស់ពួកគេ ទោះជាតាមរយៈការទទួលខុសត្រូវ ឬតាមរយៈលទ្ធភាពចរចាជាមួយឪពុកម្តាយពីការទៅលេងផ្ទះមិត្តភក្តិ ។ល។ ដូច្នេះ រាល់ពេលដែលមនុស្សម្នាក់ជួបនឹងបញ្ហា ឬតម្រូវការក្នុងការចរចាពីអ្វីមួយជាមួយនរណាម្នាក់ អ្នកនោះគឺកំពុងប្រើប្រាស់ជំនាញភាពជាអ្នកដឹកនាំរបស់គេ។ មនុស្សម្នាក់នោះកំពុងក្លាយជាអ្នកទំនាក់ទំនង អ្នកចរចា និងអ្នកដោះស្រាយបញ្ហាយ៉ាងមានប្រសិទ្ធភាព។
- សុំឱ្យសិស្សមួយចំនួនចែករំលែកឧទាហរណ៍ផ្សេងៗពីគុណសម្បត្តិនៃភាពជាអ្នកដឹកនាំ ផ្ទាល់របស់គេ។
  - ឧទាហរណ៍ ៖
    - លទ្ធភាពដែលអាចគិតពីគោលដៅបច្ចុប្បន្ន (វាអាចពាក់ព័ន្ធនឹងការសិក្សា) អាចផ្តោតលើគោលដៅនោះ និងធ្វើផែនការដើម្បីសម្រេចវា
    - មានលទ្ធភាពក្នុងការប្រាប់ពីតម្រូវការរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពទៅកាន់គ្រួសារ មិត្តភក្តិ មិត្តរួមថ្នាក់ និងគ្រូបង្រៀន

- លទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តសម្រាប់ខ្លួនឯងតាមលទ្ធភាពដែលអាចធ្វើទៅបាន។
- គិតបានល្អិតល្អន់ពីរបៀបដែលគេចំណាយពេលវេលា និងប្រាក់កាស។

**គន្លឹះសម្រាប់គ្រូបង្រៀន**

- សិស្សភាគច្រើនអាចនឹងមិនសូវដឹងពីភាពជាអ្នកដឹកនាំដែលជាទស្សនៈទានរបស់អ្នកដែលនៅជិតខ្លួនឯង ឬផ្ទះទេ។ ដូច្នេះសម្រាប់ល្បែងបាល់អំណាចពួកគេអាចត្រូវការឧទាហរណ៍ផ្សេងៗដូចជា អ្នកដឹកនាំនៅក្នុងជីវិតផ្ទាល់របស់គេអាចជា ឪពុកម្តាយ បងប្អូនសមាជិកគ្រួសារ ឬមិត្តភក្តិដែលបានបង្ហាញពីភាពជាអ្នកដឹកនាំ អ្នកដឹកនាំនៅក្នុងសហគមន៍អាចជាអ្នកជិតខាង គ្រូបង្រៀន ឬអ្នកលក់ទំនិញដែលបានបង្ហាញពីគុណសម្បត្តិភាពជាអ្នកដឹកនាំមួយចំនួនជាសាធារណៈ ដូចជាការសម្អាត ឬការដាំដើមឈើ និងកិច្ចការផ្សេងៗទៀត។

**សារសំខាន់ៗ ៖**

- មនុស្សគ្រប់រូបមានសក្តានុពលក្នុងការក្លាយជាអ្នកដឹកនាំបាន។
- ភាពជាអ្នកដឹកនាំមិនមែនមានន័យត្រឹមតែការដឹកនាំអ្នកដទៃនោះទេ។ យើងគ្រប់គ្នាមានគុណសម្បត្តិមួយចំនួនដែលអាចក្លាយជាអ្នកដឹកនាំក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង។ លទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយបញ្ហានៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងក៏ជាបំណិនមួយនៃភាពជាអ្នកដឹកនាំដែរ។
- វាមានសារៈសំខាន់ក្នុងការទទួលស្គាល់នូវលក្ខណៈនៃភាពជាអ្នកដឹកនាំរបស់មនុស្សម្នាក់ៗ។ មនុស្សគ្រប់រូបមានសក្តានុពលដើម្បីអភិវឌ្ឍបំណិន និងគុណសម្បត្តិនៃភាពជាអ្នកដឹកនាំដែលមានដូចជា មានលទ្ធភាពក្នុងការកំណត់គោលដៅ និងរៀបចំផែនការដើម្បីសម្រេចគោលដៅនោះ បំណិនប្រាស្រ័យទាក់ទងល្អ និងមានទំនួលខុសត្រូវ។
- នៅពេលដែលមនុស្សម្នាក់បានដឹងពីលក្ខណៈទាំងនេះ គេអាចប្រើប្រាស់វាកាន់តែមានប្រសិទ្ធភាពថែមទៀត និងអភិវឌ្ឍវាបន្តទៀត។

**គ្របខ័ណ្ឌចំណេះដឹង**

- **ភាពជាអ្នកដឹកនាំ**មានន័យផ្សេងៗគ្នាសម្រាប់មនុស្សខុសៗគ្នានៅជុំវិញពិភពលោក ហើយវាក៏មានន័យផ្សេងៗគ្នាចំពោះស្ថានភាពខុសៗគ្នាដែរ។ ពាក្យនេះធ្វើឱ្យយើងគិតឃើញពីរូបភាពផ្សេងៗជាច្រើន។ ឧទាហរណ៍ ៖
    - អ្នកដឹកនាំនយោបាយ - ការថ្លែងសុន្ទរកថាប្រកបដោយថាមពល និងគួរឱ្យរំជួលចិត្ត។
    - អ្នកស្រាវជ្រាវរុករក - ត្រួសត្រាយផ្លូវនៅក្នុងព្រៃដើម្បីឱ្យសមាជិកក្រុមរបស់គាត់ដើរបាន។
    - អ្នកគ្រប់គ្រងប្រតិបត្តិដែលធ្វើការនៅក្នុងក្រុមហ៊ុន ឬអង្គការ ការដឹកនាំក្រុម។
    - អ្នកដឹកនាំសហគមន៍ដែលប្រមូលផ្តុំមនុស្សដើម្បីបុព្វហេតុរួមមួយ។

- **អ្នកដឹកនាំ**ផ្តល់លទ្ធភាពឱ្យខ្លួនឯង និងអ្នកដទៃឱ្យកំណត់គោលដៅ បង្កើតនូវទស្សនវិស័យដែលមានលក្ខណៈជំរុញទឹកចិត្ត និងជាញឹកញាប់បង្កើតនូវអ្វីដែលថ្មី។ ភាពជាអ្នកដឹកនាំគឺសំដៅលើការកំណត់ទិសដៅដែលគេត្រូវទៅដើម្បីសម្រេចគោលដៅជាក្រុម។ វាមានលក្ខណៈថាមវន្ត រំភើប និងជំរុញទឹកចិត្ត។ អ្នកដឹកនាំជួយក្រុមឱ្យមានវឌ្ឍនៈភាពដោយប្រើប្រាស់បំណិនគ្រប់គ្រងក្នុងការជំរុញ លើកទឹកចិត្ត និងដឹកនាំអ្នកដទៃ។
    - **គុណសម្បត្តិរបស់អ្នកដឹកនាំល្អ ៖**
    - **គុណសម្បត្តិផ្នែកអាកប្បកិរិយា**
        - មានការគោរព
        - មានគុណតម្លៃល្អ
        - មានការទទួលខុសត្រូវ
        - មានវិធីសាស្ត្រដែលអាចកែសម្រួល និងបត់បែនបាន
        - យល់ពីតម្រូវការរបស់ក្រុម
        - មានសមត្ថភាពក្នុងការផ្តោត កំណត់គោលដៅ និងរៀបចំផែនការ
        - អាចលើកទឹកចិត្ត និងដឹកនាំអ្នកដទៃ
        - ផ្តោតលើគោលដៅរួម
    - **គុណសម្បត្តិផ្នែកបំណិន**
        - ជាអ្នកប្រាស្រ័យទាក់ទងល្អ ៖ ជាអ្នកពូកែស្តាប់ និងជាអ្នកពូកែវោហារសព្ទ
        - មានបំណិនដោះស្រាយបញ្ហា
        - មានបំណិនទំនាក់ទំនងអន្តរបុគ្គល
        - មានបំណិនចរចា
        - កំណត់អាទិភាពគោលដៅ និងភារកិច្ច
        - មានទំនុកចិត្ត
        - មានការប្តេជ្ញាចិត្ត

# ជំពូកទី៤ ៖ សិទ្ធិមនុស្ស

## ទិដ្ឋភាពទូទៅ

យើងម្នាក់ៗគឺជាមនុស្ស ហើយយើងម្នាក់ៗសុទ្ធតែមានសិទ្ធិ។ សិទ្ធិមនុស្សជារបស់មនុស្សគ្រប់រូបទាំងអស់នៅគ្រប់ទីកន្លែង។ វាគឺជាសេរីភាព និងលក្ខខណ្ឌដែលមិនត្រូវបានរំលោភបំពាន ឬរឹបអូសដោយបុគ្គលដទៃ សូម្បីតែរដ្ឋាភិបាល ឬរដ្ឋក្តី។ វាគឺជាកាតព្វកិច្ចរបស់រដ្ឋាភិបាល និងប្រព័ន្ធច្បាប់នៃប្រទេសទាំងអស់ដែលត្រូវការពារ និងលើកកម្ពស់សិទ្ធិទាំងនេះ។ នៅក្នុងសកម្មភាពនេះ គេនឹងណែនាំសិស្សឱ្យស្គាល់នូវគំនិតស្តីពីសិទ្ធិមនុស្សជាមូលដ្ឋាន និងព្យាយាមកំណត់ យល់ និងបង្ហាញពីសិទ្ធិទាំងនេះមួយចំនួននៅក្នុងបរិបទជីវិតរបស់ពួកគេផ្ទាល់។

🕘 **រយៈពេល** ៖ ២ ម៉ោង

❐ **ចំនួនលំនាំបង្រៀនសរុប** ៖ ២ មេរៀន

🏆 **វត្ថុបំណង** ៖

☺ ដើម្បីបង្កើតការយល់ដឹងពីទស្សនៈទាននៃសិទ្ធិមនុស្ស។

☺ ដើម្បីយល់ដឹងពីរបៀបអនុវត្តសិទ្ធិទាំងនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

# មេរៀនទី៩ ៖ ការណែនាំពីសិទ្ធិមនុស្ស[៩]

🕒 **រយៈពេល ៖** ៤៥នាទី

➲ **វត្ថុបំណង ៖** ដើម្បីឱ្យយល់ដឹងពីទស្សនៈទាននៃសិទ្ធិមនុស្ស។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ៖**

- ☞ សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្តារខៀន និងដីស កន្ត្រៃ ប៊ិកគូសគំនូរ និងក្រដាសព័ត៌មាន(មានគ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗ)។
- ☞ សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន ៖**

- ☞ អានទិដ្ឋភាពទូទៅស្តីពី ជំពូកទី៤ ៖ សិទ្ធិមនុស្ស។
- ☞ អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ☞ សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ☞ ប្រមូលសម្ភារៈចាំបាច់ទាំងអស់ផ្សេងទៀត។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- ☞ សុំឱ្យសិស្សចែករំលែកពីការយល់ដឹងរបស់ពួកគេចំពោះពាក្យ «សិទ្ធិ» (ដែលបានសរសេរនៅលើក្តារខៀន) និងសរសេរពីចម្លើយរបស់សិស្សនៅលើក្តារខៀនផងដែរ។
- ☞ បែងចែកសិស្សជា៤ក្រុម និងចែកកន្ត្រៃ ប៊ិកគូររូប និងក្រដាសព័ត៌មានទៅឱ្យក្រុមនីមួយៗ។ ក្រុមនីមួយៗត្រូវប្រើសម្ភារៈទាំងនេះដើម្បីបង្កើតជាដើមឈើសិទ្ធិមនុស្ស។ ដើម្បីបង្កើតដើមឈើសិទ្ធិមនុស្សបាន សិស្សត្រូវគូរតួដើមឈើ បន្ទាប់មកគូរស្លឹកឈើ។ ស្លឹកឈើត្រូវគូរឱ្យបានធំល្មមដែលអាចសរសេរពាក្យបាន២-៣នៅក្នុងស្លឹកនីមួយៗ។ នៅលើស្លឹកនីមួយៗសមាជិកក្រុមត្រូវសរសេរឈ្មោះ ឬពាក្យគន្លឹះរបស់សិទ្ធិមួយដែលពួកគេគិតថាមានភាពចំបាច់សម្រាប់មនុស្សក្នុងការដឹកនាំជីវិតឱ្យប្រកបដោយគុណភាព ការគោរព និងសេចក្តីថ្លៃថ្នូរ។ ក្រុមទាំងអស់មានពេល ១៥នាទីដើម្បីគូរដើមឈើរបស់ពួកគេ។
- ☞ ក្រោយរយៈពេល ១៥នាទីបានបញ្ចប់ ក្រុមនីមួយៗត្រូវបង្ហាញដើមឈើរបស់ខ្លួនទៅកាន់ក្រុមធំ និងពន្យល់ពីអ្វីដែលពួកគេបានសរសេរ។

---

[៩] TARSHI (២០០៦)។ *មូលដ្ឋាន និងលើសពីនេះ, សៀវភៅណែនាំសម្រាប់គ្រូបង្គោល, «ការរួមបញ្ចូលបញ្ហាផ្លូវភេទ ផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិ»។* ទីក្រុងញូវដេលី។

☞ បញ្ចប់សកម្មភាពដោយការពិភាក្សា។

## ៣. ការពង្រឹងចំណេះដឹង

🗣 **ចំណុចសម្រាប់ការពិភាក្សា ៖**

- តើដើមឈើទាំងអស់មានចំណុចដែលស្រដៀងគ្នាដែរឬទេ? តើសិទ្ធិមួយចំនួនមានលក្ខណៈដូចគ្នាទៅនឹងដើមឈើសិទ្ធិមនុស្សលើសពីមួយ ឬដូចគ្នាទាំងអស់? ហេតុអ្វី? តើសិទ្ធិដែលដូចគ្នាទាំងនេះបង្ហាញពីអ្វីមួយដែលសហគមន៍ ប្រទេស និងរដ្ឋដែលយើងរស់ ឬតម្រូវការទូទៅរបស់យើងដែរឬទេ? តើវាមានភាពដូចគ្នាសម្រាប់ក្រុមដែលមកពីប្រទេស ឬតំបន់ផ្សេងគ្នាដែរឬទេ?
  - ☝ បាទ / ចាស ! មានសិទ្ធិមួយចំនួនដែលយើងបានឃើញនៅលើដើមឈើលើសពីមួយ។ មូលហេតុគឺដោយសារតែយើងភាគច្រើនជួបប្រទះបញ្ហាទាំងនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ហើយមានអារម្មណ៍ថា យើងគួរតែទទួលបានសិទ្ធិនេះដើម្បីអាចរស់នៅក្នុងជីវិតមួយដែលមានការគោរព និងភាពស្មើភាពគ្នា(សិទ្ធិដែលដូចគ្នាមួយចំនួនដែលគេអាចលើកឡើងមាន ៖ សិទ្ធិទទួលបានការអប់រំ សន្តិភាព គ្មានការរើសអើង សមភាពយេនឌ័រ ការលេងកម្សាន្ត អាហារ ទីជម្រក និងជីវិត)។ សិទ្ធិទាំងនេះបង្ហាញថា មនុស្សលោកជឿថាសិទ្ធិទាំងនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ការរស់នៅក្នុងជីវិតរបស់ពួកគេប្រកបដោយភាពថ្លៃថ្នូរនៅទូទាំងសហគមន៍ និងប្រទេសទាំងអស់។ ទោះជាយ៉ាងនេះក្តី របៀបដែលគេយល់ឃើញ និងប្រព្រឹត្តិអាចមានភាពខុសគ្នាដោយផ្អែកលើទម្លាប់វប្បធម៌ ការយល់ឃើញផ្អែកសាសនា ច្បាប់ប្រទេស ។ល។
- តើអ្វីទៅជាសិទ្ធិមនុស្ស?
  - ☝ សិទ្ធិមនុស្សគឺជាសិទ្ធិជាច្រើនដែលមានសារៈសំខាន់ចំពោះសុខុមាលភាព សេចក្តីថ្លៃថ្នូរ និងការគោរពរបស់បុគ្គលគ្រប់រូប។ ហើយវាជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូបដែលរស់នៅគ្រប់ទីកន្លែងទូទាំងពិភពលោក។
- តើមនុស្សទាំងអស់ជានិច្ចកាលត្រូវតែមានសិទ្ធិទាំងនេះឬ? តើនឹងមានអ្វីកើតឡើងប្រសិនបើសិទ្ធិទាំងនេះត្រូវបានដកហូត?
  - ☝ បាទ / ចាស! មនុស្សទាំងអស់ជានិច្ចកាលត្រូវតែមានសិទ្ធិទាំងនេះ ពីព្រោះសិទ្ធិទាំងនេះអនុញ្ញាតឱ្យមនុស្សរស់នៅប្រកបដោយសុខុមាលភាព ការគោរព និងភាពថ្លៃថ្នូរ។ ប្រសិនបើសិទ្ធិនេះត្រូវបានគេដកហូត នោះគេចាត់ទុកថាវាជារឿងអយុត្តិធម៌ចំពោះមនុស្ស និងជាការរំលោភបំពានសិទ្ធិមនុស្សរបស់គេ។
- តើសិទ្ធិមនុស្សដូចគ្នាទៅនឹងច្បាប់ឬ?
  - ☝ សិទ្ធិមនុស្សគឺមិនដូចច្បាប់នោះទេ។ គេសន្មតថា ច្បាប់គឺសម្រាប់ការពារ និងធានា សិទ្ធិមនុស្ស ប៉ុន្តែវាមិនដូច្នេះជានិច្ចកាលនោះទេ។ ឧទាហរណ៍ ៖ ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍មិនមានច្បាប់ដែលទទួលស្គាល់ ឬផ្តល់ការការពារប្រឆាំងនឹងការរំលោភសេពសន្ថវៈក្នុងជីវិតអាពាហ៍ពិពាហ៍ ដែលរំលោភលើសិទ្ធិរបស់បុគ្គលក្នុងការ

រស់នៅក្នុងជីវិតមួយដែលគ្មានអំពើហិង្សា និងការរំលោភបំពាន។

**គន្លឹះសម្រាប់គ្រូបង្រៀន**

- សិស្សអាចយល់ថាទស្សនៈទាននេះគឺថ្មីសម្រាប់ពួកគេទាំងស្រុង។ វាអាចមានភាពចាំបាច់ក្នុងការផ្តល់ឧទាហរណ៍មួយចំនួនភ្លាមៗ។ សម្រាប់លំហាត់ដើមឈើ លោកគ្រូ អ្នកគ្រូ អាចលើកឧទាហរណ៍ពីសិទ្ធិនានាដូចជា សិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ សិទ្ធិបោះឆ្នោត ជាដើម។ ប្រាប់សិស្សថា មិនមានចម្លើយដែលត្រូវ ឬខុសទេ ហើយពួកគេអាចសរសេរនូវអ្វីក៏បានដែលមាននៅក្នុងចិត្តរបស់ពួកគេ។
- ដើមឈើសិទ្ធិទាំងអស់ដែលសិស្សបានគូរត្រូវរក្សាទុកឱ្យមានសុវត្ថិភាពដើម្បីប្រើនៅក្នុងសកម្មភាពបន្ទាប់។

**សារសំខាន់ៗ ៖**

- សិទ្ធិមនុស្សគឺជាសិទ្ធិផ្សេងៗជាច្រើនដែលមានសារៈសំខាន់ចំពោះសុខុមាលភាព សេចក្តីថ្លៃថ្នូរ និងការគោរពរបស់បុគ្គលគ្រប់រូប។ វាគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូបទាំងអស់ដែលរស់នៅគ្រប់ទីកន្លែងទូទាំងពិភពលោក។
- សិទ្ធិមនុស្សមិនដូចគ្នានឹងច្បាប់នោះទេ។

# មេរៀនទី ១០ ៖ ការយល់ដឹងពីសិទ្ធិមនុស្ស[១០]

🕒 **រយៈពេល** ៖ ១ ម៉ោង

➲ **វត្ថុបំណង** ៖ ដើម្បីពន្យល់ពីសិទ្ធិមនុស្សផ្សេងៗដោយប្រើប្រាស់ភាសាសាមញ្ញៗ។

## ១. ការរៀបចំ

📖 **សម្ភារៈដែលត្រូវការ** ៖

- សម្រាប់គ្រូ៖ ក្រដាសផ្ទាំងធំ និងហ្វឺត ឬក្តារខៀន និងដីស ស្កុត ក្រដាស និងប៊ិក ឬខ្មៅដៃ (មានគ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗ) និងឯកសារចែកជូនទី៨ ៖ «សិទ្ធិមនុស្ស» (សិស្សម្នាក់មួយច្បាប់)។
- សម្រាប់សិស្ស៖ គ្មាន។

**ការរៀបចំទុកជាមុន** ៖

- អាន និងយល់លំនាំបង្រៀនឱ្យបានច្បាស់។
- ថតចម្លងឯកសារចែកជូនទី៨ ដើម្បីចែកសិស្ស។
- សរសេរសារសំខាន់ៗនៃមេរៀនដើម្បីបង្ហាញសិស្សនៅចុងម៉ោងមុនពេលបំបែកគ្នា។
- ប្រមូលសម្ភារៈចាំបាច់ទាំងអស់។

## ២. ដំណើរការបង្រៀន

📢 **សេចក្តីណែនាំ**

លោកគ្រូ អ្នកគ្រូត្រូវ ៖

- បែងចែកសិស្សជា៥ក្រុម
- បិទរូបភាពដើមឈើសិទ្ធិមនុស្សដែលបានគូរពីសកម្មភាពមុននៅលើជញ្ជាំងទុកជាមុន។
- ប្រាប់សិស្សថា ពួកគេនឹងលេងល្បែងមួយឈ្មោះថា «ល្បែងលើកោះ»។ ពួកគេនិងទៅ រស់នៅលើកោះថ្មីមួយដែលមានអ្វីៗគ្រប់យ៉ាងដែលចាំបាច់ដើម្បីអាចរស់រានមានជីវិតបាន។ មិនមាននរណាម្នាក់ធ្លាប់រស់នៅទីនោះទេពីមុនមក ដូច្នេះវាមិនទាន់មានច្បាប់ ឬប្រវត្តិអ្វីនៅឡើយ។ ពួកគេត្រូវបង្កើតបញ្ជីសិទ្ធិមនុស្សចំនួន១០ចំណុច ដែលនឹងត្រូវប្រើប្រាស់ដោយស្វ័យប្រវត្តិសម្រាប់អ្នកគ្រប់គ្នានៅលើកោះនោះមិនថាពួកគេមានតួនាទីអ្វី អត្តសញ្ញាណយេនឌ័រអ្វី ជាតិសាសន៍ ឬពូជសាសន៍អ្វី ស្ថានភាពសេដ្ឋកិច្ច ។ល។ បែបណាឡើយ។ ក្រុមនីមួយៗមានពេល១០នាទីដើម្បីសរសេរបញ្ជីនេះ។
- បន្ទាប់ពី១០នាទីបានបញ្ចប់ ក្រុមនីមួយៗត្រូវបង្ហាញពីបញ្ជីរបស់ពួកគេទៅកាន់ក្រុមធំ។ គេត្រូវចងក្រងបញ្ជីសិទ្ធិមនុស្សពេញលេញមួយដែលដាក់បញ្ចូលសិទ្ធិទាំងអស់ដែលក្រុមកោះទាំង៥

---

[១០] ក្រុមការងារកម្មវិធីសិក្សាពីផ្លូវភេទ និងជំងឺអេដស៍អន្តរជាតិ (២០០៩). *Its All One*. ក្រុមប្រឹក្សាប្រជាជន។

បានលើកឡើង។

☞ ណែនាំសិស្សឱ្យដឹងពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR) និងពន្យល់ពួកគេថា វាគឺជាបញ្ជីនៃសិទ្ធិសម្រាប់មនុស្សគ្រប់រូបនៅលើសកលលោក។ ចែកឯកសារចែកជូនទី៨ ៖ «សិទ្ធិមនុស្ស» ទៅឱ្យសិស្សទាំងអស់។ សុំឱ្យសិស្សម្នាក់ៗអានមាត្រាមួយៗឮៗ។ បន្ទាប់ពីអានរួច សុំឱ្យសិស្សសួរសំណួរផ្សេងៗសម្រាប់ការគូសបញ្ជាក់ និង ពិភាក្សាបន្ថែម។

## ៣. ការពង្រឹងចំណេះដឹង

**ចំណុចសម្រាប់ការពិភាក្សា ៖**

- តើមានចំណុចអ្វីខ្លះដែលស្រដៀងគ្នារវាងបញ្ជីដែលបានចងក្នុងការអនុវត្តសកម្មភាពនេះ និង បញ្ជីរបស់ UDHR?
- តើសិទ្ធិណាខ្លះដែលមាននៅក្នុងបញ្ជីរបស់ UDHR ដែលសិស្សមិនបានដាក់បញ្ចូល?
- តើយើងចង់ថែមសិទ្ធិណាមួយទៅក្នុងបញ្ជីរបស់យើងដែរ ឬទេ?
- តើមានសិទ្ធិណាមួយនៅក្នុងបញ្ជីរបស់ក្រុមមិនមាននៅក្នុង UDHR ដែរឬទេ?
- តើសិទ្ធិទាំងអស់នេះមានសារៈសំខាន់ស្មើៗគ្នា ដោយគ្មានសិទ្ធិណាសំខាន់ជាងសិទ្ធិណាមួយផ្សេងទៀតទេ?[១១]
    - **ជាសកល ៖** ចំណុចនេះមានន័យថា សិទ្ធិមិនមែនជាអភ័យឯកសិទ្ធិដែលមនុស្សម្នាក់មាននោះទេ ប៉ុន្តែជាអ្វីដែលមនុស្សគ្រប់គ្នាមានសិទ្ធិទទួលបានដោយមិនគិតពីទីកន្លែង ដែលគេរស់នៅ មកពីកុលសម្ព័ន្ធណា ឬថាតើពួកគេជាបុរស ឬស្ត្រី ។ល។ ទេ។
    - **មិនអាចបែងចែកបាន ៖** ចំណុចនេះមានន័យថា គេមិនអាចបង្កើតឋានានុក្រមរបស់ សិទ្ធិដោយចាត់ទុកថា សិទ្ធិមួយចំនួនមានសារៈសំខាន់ជាងសិទ្ធិផ្សេងទៀតបានទេ។ ឧទាហរណ៍ ៖ អ្នកមិនអាចអះអាងថាសិទ្ធិក្នុងការបោះឆ្នោតសំខាន់ជាងសិទ្ធិទទួលបានការថែទាំសុខភាពទេ។
    - **ទាក់ទងគ្នា ៖** សិទ្ធិមានទំនាក់ទំនង និងជួយពង្រឹងការអនុវត្តគ្នាទៅវិញទៅមក។ គេមិនអាចមានសិទ្ធិមួយពេញលេញដោយពុំមានសិទ្ធិផ្សេងទៀតទេ។ ឧទាហរណ៍ ៖ ដើម្បីមានសិទ្ធិទទួលបានការថែទាំសុខភាព គេចាំបាច់ត្រូវតែមានសិទ្ធិទទួលបានស្ថេរភាពសេដ្ឋកិច្ច និងរកប្រាក់ចំណូល។
    - **មិនអាចដកហូតបាន ៖** សិទ្ធិ និងសេរីភាពទាំងនេះមិនអាចត្រូវបានជំទាស់ ឬដកហូតពីបុគ្គលណាមាក់ឡើយ ហើយបុគ្គលម្នាក់ៗកើតមកមានសិទ្ធិដូចៗគ្នា។

---

[១១] TARSHI,. (២០០៦). *មូលដ្ឋាន និងលើសពីនេះ, សៀវភៅណែនាំសម្រាប់គ្រូបង្គោល, "ការរួមបញ្ចូលបញ្ហាផ្លូវភេទ ផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិ"* ។ ទីក្រុងញូវដេលី។

**គន្លឹះសម្រាប់គ្រូបង្រៀន**

- វាជាការចាំបាច់ដែលត្រូវរៀបចំឧទាហរណ៍ជាមុនដើម្បីពន្យល់អត្ថន័យរបស់ពាក្យគន្លឹះផ្សេងៗ ៖ ជាសកល មិនអាចបែងចែកបាន ទាក់ទងគ្នា និងមិនអាចដកហូតបានដែលសិស្សអាចភ្ជាប់ ឬនិងយល់បាន (ពិចារណាពីលក្ខខណ្ឌអាយុ និងបរិយាកាស)។
- វាមានសារៈសំខាន់ក្នុងការចងចាំថា នៅពេលដែលមនុស្សវ័យក្មេងចូលរួមក្នុងសកម្មភាពនេះមិនទាន់បានរៀបចំខ្លួនសម្រាប់ជំនាញ ឬឯកទេសទាក់ទងនឹងការងារស្តីពីសិទ្ធិ ពួកគេពិតជាត្រូវយល់ចេញពីក្នុងចិត្តខ្លួនឯងពីទស្សនៈទាននៃសិទ្ធិមនុស្សថាជាសិទ្ធិ និងសេរីភាពដែលមានចំពោះគេ និងអ្នកដទៃផ្សេងទៀតនៅក្នុងជីវិតរបស់គេ។ ហេតុដូច្នេះហើយគោលបំណងនៃមេរៀននេះគឺដើម្បីផ្តល់ឱ្យគេនូវទំនុកចិត្ត និងចំណេះដឹងពីទស្សនៈទានទាំងនេះដើម្បីគាំទ្រទំនុកចិត្តនោះ។

**សារសំខាន់ៗ ៖**

- មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែងសុទ្ធតែមានសិទ្ធិមនុស្ស។
- សិទ្ធិមនុស្សមានលក្ខណៈសកល មិនអាចបែងចែកបាន ទាក់ទងគ្នា និងមិនអាចដកហូតបាន។

**ឯកសារចែកជូនទី៨ ៖ សិទ្ធិមនុស្ស**[១២]

**បញ្ជីខាងក្រោមនេះពន្យល់ពីសិទ្ធិមនុស្សនីមួយៗនៅក្នុង UDHR ដោយប្រើប្រាស់ភាសាសាមញ្ញៗ ៖**

នៅពេលដែលកុមារចាប់កំណើត ពួកគេមានសេរីភាព ហើយកុមារគ្រប់រូបត្រូវទទួលបានសិទ្ធិដូចៗគ្នា។ ពួកគេមានហេតុផល និងមនសិកា និងគួរអនុវត្តចំពោះគ្នាទៅវិញទៅមកដោយមិត្តភាព។

មនុស្សគ្រប់រូបអាចទាមទារសិទ្ធិខាងក្រោមដោយមិនគិតពីភេទ ពណ៌សម្បុរ ភាសា ជំនឿនយោបាយ សាសនា ក្រុមសង្គម ប្រទេសកំណើត ឬស្ថានភាពប្រទេសថាមានឯករាជ្យ ឬមិនមានឯករាជ្យនោះទេ។ គេមានសិទ្ធិរស់រានមានជីវិត និងរស់រានដោយមានសេរីភាព និងសុវត្ថិភាព។

ពុំមាននរណាម្នាក់ប្រព្រឹត្តិចំពោះអ្នកដូចជាទាសកររបស់គេទេ ហើយអ្នកក៏មិនអាចប្រព្រឹត្តិដាក់នរណាម្នាក់ដូចជាទាសកររបស់អ្នកដែរ។

គ្មាននរណាម្នាក់មានសិទ្ធិធ្វើទារុណកម្មអ្នកឡើយ។

អ្នកទទួលបានការការពារដោយស្របច្បាប់ដូចគ្នាតាមវិធីដូចគ្នាទោះនៅកន្លែងណាក៏ដោយហើយមនុស្សផ្សេងៗទៀតក៏ទទួលបានការការពារក្នុងមធ្យោបាយដូចគ្នាដែរ។

មនុស្សគ្រប់គ្នាមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់។ គេត្រូវអនុវត្តច្បាប់ឱ្យស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប។

អ្នកត្រូវមានសិទ្ធិសុំជំនួយផ្នែកច្បាប់នៅពេលដែលសិទ្ធិដែលប្រទេសរបស់អ្នកបានផ្តល់ឱ្យអ្នកមិនត្រូវបានការគោរព។

គ្មាននរណាម្នាក់មានសិទ្ធិចាប់អ្នកដាក់ពន្ធធនាគារ ទុកអ្នកនៅទីនោះ ឬបញ្ជូនអ្នកទៅឆ្ងាយពីប្រទេសរបស់អ្នកដោយអយុត្តិធម៌ ឬគ្មានហេតុផលសមស្របទេ។

ប្រសិនបើអ្នកត្រូវទទួលការជំនុំជម្រះ ការជំនុំជម្រះត្រូវធ្វើឡើងជាសាធារណៈ។ បុគ្គលដែលកាត់ទោសអ្នកមិនត្រូវអនុញ្ញាតឱ្យខ្លួនទទួលរងឥទ្ធិពលពីអ្នកដទៃឡើយ។

គេត្រូវចាត់ទុកអ្នកថាជាមនុស្សស្អាតស្អំ(គ្មានទោស)រហូតដល់មានភស្តុតាងបញ្ជាក់ថាអ្នកបានប្រព្រឹត្តិទោសកំហុស។ ប្រសិនបើគេចោទប្រកាន់អ្នកពីបទឧក្រិដ្ឋ អ្នកត្រូវតែមានសិទ្ធិការពារខ្លួនរបស់អ្នកជានិច្ច។ គ្មាននរណាម្នាក់មានសិទ្ធិថ្កោលទោស ឬពិន័យអ្នកចំពោះអ្វីមួយដែលអ្នកមិនបានធ្វើទេ។

អ្នកមានសិទ្ធិស្នើសុំឱ្យមានការការពារប្រសិនបើមាននរណាម្នាក់ព្យាយាមធ្វើឱ្យខូចកេរ្តិ៍

---

[១២] ដកស្រង់ចេញពី ក្រុមការងារកម្មវិធីសិក្សាពីផ្លូវភេទ និងជំងឺអេដស៍អន្តរជាតិ (២០០៩). *Its All One*. ក្រុមប្រឹក្សាប្រជាជន។

ឈ្មោះរបស់អ្នក ចូលក្នុងផ្ទះរបស់អ្នក បើកមើលអ៊ីម៉ែលរបស់អ្នក ឬរំខានអ្នក ឬក្រុមគ្រួសារអ្នកដោយមិនមានហេតុផលសមស្រប។

អ្នកមានសិទ្ធិធ្វើដំណើរទៅមកនៅក្នុងប្រទេសរបស់អ្នកតាមចិត្តរបស់អ្នក។ អ្នកមានសិទ្ធិចាកចេញពីប្រទេសរបស់អ្នកទៅប្រទេសផ្សេងមួយទៀត ហើយអ្នកក៏ត្រូវតែអាចវិលត្រលប់មកប្រទេសរបស់អ្នកវិញបានដែរប្រសិនបើអ្នកចង់។

ប្រសិននរណាម្នាក់ធ្វើបាបអ្នក អ្នកមានសិទ្ធិស្វែងរកសិទ្ធិជ្រកកោន (ជម្រកសុវត្ថិភាព) នៅក្នុងប្រទេសផ្សេងមួយទៀត។ អ្នកអាចនឹងបាត់បង់សិទ្ធិមួយនេះប្រសិនបើអ្នកបានប្រព្រឹត្តិការរំលោភលើសិទ្ធិមនុស្សធ្ងន់ធ្ងរ។

អ្នកមានសិទ្ធិជាកម្មសិទ្ធិរបស់ប្រទេសមួយ ហើយពុំមាននរណាម្នាក់អាចឃាត់ឃាំងអ្នកមិនឱ្យក្លាយជាពលរដ្ឋរបស់ប្រទេសមួយផ្សេងទៀតដោយពុំមានហេតុផលសមស្របឡើយ។

ដរាបណាមនុស្សម្នាក់ទទួលបានសិទ្ធិស្របច្បាប់ក្នុងការធ្វើរឿងនេះ គេមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងមានក្រុមគ្រួសារ។ មិនថាអ្នកមានពណ៌សម្បុរអ្វី មកពីប្រទេសណា ឬកាន់សាសនាអ្វី វាមិនមែនជាឧបសគ្គចំពោះរឿងនេះឡើយ។ បុរស និងស្ត្រីមានសិទ្ធិដូចគ្នានៅពេលដែលពួកគេបានរៀបអាពាហ៍ពិពាហ៍ ហើយក៏ដូចគ្នាផងដែរនៅពេលដែលពួកគេបែកបាក់គ្នា។ គ្មាននរណាម្នាក់អាចបង្ខំមនុស្សម្នាក់ឱ្យរៀបការទេ។ រដ្ឋាភិបាលនៃប្រទេសរបស់អ្នកត្រូវការពារក្រុមគ្រួសារ និងសមាជិកក្រុមគ្រួសាររបស់អ្នក។

អ្នកមានសិទ្ធិកាន់កាប់កម្មសិទ្ធិផ្ទាល់ខ្លួន និងគ្មាននរណាម្នាក់មានសិទ្ធិដកកម្មសិទ្ធិនោះពីអ្នកដោយមិនមានហេតុផលត្រឹមត្រូវទេ។ អ្នកមានសិទ្ធិនិយាយពីសាសនារបស់អ្នកបានដោយសេរី ផ្លាស់ប្តូរសាសនា និងអនុវត្តសាសនាដោយខ្លួនឯង ឬជាមួយអ្នកដទៃ។

អ្នកមានសិទ្ធិគិតពីអ្វីដែលអ្នកចង់ និងនិយាយពីអ្វីដែលអ្នកចូលចិត្ត ហើយគ្មាននរណាម្នាក់អាចហាមឃាត់អ្នកមិនឱ្យធ្វើរឿងទាំងនេះទេ។ អ្នកមានសិទ្ធិចែករំលែកគំនិតរបស់អ្នកជាមួយអ្នករាល់គ្នា រួមទាំងអ្នកដែលមកពីប្រទេសផ្សេងផងដែរ។

អ្នកមានសិទ្ធិរៀបចំកិច្ចប្រជុំដោយសន្តិវិធី ឬចូលរួមក្នុងកិច្ចប្រជុំនានាដោយសន្តិវិធី។ គ្មាននរណាម្នាក់មានសិទ្ធិបង្ខំអ្នកឱ្យចូលរួមក្នុងក្រុមណាមួយទេ។

អ្នកមានសិទ្ធិដូចគ្នាទៅនឹងបុគ្គលដទៃដើម្បីចូលរួមជាផ្នែកមួយនៅក្នុងកិច្ចការនយោបាយក្នុងប្រទេសរបស់អ្នក។ អ្នកអាចធ្វើកិច្ចការនេះដោយចូលរួមជាផ្នែកមួយរបស់រដ្ឋាភិបាលដោយខ្លួនឯង ឬតាមរយៈការជ្រើសរើសអ្នកនយោបាយដែលមានគំនិតដូចគ្នា។ រដ្ឋាភិបាលត្រូវទទួលការបោះឆ្នោតជាទៀងទាត់ ហើយការបោះឆ្នោតគួរមានលក្ខណៈសម្ងាត់។ គេត្រូវតែអនុញ្ញាតឱ្យអ្នកបោះឆ្នោត ហើយសន្លឹកឆ្នោតទាំងអស់ត្រូវតែរាប់ដោយស្មើភាព។

សង្គមដែលអ្នករស់នៅត្រូវជួយអ្នកឱ្យអភិវឌ្ឍ និងបង្កើតនូវអត្ថប្រយោជន៍ល្អបំផុត

(វប្បធម៌ការងារ សុខុមាលភាពសង្គម) ដែលបានផ្តល់ឱ្យអ្នក និងមនុស្សគ្រប់គ្នានៅក្នុងប្រទេសរបស់អ្នក។

អ្នកមានសិទ្ធិបំពេញការងារ មានសេរីភាពក្នុងការជ្រើសរើសការងារ និងទទួលបានប្រាក់បៀវត្សដែលអាចឱ្យអ្នករស់នៅ និងផ្គត់ផ្គង់គ្រួសាររបស់អ្នកបាន។ ប្រសិនបើបុរស និងស្ត្រីធ្វើការដូចគ្នា ពួកគេត្រូវទទួលបានប្រាក់ឈ្នួលដូចគ្នា។ មនុស្សទាំងអស់ដែលធ្វើការមានសិទ្ធិចូលរួមដូចគ្នាដើម្បីការពារអត្ថប្រយោជន៍របស់ពួកគេ។

ថ្ងៃធ្វើការមិនត្រូវវែងពេកទេ ព្រោះគ្រប់គ្នាមានសិទ្ធិទទួលបានការឈប់សម្រាក និងអាចទទួលបាននូវថ្ងៃឈប់សម្រាកដោយមានប្រាក់ឈ្នួលទៀងទាត់។

អ្នកមានសិទ្ធិមាននូវអ្វីគ្រប់យ៉ាងដែលអ្នកត្រូវការដើម្បីឱ្យអ្នក និងក្រុមគ្រួសារមិនមានជំងឺមិនស្រេកឃ្លាន មានសម្លៀកបំពាក់ និងផ្ទះ និងទទួលបានជំនួយប្រសិនបើអ្នកមិនមានការងារធ្វើ អ្នកឈឺ អ្នកចាស់ ប្តី ឬប្រពន្ធស្លាប់ ឬអ្នកមិនមានលទ្ធភាពអាចផ្គត់ផ្គង់ការរស់នៅដោយសារមូលហេតុផ្សេងទៀតដែលអ្នកមិនអាចជួយខ្លួនឯងបាន។ ទាំងម្តាយដែលនឹងមានកូនព្រមទាំងកូនរបស់គាត់ត្រូវទទួលបានជំនួយជាពិសេស។ កុមារទាំងអស់មានសិទ្ធិដូចគ្នាទៅនឹងកុមារផ្សេងទៀត មិនថាម្តាយកុមារនោះបានរៀបអាពាហ៍ពិពាហ៍ ឬអត់នោះទេ។

អ្នកមានសិទ្ធិទៅសាលារៀន មនុស្សគ្រប់គ្នាត្រូវតែអាចទៅសាលារៀនបាន។ ការអប់រំនៅថ្នាក់បឋមសិក្សាត្រូវទទួលបានដោយអត់បង់ថ្លៃ។ អ្នកត្រូវតែអាចរៀនវិជ្ជាជីវៈ ឬជំនាញ ឬបន្តការសិក្សារបស់អ្នកឱ្យបានជ្រៅជ្រះតាមបំណងរបស់អ្នក។ នៅសាលាអ្នកត្រូវតែអាចអភិវឌ្ឍទេពកោសល្យរបស់អ្នកបាន។ គេត្រូវបង្រៀនអ្នកឱ្យចុះសម្រុងជាមួយអ្នកដទៃ ដោយមិនគិតពីពណ៌សម្បុរ សាសនា ឬសាវតារបស់គេឡើយ។ ឪពុកម្តាយរបស់អ្នកមានសិទ្ធិជ្រើសរើសពីវិធី និងអ្វីដែលអ្នកត្រូវរៀននៅសាលា។

អ្នកមានសិទ្ធិចូលរួមនៅក្នុងផ្នែកនៃសិល្បៈ និងវិទ្យាសាស្ត្រក្នុងសហគមន៍របស់អ្នក និងអំពើល្អណាមួយដែលពួកគេបានធ្វើ។ កិច្ចការរបស់អ្នកក្នុងនាមជាសិល្បៈករ អ្នកនិពន្ធ ឬអ្នកវិទ្យាសាស្ត្រត្រូវទទួលបានការការពារ ហើយអ្នកគួរតែអាចទទួលបានអត្ថប្រយោជន៍ពីការងារទាំងនោះ។

ដើម្បីធានាថាសិទ្ធិរបស់អ្នកត្រូវបានគេគោរព ចាំបាច់ត្រូវតែមានការបង្កើត«សណ្តាប់ធ្នាប់» មួយដែលអាចការពារវាបាន។ «សណ្តាប់ធ្នាប់» នេះគួរតែមាននៅក្នុងស្រុក និងទូទាំងពិភពលោក។

អ្នកមានកាតព្វកិច្ចចំពោះសហគមន៍របស់អ្នក។ ច្បាប់ត្រូវតែការពារសិទ្ធិមនុស្សរបស់អ្នក។ ច្បាប់ត្រូវតែអនុញ្ញាតឱ្យមនុស្សគ្រប់រូបគោរពអ្នកដទៃ និងទទួលការគោរពវិញដែរ។

មិនមានសង្គម និងមិនមានមនុស្សនៅផ្នែកណាមួយនៃពិភពលោកត្រូវប្រព្រឹត្តិទង្វើដែលបំផ្លាញសិទ្ធិដូចបានរៀបរាប់ខាងលើឡើយ។

# ឧបសម្ព័ន្ធទី១

## សន្លឹកកិច្ចការសិស្ស

## មេរៀនទី២ – ល្បែងស្ដីពីបំណងប្រាថ្នា

### កិច្ចការក្នុងថ្នាក់

**សេចក្ដីណែនាំ ៖**

ល្បែងជិះកង់គឺជាវិធីដ៏សប្បាយរីករាយមួយក្នុងការគិតពីការស្វែងរកផ្លូវឆ្ពោះទៅកាន់គោលដៅរបស់ប្អូន។

- តើនឹងមានបញ្ហាប្រឈមអ្វីខ្លះកើតឡើងនៅពេលប្អូនធ្វើតាមបំណងប្រាថ្នារបស់ប្អូន? ចូរសរសេរពីបញ្ហាប្រឈមចំនួន២ដែលប្អូនគិតឃើញ ៖

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………

- តើប្អូនមានផែនការអ្វីខ្លះដើម្បីជម្នះលើបញ្ហាប្រឈមដែលអាចកើតឡើងទាំងនេះ? ចូរសរសេរពីដំណោះស្រាយចំនួន២ដើម្បីជម្នះលើបញ្ហាប្រឈមទាំងនេះ ៖

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………



## មេរៀនទី៣ – មិត្តភក្តិទាំង៥នាក់របស់ខ្ញុំ ៖ គោលដៅ និងការកំណត់គោលដៅ

កិច្ចការក្នុងថ្នាក់

<u>ការកំណត់គោលដៅរបស់ខ្ញុំ</u>

| | គោលដៅ | ហេតុអ្វី? | អ្នកណា? | យ៉ាងណា? | ពេលណា? | ជាអ្វី? |
|---|---|---|---|---|---|---|
| ផ្ទាល់ខ្លួន | | | | | | |
| គ្រួសារ | | | | | | |
| ការអប់រំ/សាលារៀន | | | | | | |
| មិត្តភក្តិ | | | | | | |
| សុខភាព | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## មេរៀនទី៤ ៖ ការគ្រប់គ្រងពេលវេលា

**កិច្ចការក្នុងថ្នាក់**

**សេចក្ដីណែនាំ ៖**

<u>សន្លឹកសកម្មភាពបិទស្ទីគ័រ(រាងមូល)</u>

ក្នុងតារាងខាងក្រោម ចូរបិទស្ទីគ័រមួយសម្រាប់រៀងរាល់រយៈពេលមួយម៉ោងម្ដងដែលប្អូនចំណាយលើសកម្មភាពនោះ (សម្រាប់រយៈពេល ២៤ ម៉ោង)។ ឧទាហរណ៍ ប្រសិនបើនរណាម្នាក់ចំណាយពេល២ម៉ោងក្នុងមួយថ្ងៃសម្រាប់ការសិក្សា និងមួយម៉ោងសម្រាប់ការលេងកម្សាន្ត នោះគេនឹងបិទស្ទីគ័រដូចខាងក្រោម៖

| | |
|---|---|
| ការសិក្សា | ● ● |
| ការកម្សាន្ត | ● |

| | |
|---|---|
| ការងារផ្ទះ | |
| រៀបចំទៅសាលារៀន | |
| សាលារៀន | |
| ត្រលប់ទៅផ្ទះវិញ | |
| ញាំអាហារថ្ងៃត្រង់ | |
| ការសិក្សា | |
| ការលេងកម្សាន្ត | |
| ធ្វើកិច្ចការផ្ទះ | |
| ជួយការងារផ្ទះ | |
| គេង | |

ឯកសារចែកជូនទី៥ – តារាងពេលវេលាគំរូ

| សកម្មភាព | ម៉ោងក្នុងមួយថ្ងៃ | ម៉ោងក្នុងមួយសប្ដាហ៍ |
|---|---|---|
| គេង | | |
| អាហារពេលព្រឹក | | |
| អាហារថ្ងៃត្រង់ | | |
| អាហារពេលល្ងាច | | |
| ការងារ | | |
| រៀនសូត្រ | | |
| ការធ្វើដំណើរ | | |
| ការថែទាំខ្លួនឯង | | |
| កិច្ចការប្រចាំថ្ងៃ | | |
| ការកម្សាន្ត | | |
| សរុប | | |

## មេរៀនទី៥ ៖ តើខ្ញុំសម្រេចចិត្តដោយរបៀបណា?

**កិច្ចការផ្ទះ**

**សេចក្តីណែនាំ ៖**

- ចូរឆ្លើយសំណួរខាងក្រោម

សំណួរទី១ ៖ ចូរគិតពីស្ថានភាពដែលត្រូវសម្រេចចិត្តណាមួយដែលប្អូនធ្លាប់ឆ្លងកាត់ពីមុនមក និងរៀបរាប់ពីស្ថានភាពនោះ។

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

សំណួរទី២ ៖ ឥឡូវ ចូររៀបរាប់ពីរបៀបដែលប្អូនធ្វើការសម្រេចចិត្តនោះដោយប្រើប្រាស់វិធីសាស្ត្រដែលប្អូនបានសិក្សាក្នុងថ្នាក់ ឬមេរៀន និងឯកសារចែកជូនទី៦ - ជំហានប្រកបដោយប្រសិទ្ធភាពដែលជួយដល់ការធ្វើសេចក្តីសម្រេចចិត្ត ៖

សូមផ្អាកសកម្មភាពសិន ហើយធ្វើការគិតពិចារណា ៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

ផលវិបាកផ្សេងៗ ៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

ស្គាល់ ឬដឹងការពិត៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

ការសម្រេចចិត្ត ៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

សំណួរទី៣ ៖ តើមានភាពខុសប្លែកគ្នាណាមួយដែរ ឬទេចំពោះដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់ប្អូនដោយការប្រើប្រាស់វិធីសាស្រ្តនេះ និងឯកសារចែកជូនទី៦ - ជំហានប្រកបប្រសិទ្ធភាពដែលជួយដល់ការធ្វើសេចក្តីសម្រេចចិត្ត? សូមពន្យល់ឱ្យបានលម្អិតតាមដែលអាចធ្វើបាននៅខាងក្រោមនេះ។

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

# ឧបសម្ព័ន្ធទី២

## ទម្រង់វាយតម្លៃសិស្ស

ពិន្ទុសរុប
........../៤០

# កម្រងសំណួរការធ្វើតេស្តចំណេះដឹងសិស្ស សម្រាប់ក្មេងស្រី វ័យជំទង់ (ម៉ូឌុល ៤)

វិទ្យាល័យ ឬអនុវិទ្យាល័យ.....................ខេត្ត/ក្រុង..................ស្រុក/ខណ្ឌ................ឃុំ/សង្កាត់..................
ឈ្មោះគ្រូបង្រៀន...........................................ភេទ.............ឈ្មោះសិស្ស....................................ភេទ...........
ថ្នាក់ទី.................... កាលបរិច្ឆេទការធ្វើតេស្ត: ថ្ងៃទី...............ខែ.........................ឆ្នាំ.................

| ខ្លឹមសារ | ពិពណ៌នាសកម្មភាព | ផ្សេងៗ |
|---|---|---|
| **ម៉ូឌុលទី៤**: *ខ្ញុំ និងបំណងប្រាថ្នារបស់ខ្ញុំ* | | |
| ជំពូកទី១៖ បំណងប្រាថ្នា | | |
| ១.១. បំណងប្រាថ្នាជាអ្វី? លទ្ធផល ☐ | ☐ក. ជាការកំណត់ពីគោលបំណង់ច្បាស់លាស់។ | |
| | ☐ខ. ជាការដាក់គោលដៅនៃសេចក្តីត្រូវការរបស់យើង។ | |
| | ☐គ.ជាគោលបំណងដែលយើងចង់អោយវាសម្រេចបានក្នុងជីវិត។ | |
| | ☐ឃ. ជាការរំពឹងទុកថានឹងធ្វើអ្វីមួយ។ | |
| | ☐ង. មិនដឹង។ | |
| ១.២. តើការកំណត់បំណងប្រាថ្នាជាអ្វី? លទ្ធផល ☐ | ☐ក. គឺជាការគិតអំពីកត្តាផ្សេងៗដែលអាចសម្រេចគោលដៅ។ | |
| | ☐ខ. គឺជាការកំណត់គោលដៅតូចៗផ្សេងៗ។ | |
| | ☐គ. គឺជាជំហានដំបូងនៃការសម្រេចវា និងការគិតអំពីកត្តាផ្សេងៗ វិភាគអំពីផលវិបាក និងកំណត់នូវគោលដៅតូចៗ។ | |
| | ☐ឃ. គឺជាជំហានដំបូងនៃការកំណត់គោលដៅដែលត្រូវធ្វើ។ | |
| | ☐ង. មិនដឹង។ | |
| ១.៣. ហេតុអ្វីបានជាអ្នកគិតថាការកំណត់គោលដៅមានសារៈសំខាន់? លទ្ធផល ☐ | ☐ក. ព្រោះដើម្បីផ្តល់នូវទិសដៅនិងគោលបំណងក្នុងជីវិតរបស់មនុស្ស។ | |
| | ☐ខ. ព្រោះយើងនឹងងាយស្រួលរៀបចំផែនការអនាគតរបស់យើង។ | |
| | ☐គ. ព្រោះធ្វើអោយយើងយល់ច្បាស់អំពីផែនការជីវិត។ | |
| | ☐ឃ.ព្រោះដើម្បីអោយយើងដឹងអំពីអ្វីដែលត្រូវធ្វើបន្តទៀត | |
| | ☐ង. មិនដឹង។ | |
| ជំពូកទី២៖ ការកំណត់អាទិភាព និងការគ្រប់គ្រងពេលវេលា | | |
| ២.១. តើធ្វើដូចម្តេចដើម្បីប្រើប្រាស់ពេលវេលាអោយមានប្រសិទ្ធភាព? លទ្ធផល ☐ | ☐ក. ត្រូវធ្វើផែនការ និងបែងចែកអោយដាច់រវាងកិច្ចការបន្ទាន់ និងកិច្ចការសំខាន់ និងកំណត់នូវកិច្ចការអាទិភាពផងដែរ។ | |
| | ☐ខ. គោរពពេលវេលាក្នុងការសិក្សា។ | |
| | ☐គ. កំណត់ពេលវេលាអោយបានច្បាស់លាស់ក្នុងការធ្វើអ្វីមួយ។ | |
| | ☐ឃ. ត្រូវរៀបចំផែនការពេលវេលា និងអនុវត្តផែនការ។ | |
| | ☐ង. មិនដឹង។ | |

| | | |
|---|---|---|
| ២.២. អ្វីទៅជាការសម្រេចចិត្តដ៏ត្រឹមត្រូវ?<br><br>លទ្ធផល<br>☐ | ☐ក. ជាការសម្រេចចិត្តក្នុងការធ្វើអ្វីមួយ។ | |
| | ☐ខ. គឺការធ្វើការជ្រើសរើសរវាងជម្រើសច្រើន ដោយធ្វើការពិចារណា។ | |
| | ☐គ. គឺការធ្វើការជ្រើសរើសរវាងជម្រើសច្រើន។ | |
| | ☐ឃ. គឺការធ្វើការជ្រើសរើសរវាងជម្រើសច្រើន ដោយឆ្លងកាត់ការពិចារណាយ៉ាងហ្មត់ចត់មុននិងសម្រេចចិត្ត។ | |
| | ☐ង. មិនដឹង។ | |
| ២.៣. អ្វីទៅជាការគ្រប់គ្រងប្រាក់ប្រកបដោយប្រសិទ្ធិភាព?<br><br>លទ្ធផល<br>☐ | ☐ក. ជាការរៀបចំផែនការថវិកានិងការសន្សំ ការកំណត់មុខចំណាយ។ | |
| | ☐ខ. ជាការចំណាយថវិកាលើមុខទំនិញដែលយើងចង់បាន | |
| | ☐គ. ជាការរៀបចំផែនការថវិកានិងការសន្សំ ដោយកំណត់មុខចំណាយច្បាស់លាស់ និងអនុវត្តផែនការជាប្រចាំប្រកបដោយប្រសិទ្ធភាព។ | |
| | ☐ឃ. ជាការចំណាយថវិកាត្រឹមត្រូវតាមផែនការ និងចំណាយលើមុខទំនិញអាទិភាព។ | |
| | ☐ង. មិនដឹង។ | |
| ជំពូកទី៣៖ ភាពជាអ្នកដឹកនាំ | | |
| ៣.១. នរណាជាអ្នកដឹកនាំ?<br>លទ្ធផល<br>☐ | ☐ក. គឺជាមនុស្សដែលមានទ្រព្យសម្បត្តិច្រើន និងបទពិសោធន៍។ | |
| | ☐ខ. គឺជាមនុស្សដែលមានអាយុច្រើន។ | |
| | ☐គ. មនុស្សគ្រប់រូបគឺជាអ្នកដឹកនាំ។ | |
| | ☐ឃ. គឺជាមនុស្សដែលមានបទពោសោធន៍និងមានចំណេះដឹងខ្ពស់ | |
| | ☐ង. មិនដឹង។ | |
| ជំពូកទី៣៖ សិទ្ធិមនុស្ស | | |
| ៣.២. អ្វីទៅជាសិទ្ធិមនុស្ស?<br><br>លទ្ធផល<br>☐ | ☐ក. គឺជាសិទ្ធិជាច្រើនដែលសំខាន់សំរាប់សុខុមាលភាព សេចក្តីថ្លៃថ្នូរ និងការគោរពរបស់មនុស្សគ្រប់រូបគ្រប់ទីកន្លែងទូទាំងពិភពលោក។ | |
| | ☐ខ. គឺជាសិទ្ធិដែលបុគ្គលម្នាក់ៗអាចធ្វើបាន ប៉ុន្តែត្រូវស្ថិតនៅក្រោមច្បាប់របស់ប្រទេសខ្លួន។ | |
| | ☐គ. គឺជាសិទ្ធិដែលយើងម្នាក់ៗអាចប្រើបានទៅតាមសេចក្តីត្រូវការ | |
| | ☐ឃ. គឺជាសិទ្ធិដែលមនុស្សគ្រប់រូបត្រូវតែទទួលបាន។ | |
| | ☐ង. មិនដឹង។ | |